# មជ្ឈមណ្ឌលឯកសារកម្ពុជា

*ព្រំ សារ៉ាត់ ភេទប្រុស (រស់)*
*តួនាទីៈ "យោធាជើងទឹក កងពល១៦៤"*
*សម្ភាសជាមួយឈ្មោះ ព្រំ សារ៉ាត់ អាយុ៥៩ឆ្នាំ*
*ស្រុកកំណើតនៅភូមិព្រៃឈើទាល ឃុំព្រះក្នុំ ស្រុកអង្គរជ័យ ខេត្តកំពត*
*រស់នៅភូមិអូរគ្រែង ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង*
*ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៧*
*សម្ភាសដោយៈ ឡុង ដានី*
*សរុបៈ ៩៧ទំព័រ*

ដានី ៖ ជំរាបសួរ បងខ្ញុំចង់ស្គាល់ឈ្មោះពូៗឈ្មោះស្អីដែរ?

សារ៉ាត់ ៖ ឈ្មោះខ្ញុំឈ្មោះ ព្រំ សារ៉ាត់ ។

ដានី ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

សារ៉ាត់ ៖ ខ្ញុំអាយុ៥៩ហើយ ។

ដានី ៖ ពូឈ្មោះ ព្រំ សារ៉ាត់ មានដាក់ឈ្មោះក្រៅទៀតដែរអត់?

សារ៉ាត់ ៖ ឈ្មោះក្រៅ មានតែស្រុកកំណើត ប៉ុននៅកន្លែងនេះអត់មានទេ ។

ដានី ៖ នៅនេះដាក់ឈ្មោះព្រំ សារ៉ាត់?

សារ៉ាត់ ៖ ស្គាល់តែមួយ ។

ដានី ៖ អាយុពូ៥៩?

សារ៉ាត់ ៖ បាទ!

ដានី ៖ ពូកើតឆ្នាំអីដែរ ឆ្នាំខ្មែរយើង?

សារ៉ាត់ ៖ ឆ្នាំខ្ញុំកើតឆ្នាំ១៩៤៩ ។

ដានី ៖ គ្រួសារពូឈ្មោះអីដែរ?

សារ៉ាត់ ៖ ឈ្មោះវែង រីម ។

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

សារ៉ាត់ ៖ គាត់អាយុ៤៩ ។

ដានី ៖ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់?

សារ៉ាត់ ៖ ៤នាក់ ប្រុស២ ស្រី២ ។

ដានី ៖ ពូសព្វថ្ងៃបង្កើតមុខរបរធ្វើអីដែរ?

សារ៉ាត់ ៖ ខ្ញុំមុខរបរខ្ញុំធ្វើស្រែ ចម្ការរឿងផ្សំតិចតួច ។

ដានី ៖ ពូស្រុកកំណើតនៅណា?

សារ៉ាត់ ៖ ខ្ញុំស្រុកកំណើតនៅភូមិព្រៃឈើទាល ឃុំព្រះភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។

ដានី ៖ ចុះគ្រួសារពូ?

សារ៉ាត់ ៖ គ្រួសារខ្ញុំនៅភូមិព្រៃឈើទាល ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវវិញ ។

ដានី ៖ សព្វថ្ងៃពូរស់នៅភូមិឃុំស្រុកអីដែរ?

សារ៉ាត់ ៖ សព្វថ្ងៃបច្ចុប្បន្នខ្ញុំនៅភូមិអូរគ្រែង ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង ។

ដានី ៖ ពូមករស់នៅភូមិអូរគ្រែងនឹងតាំងពី?

សារ៉ាត់ ៖ ខ្ញុំចូលមកនៅភូមិអូរគ្រែងឆ្នាំ១៩៩១ ឡើងពីជំរុំដីថៃចូលមកដល់ធ្វើផ្ទះធ្វើសម្បែង ។

ដានី ៖ ឪពុកម្ដាយពូគាត់ឈ្មោះអីដែរ?

សារ៉ាត់ ៖ ខ្ញុំឪពុកឈ្មោះព្រំ ទង ម្ដាយឈ្មោះ មិញ ញ៉ន ។

ដានី ៖ ចុះគាត់ទាំង២អត់នៅ?

សារ៉ាត់ ៖ គាត់ស្លាប់ហើយ ។

ដានី ៖ គាត់ស្លាប់ទាំង២នាក់?

សារ៉ាត់ ៖ គាត់ស្លាប់តាំងពី ឪពុកគាត់ស្លាប់ឆ្នាំ១៩៧៧ ម្ដាយស្លាប់តាំងពី៦៣ ។

ដានី ៖ ចុះកាលជំនាន់ឆ្នាំ៧៧នឹង ពូបានទៅចូលរួមអី?

សារ៉ាត់ ៖ ខ្ញុំឆ្នាំ១៩៧៧នឹង វានៅក្នុងក្របខណ្ឌថា៣ឆ្នាំ ។

ដានី ៖ ប៉ុន្តែពូអត់បានទៅទេ ពេលគាត់ខូច?

សារ៉ាត់ ៖ អត់បានទៅទេ ។

ដានី ៖ ចុះពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

សារ៉ាត់ ៖ បងប្អូនខ្ញុំ៥នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សារ៉ាត់ ៖ ស្រី១ ប្រុស៤ ។

ដានី ៖ សព្វថ្ងៃនៅទាំង៥?

សារ៉ាត់ ៖ សព្វថ្ងៃស្លាប់២ នៅសល់៣ ។

ដានី ៖ ស្លាប់ដោយសារអីទៅ?

សារ៉ាត់ ៖ ស្លាប់នៅចន្លោះក្នុងឆ្នាំ៧៩ ពេលយួនចូលមកនឹង ។

ដានី ៖ ស្លាប់ស្រីប្រុស?

សារ៉ាត់ ៖ ប្រុសទាំង២ បងខ្ញុំមួយ ប្អូនពៅមួយ ។

ដានី ៖ គាត់ធ្វើអីកាលនោះ?

សារ៉ាត់ ៖ កាលនឹងគាត់ធ្វើទ័ព ប្អូនពៅអត់ទាន់ធ្វើអី វាជាកុមារ ធ្វើដំណើរមកតាមសំដៅទិសយើង
ខាងលិចនឹងដែរ ប៉ុន្តែមកអត់ដល់ដាច់ស្បៀងតាមមើល ។

ដានី ៖ ២នាក់នឹងស្លាប់ដោយសារដាច់ស្បៀងទេ?

សារ៉ាត់ ៖ ២នាក់នឹង ម្នាក់ស្លាប់ដោយសារកងទ័ពបង ធ្វើកងទ័ព ។

ដានី ៖ ឈ្មោះអីទៅគាត់?

សារ៉ាត់ ៖ ព្រំ ស៊ី ។

ដានី ៖ ចុះប្អូនពៅ?

សារ៉ាត់ ៖ ប្អូនឈ្មោះ ហៅព្រំ ប្រុសៗ ។

ដានី ៖ សព្វថ្ងៃសល់៣នាក់ នៅ?

សារ៉ាត់ ៖ សព្វថ្ងៃខ្ញុំមួយ ប្អូនស្រីនេះមួយ ហើយនឹងប្អូនប្រុសមួយទៀតនៅខាងដងទង ។

ដានី ៖ ដងទង់ណា?

សារ៉ាត់ ៖ អាកន្លែងស្ពានវែង យើងទៅពីនេះតាមផ្លូវទៅនេះ ។

ដានី ៖ ក្នុងស្រុកសំឡូតយើងដែរ?

សារ៉ាត់ ៖ អានឹងវាព្រំប្រទល់សំឡូតនឹងរតនមណ្ឌល ។

ដានី ៖ ពូខស្ញាហ៏ទៅលេងស្រុកកំណើតទេ?

សារ៉ាត់ ៖ ខ្ញុំទៅបាន៣ដង ។

ដានី ៖ នៅដូចថាមីងមាអីគាត់នៅ?

សារ៉ាត់ ៖ បាទ!នៅស្គាល់ស្មាគមន៍ រាក់ទាក់ បានទៅធ្វើបុណ្យធ្វើអីដល់សពឪពុកម្តាយ ។

ដានី ៖ ពូកូនទីប៉ុន្មានក្នុងគ្រួសារ?

សារ៉ាត់ ៖ ខ្ញុំកូនទី២ ។

ដានី ៖ កាលពីក្មេងៗពូបានរៀនសូត្រអីដែរអត់?

សារ៉ាត់ ៖ ខ្ញុំកាលពីក្មេងនោះខ្ញុំរៀនគំរិតថ្នាក់បឋមសិក្សា ។

ដានី ៖ រៀននៅ?

សារ៉ាត់ ៖ យើងកាលនោះយើងហៅថ្នាក់ទី៩ យើងមាននែក!កុមារដ្ឋាន បញ្ញដ្ឋាន អដ្ឋិកដ្ឋាន និង មជ្ឈមដ្ឋានទី១ ទី២នោះណា សម័យនោះ ។

ដានី ៖ កាលនោះពូចេះអានចេះសរសេរអីច្បាស់ទេ?

សារ៉ាត់ ៖ បាទ!ចេះអានចេះសរសេរ លេចអាគាក់អីទៅរួច ។

ដានី ៖ នៅសាលាណាដែលពូរៀននឹង?

សារ៉ាត់ ៖ ខ្ញុំរៀននៅសាលាវត្ត ។

ដានី ៖ វត្តអីគេ?

សារ៉ាត់ ៖ វត្តថ្មី ឈ្មោះនៅក្នុងនេះគេហៅអន្លុយសមេត្រី នៅក្នុងឃុំព្រះភ្នំ ។

ដានី ៖ ពូរៀនដល់ឆ្នាំណា បានពូឈប់?

សារ៉ាត់ ៖ ខ្ញុំរៀនឈប់នៅឆ្នាំ១៩៦៣ ពេលដែលម្តាយស្លាប់ ។

ដានី ៖ នៅពេលម្តាយស្លាប់ពូឈប់រៀន?

សារ៉ាត់ ៖ បាទ!ទាល់ដៃ ទាល់ជើង អត់មានទៅចិញ្ចឹមបងចិញ្ចឹមប្អូន ។

ដានី ៖ កាលនឹងម្តាយពូស្លាប់ដោយសារមូលហេតុអី?

សារ៉ាត់ ៖ ជម្ងឺ ប្រហែលជាជម្ងឺមហារីកស្បូន ព្រោះគាត់ចេះតែឈឺក្នុងពោះ ។

ដានី ៖ ដល់ពេលពូឈប់មកៗធ្វើអីទៅ?

សារ៉ាត់ ៖ ឈប់ពីរៀន ធ្វើតែស្រែ ។

ដានី ៖ ធ្វើស្រែរហូតដល់ពេលណាទៅបាន?

សារ៉ាត់ ៖ ដល់ពេលឆ្នាំ១៩៧០ រដ្ឋប្រហារថ្ងៃ១៨មិនានឹងដូរ ។

ដានី ៖ ១៨មិនាឆ្នាំ៧០រដ្ឋប្រហារ យ៉ាងម៉េចទៅ?

សារ៉ាត់ ៖ ឆ្នាំ៧០រដ្ឋប្រហារ១៨មិនានឹង វាកើតប្រទេសយើងកលិយុគៗវាមានសភាពការណ៍បង្ហាញ ឲ្យយើងឃើញថាយុវជនមានការលំបាកហើយ ព្រោះពេលនោះគឺថាទាហានធៀវគីឡើងៗ ពីខាងត្បូងមកៗរាតត្បាតនៅតំបន់ស្រុកខ្ញុំនឹង គឺថាវាធ្វើតាមអំពើចិត្តយោធាដាស៊ីស ។ ឧទាហរណ៍ថា ផ្ទះមួយមានកង់ផ្ទះនោះមានកង់ វាយកកង់ទាំងអស់យកមកតំរៀបគ្នាហើយ កិនរថក្រោះ

ដានី ៖ មានអញ្ចឹងដែរ?

សារ៉ាត់ ៖ មាន ។

ដានី ៖ នៅខាងណានឹង?

សារ៉ាត់ ៖ នៅខាងស្រុកខ្ញុំ អន្លង់វែង ។

ដានី ៖ ឆ្នាំណា?

សារ៉ាត់ ៖ លោកសង្ឃ វាចូលមកដល់ក្នុងវត្តវាឲ្យលោកសង្ឃអាករមាន់ បោចមាន់ឲ្យវាធ្វើម្ហូបឲ្យវាស៊ី បញ្ញាតាចាស់ៗឲ្យឡើងចុងដូង បេះដូងឲ្យវាស៊ី ។ ដល់អញ្ចឹងយើងជាយុវជនឃើញអំពើបែបនេះយើងពិបាករស់ណា ដូច្នេះយើងត្រូវតែគេចខ្លួន ។

ដានី ៖ កាលនឹងពូបានឃើញផ្ទាល់ម៉ង?

សារ៉ាត់ ៖ ឃើញ ។

ដានី ៖ ឆ្នាំណាដែរពូក?

សារ៉ាត់ ៖ ឆ្នាំ១៩៧០ ។

ដានី ៖ ពួកធៀវគីមកពី?

សារ៉ាត់ ៖ ធៀវគី ។

ដានី ៖ ពេលពួកធៀវគីមកនឹង មានពួកវៀតកុងអីមកដែរអត់?

សារ៉ាត់ ៖ មាន ។

ដានី ៖ ចុះវៀតកុងយ៉ាងម៉េច?

សារ៉ាត់ ៖ ពួកវៀតកុងវាគេចៗខ្លួនៗវាចូលតែក្នុងភ្នំទេ ហើយវាមកៗវាធ្វើសកម្មភាពវៀតកុងគឺថា វាចូលមកវាចាត់តាំងពួកខ្មែរយើងឲ្យធ្វើរដ្ឋអំណាចបម្រើវា ។ ប៉ុនដោយឡែកខ្ញុំអីដូចថាខាងយុវជនណា គេអត់បានចាត់តាំងទេ ព្រោះខ្ញុំចេញពីផ្ទះមក ខ្ញុំមកចូលក្នុងកងទ័ព ។ កងទ័ពកាលនឹងយើងធ្វើជាកងទ័ពខ្មែរក្រហម ។

ដានី ៖ ពូដែលចេញៗមកធ្វើកងទ័ពនឹងខែណា ពូនៅចាំ?

សារ៉ាត់ ៖ ខ្ញុំចេញមកថ្ងៃទី៩ខែ៦ឆ្នាំ១៩៧០ ។

ដានី ៖ កាលនឹងពូស្ម័គ្រចិត្តទេ?

សារ៉ាត់ ៖ ស្ម័គ្រចិត្ត ព្រោះដោយសារការឃើញកម្លាំងគៀបសង្កត់ជាស៊ីសរបស់គេនឹង យុវជនទាំងអស់មកតែម្តង ។

ដានី ៖ កាលជំនាន់ពូមកនឹង មានយុវជនដែលពូនៅចាំ មានពីណាខ្លះអ្នកស្រុកជិតៗគ្នានឹង?

សារ៉ាត់ ៈ មកនឹងមានច្រើនណាស់ខ្ញុំចាំឈ្មោះមិនអស់ទេ តែខ្ញុំរាប់តែឈ្មោះអ្នកដែលមកជាមួយខ្ញុំនៅជិតគ្នាណា មានឈ្មោះបងខ្ញុំមួយព្រំ ស៊ីននឹង, គុន សុរ៉ាត, គុន សុវន, ហើយមួយទៀតមានតែក!ទឹម បានវិបុល, ឈឹម សារិន, ឈឹម ទូច មកច្រើនណាស់អ្នកដែលនៅក្នុងនឹងហើយកម្លាំងដែលមករួមក្នុងនឹងមាន២ស្រុកម៉ង ចេញ ។

ដានី ៈ ស្រុកអីគេ?

សារ៉ាត់ ៈ គឺស្រុកអង្គរជ័យ និងស្រុកទ្រាំង ។

ដានី ៈ ស្រុកទ្រាំងខេត្តតាកែវ?

សារ៉ាត់ ៈ បាទ!

ដានី ៈ ពេលដែលពូចេញពីផ្ទះនឹង មកធ្វើកងទ័ពនឹងចេញដាច់ពូភូមិតែម្តង?

សារ៉ាត់ ៈ បាទ!ដាច់ ។

ដានី ៈ ចេញមកកងទ័ពម៉ង?

សារ៉ាត់ ៈ បាទ!

ដានី ៈ ដល់ពេលដំបូងពូចូលកងទ័ពនៅក្នុងកងអី?

សារ៉ាត់ ៈ ខ្ញុំចូលមកដំបូង ខ្ញុំចូលក្នុងកងទ័ពតំបន់ គេហៅតំបន់កំពត ។

ដានី ៈ ក្នុងតំបន់កំពតនឹង ពីណាគេអ្នកគ្រប់គ្រង?

សារ៉ាត់ ៈ ក្នុងតំបន់កំពតនឹង កាលនឹងគណៈតំបន់មាន កង ចាប ។

ដានី ៈ ចុះខាងកងទ័ព?

សារ៉ាត់ ៈ កងទ័ពតែក!មាន សំ បិត ។

ដានី ៈ សំ បិត គាត់ខាងកងទ័ព ខាងបញ្ជាការកងទ័ព? ១

សារ៉ាត់ ៈ បាទ!គាត់ខាងបញ្ជាការក្នុងឋានៈ កាលនឹងមានតែកងទ័ពមានតែម៉ាកងអនុសេនាធំទេ ។

ដានី ៈ គ្នាតិចទេអញ្ចឹង?

សារ៉ាត់ ៈ គ្នាតិច ។

ដានី ៈ ប៉ុន្មាន?

សារ៉ាត់ ៈ មាន១០០នាក់ជាង ។

ដានី ៈ ប៉ុន្តែ សំ បិត គាត់ជាប្រធានកងវរសេនាធំ?

សារ៉ាត់ ៈ ប្រធានអនុសេនាធំ គាត់ស្នងការ កាលនឹងអ្នកនយោបាយបានន័យថាប្រធាន ។

ដានី ៈ ដល់ពេលក្រោពី សំ បិត ពីណាទៀត?

សាវ៉ាត់ ៖ នៅក្នុងអនុសេនាធំនឹងមាន បងរ៉ែន តាអែវ យាយសេម ហើយនឹងអស់ហើយថ្នាក់ខាងលើរបស់គាត់ណា ។

ដានី ៖ កាលនឹង ប៉ុន្តែកងចាប កងសែនឹង គាត់គណៈតំបន់?

សាវ៉ាត់ ៖ គណៈតំបន់ ។

ដានី ៖ គណៈតំបន់កំពត តំបន់៣៥?

សាវ៉ាត់ ៖ តំបន់៣៥ ។

ដានី ៖ គណៈតំបន់ជាមួយតាកង ចាប មានពីណាទៀតដែរអត់?

សាវ៉ាត់ ៖ តាមខ្ញុំចាំមានឈ្មោះបងរិន កាលនោះយើងមិនថាមានកម្លាំងប្រធានរណសិរ្ស ។

ដានី ៖ រិន នឹងឈូក រិន ហើយមិនមែនទេ?

សាវ៉ាត់ ៖ មិនមែនទេ ឈ្មោះអីរិនទេ ខ្ញុំចាំមិនបានទេ ប៉ុនគាត់ជាអនុធន ជាសង្ឃហើយគាត់ផ្សឹកគាត់រៀនខាងបាលី ។

ដានី ៖ ចុះពូធ្វើនៅកងទ័ពតំបន់នឹង នៅឈរជើងនៅម្តុំណាទៅ?

សាវ៉ាត់ ៖ ខ្ញុំឈរជើងតែម្តុំ ខាងជើងកំពតនឹងទេ ម្តុំស្ទឹងកែវយើងនឹងគេហៅស្រុកបច្ចុប្បន្នគេហៅស្ទឹងកែវ ភូមិស្រង៉ែ ម្តុំកោះស្លា ខាងត្បូងកោះស្លា ប៉ុនមិនមែននៅតាកែននេះ គឺខ្ញុំនៅខាងត្បូងវាជិតមកខាងទឹករួមខេត្តវិញ ។ ម៉ាចាប់ពីត្រឹមស្ទឹងកែវមក តំបន់ពួកខ្ញុំឈរជើង ស្ទឹងកែវធ្វើសកម្មភាពទៅត្បូង ទៅដល់កំណប់ ដល់ភូមិម៉ាប្រាំងភូមិអី មកលេងភូមិតាអេង ។

ដានី ៖ កាលនឹងយើងធ្វើកងទ័ពនៅនឹង យើងវាយទៅខាងណាវិញទៅ វាទៅខាង?

សាវ៉ាត់ ៖ យើងវាយទៅខាងទាហាន ។

ដានី ៖ ខាងទាហាននៅខាងកំពត?

សាវ៉ាត់ ៖ បាទ!ទាហានកំពត ។

ដានី ៖ ពូឈរជើងវាយនៅនឹងរយៈពេលប៉ុន្មាន?

សាវ៉ាត់ ៖ ខ្ញុំឈរជើងនៅនឹងរយៈពេល៤ឆ្នាំ ។

ដានី ៖ តាំងពី៧០ នឹងរហូត៤ឆ្នាំម៉ង?

សាវ៉ាត់ ៖ បាទ!៤ឆ្នាំ កាល៧៤ បានខ្ញុំឡើងទៅកងទ័ពភូមិភាគ ។

ដានី ៖ ដល់ពេលឆ្នាំ៧៤ផ្លាស់ពីតំបន់មកភូមិវិញ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ខែណាដែល ពូផ្លាស់?

សាវ៉ាត់ ៖ ខ្ញុំក្នុងខែ មុនចូលឆ្នាំ អាចខែ៣តាមមើល ។

ដានី ៖ ខែប្រាំងកាលនឹង?

សាវ៉ាត់ ៖ បាទ!ខែប្រាំង យុទ្ធនាការវាយកំពតឆ្នាំ៧៤ ខ្ញុំត្រូវឡើងមក ។

ដានី ៖ ពេលដែលផ្លាស់មកភូមិភាគនឹង យើងវាយបានកំពតហើយៗយ៉ាងម៉េច?

សាវ៉ាត់ ៖ នៅៗទេ ទីរួមខេត្តកំពតយើងកំពុងតែហ៊ុំព័ទ្ធដោយ អត់កងទ័ពរបស់លន់នល់អត់មានអីទេ មានតែតាមអាកាសទេ ។

ដានី ៖ ពេលដែលវាយនៅកំពតអីនឹង កាលនឹងគណៈតំបន់គេ ទីតាំងគណៈតំបន់នៅណាទៅ?

សាវ៉ាត់ ៖ ទីតាំងគណៈតំបន់ គាត់នៅខាងស្រែចែង ស្រុកឈូក នៅម៉ាដូវវត្តថ្មីយើង ស្រែចែង ខាងលិចស្រែក្នុង ។

ដានី ៖ អញ្ចឹងដូចថាតាចាបអីនឹង គាត់ធ្វើការនៅខាងមុំខាងស្រែចែង ខាងវត្តថ្មី?

សាវ៉ាត់ ៖ បាទ!គាត់ចុះមកក្នុងខេត្តកំពតនឹងទាំងមូល ។

ដានី ៖ ចុះកាលជំនាន់នឹង តាមុត គាត់នៅណា?

សាវ៉ាត់ ៖ តាមុត មាសមុតនេះគាត់នៅតំបន់១៣ហៅតំបន់តាកែវ ។

ដានី ៖ ប៉ុន្តស្រុកកំណើតគាត់នៅខាងនឹងដែរតើ?

សាវ៉ាត់ ៖ គាត់នៅស្រែក្នុង ។

ដានី ៖ ប៉ុន្តែគាត់ពេលតស៊ូ គាត់មកនៅខាងតំបន់១៣វិញ ខាងតាកែវវិញ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងពេលដែលឆ្នាំ ក្នុងខែ៣ឆ្នាំ៧៨នឹង ពួផ្លាស់មកតំបន់ មកភូមិភាគ ក្នុងកងទ័ពតំបន់ផ្លាស់មកទាំងអស់ ឬក៏យ៉ាងម៉េច?

សាវ៉ាត់ ៖ មកជ្រើសរើសកម្លាំងៗបញ្ចូល បូកបញ្ចូលហើយបានរៀបចំបានមួយវរសេនាតូចឡើងមក មាន ។ ដំបូងខ្ញុំមកនឹង បងឡូញ គាត់ទទួលរួម ប៉ុន្តែបងឡូញគាត់ស្លាប់ទៅបាននែក! សារីមិញនេះ ។

ដានី ៖ ឈ្មោះសារី?

សាវ៉ាត់ ៖ បាទ!ឈ្មោះសារីនឹង គាត់ទទួលរួមអ្នកដែលនៅ៥៤០ ប្រធានវរគាត់ទទួល ។

ដានី ៖ គាត់ទទួលប្រធានវរៈ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងគេជ្រើសរើសកងទ័ពតំបន់នឹង ជ្រើសរើសធ្វើជាវរសេនាតូចបណ្ដោយ?

សាវ៉ាត់ ៖ រៀបចំជាមួយវរសេនាតូច ហើយបានផ្ទុកម្នាំងមក បានពាអនុសេនាធំ ។

ដានី ៖ គាត់ឈ្មោះសារី ទទួលវរសេនាតូច?

សាវ៉ាត់ ៖ ប្រធានៗនយោបាយ ។

ដានី ៖ ចុះប្រធានបញ្ជាការ?

សាវ៉ាត់ ៖ ប្រធានយោធាឈ្មោះបូ ហើយសមាជិកឈ្មោះអួច ។

ដានី ៖ ឈ្មោះអួច?

សាវ៉ាត់ ៖ មាស អួច ។

ដានី ៖ ចុះវរសេនាតូច?

សាវ៉ាត់ ៖ ហ្នឹងហើយវរសេនាតូចហើយនឹង ។

ដានី ៖ ចុះនេះ អនុសេនាធំ?

សាវ៉ាត់ ៖ អនុសេនាធំមានខ្ញុំជាជាមួយអនុសេនាធំ ជាប្រធាន ហើយមាន មិញ ធន អនុសេនាធំ ហើយបាន ទឹម ដេន ។

ដានី ៖ យើងពាអនុសេនាធំនឹងមកចូលជាមួយ?

សាវ៉ាត់ ៖ បាទ!នៅក្នុងវរសេនាតូច ។

ដានី ៖ ភូមិភាគនឹងភូមិភាគស្អីគេ?

សាវ៉ាត់ ៖ ខាងភូមិភាគនារតី ។

ដានី ៖ ដល់ពេលយើងចូលមកភូមិភាគអញ្ចឹង យើងមានដាកងពលហើយនៅ?

សាវ៉ាត់ ៖ ចូលមកក្នុងភូមិភាគនឹង បានរៀបដាកងពល ក្នុងកងពលគេហៅកងពលទី៣ ។

ដានី ៖ អានឹងជិតចាប់ផ្ដើមរៀបដាកងពលហើយនឹង?

សាវ៉ាត់ ៖ បាទ!ចាប់ផ្ដើមមាន ក្នុងនារតីនឹងមាន៣កងពល កងពលទី១មានតាសឿន កងពលទី២មានតាប៊ិត កងពលទី៣មានបង មាស មុត ។

ដានី ៖ ក្នុងកងពលទី៣តាមុត គាត់ទទួលរួម?

សាវ៉ាត់ ៖ ទទួលនយោបាយ ។

ដានី ៖ ចុះខាងយោធា?

សាវ៉ាត់ ៖ ខាងយោធា បងរិនៗនៅកំពតនេះ ។

ដានី ៖ ឈ្មោះរិន ឈូក រិននឹងហើយ?

សាវ៉ាត់ ៖ មិនមែនទេ មិនមែនឈូក រិនទេ ឈូក រីន ។

ដានី ៖ ឈូក រីន?

សារ៉ាត់ ៖ បាទ!ឈូក រីន ។

ដានី ៖ រិននឹងសព្វថ្ងៃគាត់នៅណាដែរ?

សារ៉ាត់ ៖ គាត់ស្លាប់ហើយ ។

ដានី ៖ កងពលទី៣មានតែ២នាក់នឹងទេ ដែលទៅបួស?

សារ៉ាត់ ៖ បាទ!បងម៉ៃនឹង ក៏គាត់ស្លាប់ដែរ គាត់ជាអ្នកទទួលខុសត្រូវ ។

ដានី ៖ ចុះក្នុងកងពលទី៣ មានប៉ុន្មានវរសេនាធំ?

សារ៉ាត់ ៖ កងពលទី៣មាន៣វរសេនាធំ មានវរសេនាធំ១៣ ១៤ និង១៥ ។

ដានី ៖ ប្រធានវរសេនាធំ១៣ឈ្មោះអីទៅ?

សារ៉ាត់ ៖ វរសេនាធំ១៣ឈ្មោះអុំ ង៉ែត គាត់ស្លាប់ ។

ដានី ៖ ចុះ១៤?

សារ៉ាត់ ៖ ១៤បងសឿង គាត់ស្លាប់ដែរ ហើយយានគាត់ស្លាប់ ។

ដានី ៖ ១៥ឈ្មោះយាន?

សារ៉ាត់ ៖ ១៥នឹងបងយាន គាត់ស្លាប់ហើយ ។

ដានី ៖ ចុះអនុអី?

សារ៉ាត់ ៖ អនុអីខ្ញុំចាំមិនអស់ មានអុំស្រស់មួយ ក៏គាត់ស្លាប់ទៀត ។

ដានី ៖ ចុះកាល១២ កងពលទី២តាប៊ិត គាត់?

សារ៉ាត់ ៖ បាទ!

ដានី ៖ កងពលទី១ឈ្មោះសឿងនោះ?

សារ៉ាត់ ៖ បាទ!អុំសឿង ។

ដានី ៖ សព្វថ្ងៃសឿង គាត់?

សារ៉ាត់ ៖ គាត់ស្លាប់ដែរ ។

ដានី ៖ កាលនឹងកងពលទី៣ ដូចថាពេលនឹងគេបង្កើតហើយ សម្រាប់យើងវាយនៅទិសណាទៅ?

សារ៉ាត់ ៖ រៀបចំកងពលទី៣គេវាយសមរភូមិ ខ្ញុំឡើងមកគឺរៀបចំមកវាយសមរភូមិភ្នំពេញ ។

ដានី ៖ ខាងទិសណា?

សារ៉ាត់ ៖ ខាងទិសនារតី ម៉ាចន្លោះផ្លូវលេខ៤នឹងផ្លូវរថភ្លើងប៉ោយប៉ែត អានេះផ្លូវនេះ មុំម៉ាជួរកប់ស្រូវ....បច្ចុប្បន្ន ម៉ាភូមិនឹង ។

ដានី ៖ និយាយទៅវាចំខាងលិចចំម៉ង ច្រកខាងកំពង់ស្ពឺនឹង មកចំតែម្តង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ច្រកពីកំពង់ស្ពឺមកខាងខេត្តកណ្តាលវិញ ហើយម៉េច?

សារ៉ាត់ ៖ បាទៗ ។

ដានី ៖ អានឹងកាលច្រករបស់កំពង់ស្ពឺនឹងកាលនោះរបស់ខាងភូមិភាគពិសេស គេអ្នកកាន់?

សារ៉ាត់ ៖ ចំរុះគ្នា ពេលដែលខ្ញុំមករៀបចំសមរភូមិនឹង ខ្ញុំបានមកសហការជាមួយភូមិភាគពិសេស ដោយប្តូរសមរភូមិ ដូចថាខ្ញុំនៅខាងនារតីនេះ ដូច្នេះត្រូវតែដូរដោយសហការ ហើយយើង ដូចថាផ្លាស់ប្តូរសមរភូមិនោះត្រូវមានសហការគ្នា ដោយដើរមើលសមរភូមិទាំងអស់ ។ សមរភូមិនីមួយៗ ឧទាហរណ៍ថាខ្ញុំនៅសមរភូមិនេះ ត្រូវប្រគល់សមរភូមិនេះឲ្យទៅអ្នក ផ្សេងទាល់តែបង្ហាញពីទីតាំងនិងភូមិសាស្ត្រ ។

ដានី ៖ ភូមិសាស្ត្រគេធ្វើជាគូរផែនទី ហើយយ៉ាងម៉េច?

សារ៉ាត់ ៖ គូរផែនទី នៅលើក្រដាស់ខ្លះ ហើយនឹងយើងទៅមើលជាក់ស្តែង ។

ដានី ៖ អញ្ចឹងពេលដែលពូរៀបចំកងពលអីអស់ ម៉ាកងពលទី៣មកខាងដែលពូមានប្រសាសន៍មិញ ថានៅចន្លោះពីផ្លូវជាតិលេខ៤មកខាងរថភ្លើងទៅខាងបៅ៉យប៉ែតខាងអីនឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះកាលនឹងកងពល ខាងភូមិភាគពិសេស គេមានកងពលអីដែរអត់?

សារ៉ាត់ ៖ មានប៉ុន្តែខ្ញុំចាំគាត់មិនបាន ប៉ុន្តែមេបញ្ជាការរូមឈ្មោះ បងណាត បងទីនអី ខ្ញុំ គ្រាន់ស្គាល់ តែឈ្មោះទេ មិនបានជួបមុខទេ ។

ដានី ៖ ចុះឈ្មោះសារឿន?

សារ៉ាត់ ៖ បងសារឿន អានឹងគាត់នៅក្នុងកងពលទី២ ។

ដានី ៖ សារឿន គាត់នៅខាងកងពលទី២?

សារ៉ាត់ ៖ បាទ!ក្រោយមក បានឡើងភូមិភាគពិសេស ហើយគាត់ទៅកាន់៨០១ នៅខាងបាសាក់ ។

ដានី ៖ គាត់ឈ្មោះអីសារឿន?

សារ៉ាត់ ៖ ខ្ញុំអត់ចាំ ។

ដានី ៖ អញ្ចឹងចាប់ពីខែប៉ុន្មានទៅ បានពូមកនៅក្នុងចន្លោះមកនៅកន្លែងភូមិភាគ?

សារ៉ាត់ ៖ ខ្ញុំចាំបាន ខែ១២ ថ្ងៃទី៣០ ខែ១២ ឆ្នាំ១៩៧៤ គឺចូលវាយបើកសមរភូមិភ្នំពេញ ។

ដានី ៖ ថ្ងៃ១២?

សារ៉ាត់ ៖ ទេ! ថ្ងៃ៣០ ។

ដានី ៖ ថ្ងៃ៣០ខែ១២?

សារ៉ាត់ ៖ ថ្ងៃ៣០ ខែ១២ ធម្មតាយើងដាច់៣១ នឹងហើយ យប់ថ្ងៃ៣១នឹងចូលបើកសមរភូមិភ្នំពេញ ។

ដានី ៖ វាយចូលម៉ង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះចន្លោះពីខែ៣ ដល់ខែ១២នឹងយើងនៅ?

សារ៉ាត់ ៖ នៅក្នុងក្របខ័ណ្ឌ សមរភូមិផ្លូវលេខ៤ ដោះកញ្ជរ ។

ដានី ៖ ដោះកញ្ជរមកខាងកំពង់សោមនឹង?

សារ៉ាត់ ៖ ដោះកញ្ជរអាផ្លូវយើងទៅកំពង់សោមនឹង ដោះកញ្ជរខាងលិចភ្នំពេញ ខាងលិចកំពង់ស្ពឺ ។

ដានី ៖ អញ្ចឹងពេលដែលដកមកពីតំបន់ចូលភាគនឹង យើងរៀបចំកងពល រៀបចំដារចនាសម្ព័ន្ធចូលក្នុងកងពលភ្លាមៗនឹងម៉ង ហើយក៏?

សារ៉ាត់ ៖ បាទ!ឡើងមក ត្រូវរៀបចំក្នុងក្របខ័ណ្ឌកងពល ។ ឧទាហរណ៍ខ្ញុំមកពីនោះ១វរសេនាតូចឲ្យចូលនៅក្នុងវរសេនាធំ១៥នឹង មានប្រធានវរសេនាធំឈ្មោះបង យាននឹងគាត់គ្រប់គ្រង ។

ដានី ៖ ដល់ពេលចូលក្នុងក្រុម ទើបវាយខាងដោះកញ្ជរនឹង?

សារ៉ាត់ ៖ បាទ!រៀបចំវាយដោះកញ្ជរហើយ បានដកពីដោះកញ្ជរ ទៅវាយភ្នំពេញ សម្រេចផែនការរៀបចំបើកសមរភូមិវាយផ្តាច់ភ្នំពេញ ។

ដានី ៖ ចុះពេលដែលវាយចូលភ្នំពេញនឹង ពេលដែលកងទ័ពអីត្រូវរបួសឬក៏នេះគេយកទៅព្យាបាលពេទ្យនៅណាដែរ?

សារ៉ាត់ ៖ ពេទ្យនៅជិតនឹងដែរ នៅម្តុំ គេហៅភូមិខាងលិចត្នោតពងយើងនេះ ប៉ុន្តែឆ្ងាយដែរណា ។

ដានី ៖ អានឹងពេទ្យរបស់ភូមិភាគ ឬក៏ពេទ្យរបស់?

សារ៉ាត់ ៖ ពេទ្យរបស់ភូមិភាគ ។

ដានី ៖ គេហៅពេទ្យអីគេនឹង?

សារ៉ាត់ ៖ ពេទ្យនែក! ខ្ញុំចាំមិនបានពេទ្យនឹង គ្រាន់ចាំថាភូមិនឹង គេហៅភូមិក្រាំងទទឹង ។

ដានី ៖ ច្រវ៉ាវៀលអី?

សារ៉ាត់ ៖ បាទ!ម្តុំត្រង់ណាមិនដឹងទេ ប៉ុន្តែបើកសមរភូមិខ្ញុំអត់បានមកផង ព្រោះខ្ញុំអត់នៅអីនឹងគេមកតែយុទ្ធជនទេ ទៅទេចូលមក ។

ដានី ៖ ពេលដែលពូវាយចូលមកដល់ភ្នំពេញ ឆ្នាំ ១៧មេសាឆ្នាំ៧៥នឹងវាយចូលកន្លែងណា ច្រកណា?

សារ៉ាត់ ៖ ខ្ញុំចូលត្រឹមផ្លូវបែកចាន កំបូល ហើយខ្ញុំត្រូវដកមកកំពង់សោមវិញ ។

ដានី ៖ ដកមកភ្លាមៗ?

សារ៉ាត់ ៖ បាទ!ភ្លាមៗ ថ្ងៃនឹងខ្ញុំត្រូវចេញដំណើរមកភ្លាមម៉ង អត់មាននៅច្របូកច្របល់ក្រុងភ្នំពេញទេ ។

ដានី ៖ អត់មានចាំគេជម្លៀសប្រជាជនចប់ទេ?

សារ៉ាត់ ៖ អត់ទេ ។

ដានី ៖ ពូអត់បានឃើញ?

សារ៉ាត់ ៖ ខ្ញុំចេញមកមុន គ្រាន់ថាហក់ភ្នំពេញលើកទង់សហើយ ពោធិ៍ចិនតុង ទីបញ្ជាការទាំងអស់លើកទង់ស បញ្ជាការកងទ័ពឲ្យខ្ញុំកងទ័ពត្រូវធ្វើដំណើរឆ្ពោះមកកំពង់សោម ។

ដានី ៖ អញ្ចឹងពូអត់បានឃើញទិដ្ឋភាពគេជម្លៀសប្រជាជនគេទេ?

សារ៉ាត់ ៖ អត់ទេ ហើយបានមកជួបគាត់ជម្លៀសមកហើយ គាត់ក៏ដើរខ្ញុំក៏ធ្វើដំណើរមកជាមួយគ្នាមករហូតនឹង ។

ដានី ៖ កាលនឹងពេលដែលវាយមកដល់កន្លែងពោធិ៍ចិនតុង បញ្ជាការពីតាមុត គាត់បញ្ជាឲ្យមក?

សារ៉ាត់ ៖ បាទ!នៅកំពង់សោម ។

ដានី ៖ ដកមកកំពង់សោមនឹង ដកយ៉ាងម៉េចកាលនឹង គាត់បញ្ជាមកឲ្យដក?

សារ៉ាត់ ៖ ដកមកថាឲ្យយើងទៅកាន់ទិសកំពង់សោម ព្រោះកំពង់សោមមិនទាន់រៀបចំរៀបរយណា ។ ខ្ញុំធ្វើដំណើរដោយថ្មើរជើង ខ្ញុំដើរតាមផ្លូវលេខ៤រហូត ។

ដានី ៖ ទាំងកងពលទី៣ទាំងអស់?

សារ៉ាត់ ៖ មួយផ្នែក ។

ដានី ៖ ផ្នែកនឹងបានន័យថាផ្នែកយ៉ាងម៉េច?

សារ៉ាត់ ៖ ក្នុងកងពលទី៣ទាំងអស់នឹង ត្រូវមានបទបញ្ជាមកទាំងអស់ តែផ្នែកខ្លះមកបានមុន ផ្នែកខ្លះមកតាមក្រោយ កងខ្លះ អន្តភាពខ្លះ ។

ដានី ៖ ចុះដែលមកមុន ដែលពូថាថ្ងៃមកដល់ភ្លាមយើងដកមកកំពង់សោមភ្លាម ប៉ុន្មានដូចជាវរសេនាធំ ឬក៏យ៉ាងម៉េចដែរ ដកមកភ្លាម?

សារ៉ាត់ ៖ មកជាវរសេនាធំ ។

ដានី ៖ វរសេនាធំ១៥?

សារ៉ាត់ ៖ ១៥ក៏មក ១៤ក៏មក ១៣ក៏មក ។

ដានី ៖ ដល់ពេលនឹងថ្មើរជើងរហូត អត់មានជិះឡានជិះអីទេ?

សារ៉ាត់ ៖ បាទ! ថ្មើរជើងចំណុចខ្លះ ប៉ុន្តែខ្ញុំមកជិះឡានដល់វាលវិញ បានជិះចូលកំពង់សោម ។

ដានី ៖ ដើរថ្មើរជើងដល់វាលវិញ បានឡានជិះចូល?

សារ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងពេលដែលជិះមកតាមកំពង់សោមនឹង យើងថ្មើរជើងមក អត់មានវាយអីណាទេដ?

សារ៉ាត់ ៖ មកប៉ះគ្នានៅដោះកញ្ជរ។ អត់ទាន់ទេ កាលនឹងនរោត្តម ច័ន្ទរង្សី នៅនឹង ព្រោះគាត់អត់លើកទង់សរទេ ព្រោះគាត់មានទិសថាគាត់ត្រូវធ្វើដំណើរមកសមុទ្រនេះ ។ ប៉ុន្តែទទួលគាត់មក។ ផ្ទះមីនតាមផ្លូវ ផ្ទះមីនទន្ទឹមនឹងខ្ញុំដើរដែរ ខ្ញុំសួរមីនផ្ទះឃើញទាហានលើកទង់សចេញពីព្រៃនឹងម៉ង បានឃើញសញ្ញានរោត្ត ច័ន្ទរង្សីត្រូវរបួស ។

ដានី ៖ ត្រូវរបួស រួចទៅម៉េចទៅអញ្ចឹង?

សារ៉ាត់ ៖ ខ្ញុំក៏មកហួសមក ។

ដានី ៖ ចុះមានឃើញច័ន្ទរង្សីដែរអត់ នរោត្តម ច័ន្ទរង្ស?

សារ៉ាត់ ៖ ខ្ញុំឃើញ ។

ដានី ៖ ឃើញគាត់ទៅយ៉ាងម៉េចទៀតទៅ?

សារ៉ាត់ ៖ សភាពការណ៍ពេលនឹង ខ្ញុំគ្មានភារកិច្ចអីទេណា ខ្ញុំត្រូវធ្វើដំណើរហួសអញ្ចឹងមក គាត់ក៏នៅនឹងទៅ ។ រួចយើងគ្រាន់តែជួយរុំរបួសជួយអី ចាក់ថ្នាំអីទៅ ។

ដានី ៖ មានបានជួយរុំរបួស មានចាក់ថ្នាំអីដែរ?

សារ៉ាត់ ៖ ជួយ។ រុំរបួសគាត់ត្រូវត្រឹម។នេះ ព្រោះធម្មតាអាមីនផ្ទម័រ គេដាក់អាបែបអាទាហានគាត់កំពង់សាលានឹងទេ គាត់ដាក់ អាមីនបង់កៃដាក់ថ្មគេអូរ តែត្រូវម៉ាសភ្លើងវាផ្ទុះ។ អត់ស៊ីត្រង់ណាទេ ស៊ីម៉ាផ្លូវ ។ នឹងគាត់ល្អហើយអត់ស្លាប់នៅកន្លែង ។

ដានី ៖ មើលទៅរបួសដែលគាត់ត្រូវនឹង ហើយក៏យ៉ាងម៉េច?

សារ៉ាត់ ៖ ធ្ងន់ធ្ងរតំរង់នោម មិនមានលទ្ធភាពទេ សមរភូមិឆ្ងាយយ៉ាងនេះអត់មានលទ្ធភាព អត់ហួសពី៣ម៉ោងទេ ពេលវេលា ។

ដានី ៖ អញ្ចឹងពេលពូធ្វើដំណើរទៀតយ៉ាងម៉េច មកដល់វាលវិញទៀត បានជិះ?

សារ៉ាត់ ៖ បានជិះឡានចូលក្រុងកំពង់សោម ប្រជាជនគេជម្លៀសចេញហើយ ។ ខ្ញុំជួបប្រជាជនតាមផ្លូវ ខ្ញុំជួបប្រជាជនតាំងពីវាលវិញនឹងទៅរហូត ទៅដល់ក្រុង ។

ដានី ៖ បានន័យថាគេជម្លៀសប្រជាជនចេញពីកំពង់សោម ពេលពូជួននឹង ជួបគេជម្លៀសចេញពីកំពង់សោមហើយ?

សារ៉ាត់ ៖ បាទ!ជម្លៀសហើយ ព្រោះកងខ្ញុំនឹងគេមានកងតំបន់មួយគេហៅតំបន់៣៧ ។

ដានី ៖ ចុះយ៉ាងម៉េចទៅពេលដែលពូជិះឡានពីវាលវិញទៅកំពង់សោម?

សារ៉ាត់ ៖ អត់មានសភាពអីទេ ក្នុងសភាពការណ៍ធម្មតា ប្រជាជនឃើញឡាន គាត់ចេះតែងាកផ្លូវឲ្យយើងទៅៗ ។

ដានី ៖ អញ្ចឹងពេលនឹងចេញពីវាលវិញ ទៅដល់ក្រុងកំពង់សោមម៉ង?

សារ៉ាត់ ៖ ខ្ញុំអត់ទៅដល់ទេ ខ្ញុំនៅព្រលានយន្តហោះ កង កេង ។

ដានី ៖ នៅធ្វើអីនៅព្រលានយន្តហោះនឹង?

សារ៉ាត់ ៖ នៅត្រង់ថាជាកម្លាំងៗដូចថាធម្មតា កម្លាំងត្រៀមបំរុង ក្រែងលមានហេតុភេទអីផ្សេងនៅធម្មតានៅយោធា ។

ដានី ៖ នៅត្រៀមកន្លែង កង កេងនឹង ប៉ុន្មានយប់?

សារ៉ាត់ ៖ ខ្ញុំត្រៀមអស់រយៈពេល៧៥ខែ៦ ២ខែ ។

ដានី ៖ កាលនឹងទាំងម៉ាវរសេនាធំនៅនឹងទាំងអស់ ហើយយ៉ាងម៉េច?

សារ៉ាត់ ៖ ត្រូវពង្រាយ ចំណុចកងខ្ញុំនឹងបោះនៅចំណតព្រលានយន្តហោះ ចំណុចវរសេនាតូចខ្លះនៅស្ពានទឹកសាប ចំណុចវរសេនាតូចខ្លះនៅអាកន្លែងសេអ៊ី ឡើងពីចំណតរាមនឹងទៅ គេហៅចំណតរាម ចំណតសេអ៊ី ។

ដានី ៖ អញ្ចឹងក្នុងវរសេនាធំនឹង យើងពង្រាយកាន់តែខ្លាំងទៀត?

សារ៉ាត់ ៖ បាទ!ពង្រាយតាមផ្លូវរហូតដល់រាម ។

ដានី ៖ ពូនៅនឹងរយៈពេល២ខែ ពីថ្ងៃ១៧មេសាខែ៤ រហូតដល់ខែ៦?

សារ៉ាត់ ៖ បាទ!

## កាសែតទី១ ផ្នែក«ខ»

សារ៉ាត់ ៖ ហើយគាត់មានដីស្រែដីអីធ្វើនៅកន្លែងណាអញ្ចឹងទៅ យើងជួយចូលរួមជាមួយប្រជាជនធ្វើទៅ ។

ដានី ៖ កាលនឹងមានប្រជាជន គេនៅជាមួយកងទ័ពដែរ?

សារ៉ាត់ ៖ មានៗប្រជាជននៅតាមផ្ទះអញ្ជឹង ហើយកងទ័ពនៅតាមផ្ទះអញ្ជឹងទៅហើយសុំផ្ទះគាត់ស្នាក់ ខាងក្រោមអញ្ជឹងណា ហើយគាត់នៅខាងលើ យើងសុំគាត់សម្រាក ។

ដានី ៖ រយៈពេល២ខែ?

សារ៉ាត់ ៖ បាទ!២ខែ ។

ដានី ៖ ចុះកាលនឹងបញ្ជាការកងពលនៅណាទៅ,

សារ៉ាត់ ៖ នៅកំពង់សោម ។

ដានី ៖ ពេលដែលភ្ជាម បែកភ្ជាមកងពលមកដល់កំពង់សោមភ្ជាមដែរ?

សារ៉ាត់ ៖ បាទ!ទីបញ្ជាការ ។

ដានី ៖ ទីបញ្ជាការ ដូចថាតាមុតអីគាត់មកកំពង់សោមភ្ជាមដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ អញ្ជឹងវរសេនាធំ១៥នៅខាងរាមអញ្ជឹង?

សារ៉ាត់ ៖ វរសេនាធំ១៥ រាម ។

ដានី ៖ ចុះ១៣ ១៨?

សារ៉ាត់ ៖ ១៣កម្លាំងមួយចំនួន វរសេនាធំ១៣ទៅកោះរ៉ុងៗធំ ហើយវរសេនាធំ១៨នៅរាមខ្លះ ហើយឡើងទៅកោះថ្មីខ្លះ ហើយ១៥នៅមុំចំណោតនឹងខ្លះ ហើយទៅដល់ចំណោតសេអ៊ីនឹង ហើយកងពិសេសរបស់កងពលនឹងនៅក្រុង ។

ដានី ៖ កងពិសេសរបស់គាត់នឹង គេហៅវរស្អីគេដែរអានឹង គេហៅ?

សារ៉ាត់ ៖ វរលេខប៉ុន្មានដូចជា៤៥០ ។

ដានី ៖ ៤៥០នឹងវរ?

សារ៉ាត់ ៖ ដូចខ្ញុំចាំមិនបានមិនយកជាដូវការ ។

ដានី ៖ អានឹងគេហៅកងពិសេសរបស់កងពល?

សារ៉ាត់ ៖ បាទ!ប៉ុនឈ្មោះថាកងពិសេស ។

ដានី ៖ អត់មាននៅក្នុងចំណោម?

សារ៉ាត់ ៖ បាទ!ក្រោមបញ្ជារបស់កងពល ។

ដានី ៖ ចុះពូមានប្រសាសន៍មិញថា ខាង១៨នៅខាងកោះរ៉ុង វរសេនាធំ១៨?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះនៅខាងកោះថ្មី កោះសេះ កោះអី?

សាវ៉ាត់ ៈ ហ្នឹងក្រោយមកបានដូរលេខណា ដូរលេខកងពល១៦៤វិញមិនអញ្ចឹង ។

ដានី ៈ អញ្ចឹងពីកងពលទី៣មក១៦៤នឹង ដូរពេលណា?

សាវ៉ាត់ ៈ ដូរមកពេលមកនៅកំពង់សោមនេះ ។

ដានី ៈ ពេលមកដល់កំពង់សោម គេដូរម៉េង?

សាវ៉ាត់ ៈ បាទ!គេដូរៗនៅឆ្នាំ៧៦ ។

ដានី ៈ អញ្ចឹងពេលដែលដូរលេខកងពល ពីកងពលទី៣មក១៦៤នឹងដូចថាមានលក្ខណៈយ៉ាងម៉េច បានគេដូរលេខវិញ?

សាវ៉ាត់ ៈ ដូរវាឡើងទៅជាកងទ័ពរបស់មជ្ឈិម ។

ដានី ៈ កងទ័ពមជ្ឈិម?

សាវ៉ាត់ ៈ ឈប់នៅក្នុងភូមិភាគហើយ ប្រាប់ថាកងទ័ពរបស់មជ្ឈិមមានប៉ុន្មានកងពល ថា១០កងពល ដូច្នេះ១៦៤ ១៥២ មានកងប៉ុន្មានៗខ្ញុំចាំមិនអស់ បើ៨០១នឹងវាអញ្ចឹងក្រោមការគ្រប់គ្រងរបស់មជ្ឈិម ។

ដានី ៈ និយាយទៅពូចាំថ្ងៃខែឆ្នាំ ដែលគេដូរដែរអត់?

សាវ៉ាត់ ៈ អត់បានចាំទេ ចាំឆ្នាំប្រហែលជា៧៦ ។

ដានី ៈ ៧៦?

សាវ៉ាត់ ៈ ប្រហែលទៀតណា ព្រោះវាភ្លេចយូរហើយ ។

ដានី ៈ អញ្ចឹងពេលដែលគេដូរ ដូចថាដូរលេខកងពលៗពីកងពលទី៣មក១៦៤នឹង វរសេនាធំអីនឹងគេដូរលេខដែរ?

សាវ៉ាត់ ៈ ដូរទាំងអស់ ។

ដានី ៈ គេដូរលេខថាម៉េច?

សាវ៉ាត់ ៈ ៦១ ៦២ ៦៣ ។

ដានី ៈ អញ្ចឹងដូចថាវរសេនាធំលេខ១៥ដូរមកលេខ៦០ប៉ុន្មានវិញទៅ?

សាវ៉ាត់ ៈ ១៥ទៅជា៦២វិញ ១៣ទៅជា៦១ ។

ដានី ៈ ១៤?

សាវ៉ាត់ ៈ ១៤ទៅជាមាន៣វរសេនាធំ ។

ដានី ៈ បាទ!៣ហើយ បានន័យថាវរសេនាធំ១៣ ៦១អញ្ចឹងទៅ ១៤?

សាវ៉ាត់ ៈ ១៤ ៦២ នឹងនៅកោះតាង ។

ដានី ៖ ចុះ៦៣?

សាវ៉ាត់ ៖ ៦៣កោះថ្មីៗ

ដានី ៖ ៦៣ ១៥នឹងនោះ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងពូនៅក្នុងវរសេនាធំណា ដល់ពេលគេដូរនឹង?

សាវ៉ាត់ ៖ ពេលនឹងរៀបមួយវរសេនាធំថ្មីទៀតហើយ ទៅជា១៨០ៗ

ដានី ៖ អញ្ចឹងពេលដែលគេមាន៦១ ៦២ ៦៣ គេបង្កើតវរសេនាធំមួយទៀតដាក់ថា?

សាវ៉ាត់ ៖ សម្រាប់គ្រប់គ្រងនាវា គឺ១៨០ៗ

ដានី ៖ អញ្ចឹងពេលនឹងយ៉ាងម៉េចទៅកាលនឹងពូ?

សាវ៉ាត់ ៖ ខ្ញុំត្រូវមករៀបបច្ចេកទេសហើយ ដកខ្លួនចេញពីថ្មើរជើងមកហាត់ហ៊ឹកហ៊ឺនបច្ចេកទេសៗ

ដានី ៖ អញ្ចឹងពេលដែលគេផ្លាស់ប្តូរកងទ័ព គេរៀបចំជាវរសេនាធំ១៨០ កាលនឹងគេរៀបយ៉ាងម៉េច គេដកកម្លាំង?

សាវ៉ាត់ ៖ ដកកម្លាំងជ្រើសរើសៗចេញពីថា១៨ ៥០នាក់ ឧទាហរណ៍ទេណា មិនចាំទេ ព្រោះខ្ញុំមិនចាំច្បាស់ទេ ដកគ្រប់វរសេនាធំម៉ង មករៀបចំៗ ហើយបានមានរើសមួយកងទៀត មកពីខាងបូព៌ា មកបញ្ចូលគ្នាៗ

ដានី ៖ ខាងមកពីខាងបូព៌ានឹងមកពី?

សាវ៉ាត់ ៖ ចំនួនកម្លាំងរួម៧០០ៗ

ដានី ៖ ៧០០មកពីខាងបូព៌ា?

សាវ៉ាត់ ៖ បាទ!ខាងនេះក៏៧០០ ខាងនោះក៏៧០០ មកបូកទៅ១០០០ជាង រៀបចំ១៨០ៗ

ដានី ៖ ១៨០នឹង១០០០ជាង?

សាវ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងក្នុងកងពល១៦៨នឹង មានបូព៌ាប៉ុន្មានទៅ?

សាវ៉ាត់ ៖ មាន៧០០នាក់ជាងៗ

ដានី ៖ អញ្ចឹងបូព៌ាមានតែនៅក្នុងកង១៨០មួយទេ?

សាវ៉ាត់ ៖ បាទៗៗ

ដានី ៖ ខាងជើងគោកមានណា?

សាវ៉ាត់ ៖ អត់មានទេ ជើងទឹក ជើងគោកនៅកោះអត់ៗ

ដានី ៖ ខាងបូព៌ានឹងពីណាគេធ្វើធំជាងគេមក?

សារ៉ាត់ ៖ មាននែក!ឈ្មោះ បងឌឹម ។

ដានី ៖ ឌឹមនឹង គាត់តួនាទីស្អីគេដែរ?

សារ៉ាត់ ៖ ហើយមកនឹង មកក្រុបខ័ណ្ឌជាកងពលមករៀបចំជាបញ្ជាការរបស់កងពល១៦៤ ។

ដានី ៖ ឌឹមនឹងគាត់មកក្នុងនាមជាបញ្ជាការកងពល ជាគណៈកងពល?

សារ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងដល់ពេលគេជ្រើសរើសចេញពីកងពលទី៣៧០០ ចេញពីបូព៌ា៧០០ បង្កើតជាវរសេនាធំ១ទៀតឈ្មោះថា១៨០ ។ កាលនឹងដល់ពេលគេបង្កើតជាវរសេនាធំ១៨០នឹងនៅឆ្នាំ៧៦នឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ពេលដែលគេប្តូរឈ្មោះកងពល?

សារ៉ាត់ ៖ បាទៗ ។

ដានី ៖ អញ្ចឹងគេបង្កើតវរសេនាធំថ្មីនឹង ប្រធានវរសេនាធំឈ្មោះអីទៅ?

សារ៉ាត់ ៖ ប្រធានវរសេនាធំខាងខ្ញុំឈ្មោះ បងសារឿន១៨០ ។

ដានី ៖ ឈ្មោះសារឿន ស្អីសារឿន?

សារ៉ាត់ ៖ ស្អីខ្ញុំមិនចាំ ដឹតាខ្ញុំភ្លេចហើយ ។

ដានី ៖ អ្នកមកពីស្រុកណា?

សារ៉ាត់ ៖ អ្នកមកពីកំពង់ស្ពឺ ភ្នំស្រួចយើង ឪពុកគាត់ឈ្មោះកន តែមិនដឹងជាកន សារឿន ឬមួយយ៉ាងម៉េច ខ្ញុំមិនចាំ ។

ដានី ៖ ប្រធានឈ្មោះសារឿន អនុ?

សារ៉ាត់ ៖ អនុឈ្មោះ សំ មកពីបូព៌ា គាត់មេបញ្ជាការ ។

ដានី ៖ ២នាក់នឹង?

សារ៉ាត់ ៖ បាទ!៣នាក់ ។

ដានី ៖ មួយទៀត?

សារ៉ាត់ ៖ អឺ!ភ្លេច ភ្លេចៗមែន វរសេនាតូចនៅចាំ ។

ដានី ៖ ចុះដល់ពេល១៨០នឹងមានប៉ុន្មានវរសេនាតូច?

សារ៉ាត់ ៖ មាន៤ មាន៤១ ៤២ ៤៣ ៤៤ ។

ដានី ៖ ចុះវរសេនាតូច៤១ឈ្មោះអីទៅ?

សាវ៉ាត់ ៖ វរសេនាតូច៤១ឈ្មោះអឺសាន អឺឈប់ៗវរសេនាតូច៤១ឈ្មោះមឿន ។

ដានី ៖ ឈ្មោះមឿន អនុគាត់ឈ្មោះអី?

សាវ៉ាត់ ៖ ៤២ ឈ្មោះសាង, ឈ្មោះមឿន អនុគាត់ឈ្មោះឌីន ។

ដានី ៖ ៤២?

សាវ៉ាត់ ៖ សាង ឈ្មោះភាង អនុ ។

ដានី ៖ ចុះ៤៣?

សាវ៉ាត់ ៖ ៤៣វ៉ែម ៤២ឈ្មោះអីមិញ?

ដានី ៖ ៤២ឈ្មោះសាន អនុឈ្មោះភាង?

សាវ៉ាត់ ៖ អូ!៤២អនុគាត់ឈ្មោះវ៉ែម មិនមែនភាង ។

ដានី ៖ ដល់ពេល៤៣?

សាវ៉ាត់ ៖ ៤៣បានប្រធាននេះឈ្មោះសាងវិញ ។

ដានី ៖ ចុះ៤២ប្រធានឈ្មោះអី?

សាវ៉ាត់ ៖ ៤២ប្រធានឈ្មោះគង់ ។

ដានី ៖ ឈ្មោះគង់ អនុឈ្មោះវ៉ែម?

សាវ៉ាត់ ៖ បាទៗ ឈប់ច្រឡំទេ មើលខ្ញុំប្រាប់ម្ដងទៀត ៤១ ៤២ ៤៣ ៤៤, ៤១ឈ្មោះមឿន អនុគាត់ឈ្មោះឌីម ៤២ឈ្មោះសាង អនុគាត់ឈ្មោះភាង ៤៣ឈ្មោះវ៉ែម ខ្ញុំភ្លេចគាត់ ខ្ញុំភ្លេចហើយ ៤៤ឈ្មោះហឹម អនុគាត់ឈ្មោះអីទេ ឈ្មោះម៉ាន ។

ដានី ៖ ពូនៅក្នុងវរណា?

សាវ៉ាត់ ៖ ខ្ញុំនៅក្នុងវរ៤៤ ។

ដានី ៖ អញ្ចឹង៤១ ដូចថាវរ៤១នឹងទទួលខាងអី ៤២ទទួលខាងអី ៤៣ទទួលខាងអីដែរ?

សាវ៉ាត់ ៖ ផ្នែកនាវាទាំងអស់ ។

ដានី ៖ អញ្ចឹងទាំង៤នឹងផ្នែកនាវា ប៉ុន្តែ៤១ខាងនាវាស្អីទៅ?

សាវ៉ាត់ ៖ នាវាកាលនឹងយើងដំបូងយើងមក ទៅទទួលនាវាទៅរៀបចំមកបាន៤នាវា មួយវរសេនាតូចទទួលមួយនាវា ។

ដានី ៖ អញ្ចឹង៤១ទទួលខាងនាវាស្អីគេ?

សាវ៉ាត់ ៖ នាវាការពារ ទាំង៤គ្រឿងនាវាការពារ ។

ដានី ៖ ចុះ៤២?

សារ៉ាត់ ៖ ៤២ក៏ការពារ ។

ដានី ៖ ៤៣?

សារ៉ាត់ ៖ ៤៣ការពារ ៤នាវានឹងការពារទាំងអស់ ។

ដានី ៖ ៤នាវានឹងការពារទាំងអស់ ប៉ុន្តែម៉ាវរការពារម៉ានាវា?

សារ៉ាត់ ៖ បាទ!មួយនាវាម៉ាគ្រឿង គ្រប់គ្រងមួយសិន កាលនឹងប្រធានវរសេនាតូចនឹងគឺគ្រប់គ្រង នាវាម៉ាគ្រឿង ។

ដានី ៖ អញ្ចឹងកាលពីដំបូងគឺមានតែ៤នាវាទេ?

សារ៉ាត់ ៖ បាទ! ។

ដានី ៖ ៤នាវានឹងក្នុងម៉ាវរសេនាតូច គ្រប់គ្រងម៉ានាវា?

សារ៉ាត់ ៖ បាទ!

ដានី ៖ មានគ្នាប៉ុន្មាននាក់ទៅ?

សារ៉ាត់ ៖ មាន៣៨រូប ។

ដានី ៖ អញ្ចឹងម៉ាវរសេនាតូច មានតែគ្នា៣៨នាក់អញ្ចឹង?

សារ៉ាត់ ៖ បាទ!អានឹងម៉ានាវា ។

ដានី ៖ ចុះកម្លាំងផ្សេងទៀត?

សារ៉ាត់ ៖ កម្លាំងផ្សេងទៀត នៅក្នុងកាគ្រប់គ្រងដដែល ។

ដានី ៖ ប៉ុន្តែនៅលើនាវានឹងមានតែ៣៧/៨រូប?

សារ៉ាត់ ៖ បាទ!ចូលក្នុងក្របខ័ណ្ឌបច្ចេកទេស ។

ដានី ៖ ប៉ុន្តែអ្នកផ្សេងទៀត អត់នៅក្នុងបច្ចេកទេសនឹង អ្នកនឹងនៅធ្វើអី?

សារ៉ាត់ ៖ នៅធម្មតា ជាកងបំរុង គ្រប់គ្រងនាវាមកថ្មី ។

ដានី ៖ អញ្ចឹងក្នុងម៉ាវរសេនាតូចនឹង មានប៉ុន្មានម៉ាអនុសេនាធំទៀតទៅ?

សារ៉ាត់ ៖ មាន៣ ។

ដានី ៖ ចុះពេលនឹងដូចនៅកង៤៤របស់ពូមាន៣វរសេនាធំដែរ?

សារ៉ាត់ ៖ ៣អនុសេនាធំ ។

ដានី ៖ កាលនឹងពូនៅក្នុងតួនាទីពូនៅក្នុងគណៈវរឬក៏នៅក្នុង?

សារ៉ាត់ ៖ ខ្ញុំតួនាទីអនុសេនាធំ ។១

ដានី ៖ ពូអនុសេនាធំទីប៉ុន្មាន?

សាវ៉ាត់ ៖ អនុសេនាធំទី២ ។

ដានី ៖ អានឹងមានលេខ?

សាវ៉ាត់ ៖ បាទ!មានលេខៗទី១ លេខទី២ លេខទី៣ ។

ដានី ៖ លេខទី១ប្រធានអនុសេនាធំទី១ឈ្មោះអីទៅ?

សាវ៉ាត់ ៖ ប្រធានអនុសេនាធំទី១ឈ្មោះ សិត ។

ដានី ៖ ទី២ពូ?

សាវ៉ាត់ ៖ ទី២ខ្ញុំ ។

ដានី ៖ ទី៣?

សាវ៉ាត់ ៖ ទី៣ចន ។

ដានី ៖ ក្នុងម៉ាអនុសេនាធំនឹងមានគ្នាប៉ុន្មាននាក់?

សាវ៉ាត់ ៖ មានគ្នា១០០នាក់ជាង ១១០ ឬ១១០ជាង តាមកម្លាំង ។

ដានី ៖ ក្នុងអនុសេនាធំនឹងមានអនុសេនាតូចតទៀត?

សាវ៉ាត់ ៖ បាទ!មាន៣អនុសេនាតូចទៀត ។

ដានី ៖ អញ្ចឹងដល់ពេលក្នុងម៉ានាវានឹងមានតែគ្នា៣៨នាក់ គេជ្រើសរើសម៉េចទៅ?

សាវ៉ាត់ ៖ ជ្រើសរើសចេះ ជ្រើសរើសប្រធាននាវាគឺថាវរសេនាតូចគ្រប់គ្រងយើងបានមកជំបូងគ្រប់គ្រងពិសេសសិន ហើយបានរើសអនុសេនាធំមួយជាអ្នករៀនក្នុងនឹងដែរ ។

ដានី ៖ គេរើសប្រធានអនុសេនាធំទៅរៀន?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ចុះក្នុងកង៣៨នាក់នឹង ជាកងពិសេសមួយរបស់វរ ហើយម៉េច?

សាវ៉ាត់ ៖ អត់ទេ វាជាផ្នែកមួយលើការគ្រប់គ្រងលើបច្ចេកទេសនាវាថ្មីដែរមកនឹងអត់មានជាពិសេសអីទេ ។

ដានី ៖ នាវា៤គ្រឿងៗបានមកពីណា?

សាវ៉ាត់ ៖ ចិន ។

ដានី ៖ ចិនយកមកឲ្យ?

សាវ៉ាត់ ៖ ឲ្យមក ។

ដានី ៖ ៤គ្រឿងនឹងសុទ្ធតែគេហៅនាវាការពារចិនប្រគល់មកឲ្យថ្មីម៉ងនាវានឹង?

សារ៉ាត់ ៖ បាទ!ថ្មីៗ

ដានី ៖ ចុះនារីចាស់ៗដូចថានារីសេសសល់មកពីជំនាន់?

សារ៉ាត់ ៖ អានឹងនៅក្នុងក្របខ័ណ្ឌកងពលគ្រប់គ្រង បញ្ជារចេញពីកងពល ប្រធាននារីមួយដូចជាពួក PGF ពួកធន់នារីដឹកជញ្ជូន T920 T918 សុទ្ធក្រោមបញ្ជារបស់កងពល ។

ដានី ៖ អានឹងក្រោមបញ្ជារបស់កងពលដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ពីខាងអ្នកកងពលពីខាងតាមុតទៅវិញ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះពេលដែលនារីដូចថានារីខាងការពារនឹងមានតួនាទីយ៉ាងម៉េចខ្លះទៅ?

សារ៉ាត់ ៖ នារីការពារនឹងតួនាទីគ្រាន់ថា ពេលនឹងដំបូងយើងគ្រាន់ហាត់ហ្វឹកហ្វឺនឲ្យចេះប្រើប្រាស់ទេ ។

ដានី ៖ ដំបូងយើងគ្រាន់ហាត់ហ្វឹកហ្វឺនទេ?

សារ៉ាត់ ៖ បាទ!ហាត់ហ្វឹកហ្វឺន ។

ដានី ៖ ពេលដែលពូចាប់ផ្ដើមរៀបជាវរសេនាតូចនៅគ្រប់គ្រងម៉ានារីៗនឹង គេចាប់ផ្ដើមហ្វឹកហ្វឺនយ៉ាងម៉េចខ្លះទៅ?

សារ៉ាត់ ៖ បង្ហាត់ហ្វឹកហ្វឺនដោយ មានផ្នែកវាណា បើកបរ ម៉ាស៊ីន កាំភ្លើង អគ្គិសនី ទូរគមនាគមន៍ ខាងទូរលេខ ខាងវិទ្យុទាក់ទង ហើយខាងសញ្ញា ។

ដានី ៖ រ៉ាដានឹង?

សារ៉ាត់ ៖ រ៉ាដាមួយទៀត ។

ដានី ៖ ដល់ពេលហាត់ហ្វឹកហ្វឺននឹង ហាត់នៅណាទៅ?

សារ៉ាត់ ៖ ហាត់នៅកំពង់សោម អូរឈើទាល ។

ដានី ៖ នៅអូរឈើទាល កាលនឹងគេជ្រើសរើសមានប៉ុន្មាន៦ ៧ផ្នែក មានខាងបើកបរមានម៉ាស៊ីន មានខាងសញ្ញា រ៉ាដា មានខាងទូរលេខ មានកាំភ្លើង មាន៦ អញ្ចឹងគេជ្រើសរើសទៅទាំងអស់ឲ្យទៅហ្វឹកហ្វឺននៅខាងអូរឈើកំពង់សោម គេចាប់ផ្ដើមជ្រើសរើសខែណាឆ្នាំណាពូចាំ?

សារ៉ាត់ ៖ ចាំមិនបានទេ ប៉ុន្តែក្នុងឆ្នាំ៧៦ ។

ដានី ៖ អញ្ចឹងនៅពេលដែលមកហ្វឹកហ្វឺននៅកំពង់សោម ហ្វឹកហ្វឺនរយៈពេលប៉ុន្មាន?

សារ៉ាត់ ៖ រយៈពេល៦ខែ ។

ដានី ៖ រយៈពេល៦ខែ?

សារ៉ាត់ ៈ បាទ!

ដានី ៈ ហ៊ីកហ៊ីននឹងខាងណាគេមក?

សារ៉ាត់ ៈ ចិន ។

ដានី ៈ ខាងចិនម៉ង?

សារ៉ាត់ ៈ បាទ!ចិនមកផ្ទាល់ ។

ដានី ៈ ចិនមកពីខាងប្រទេសចិន?

សារ៉ាត់ ៈ ស្រុកចិន ។

ដានី ៈ ចិនមកដូចថាពេលដែលគេហ៊ីកហ៊ីននឹង គេចេះខ្មែរយើងដែរ ឬក៏យ៉ាងម៉េច?

សារ៉ាត់ ៈ មានអ្នកបកប្រែ ចិននៅស្រុកខ្មែរគេអ្នកបកឲ្យយើង យើងចាំតែទទួលសរសេរជាភាសាខ្មែរ ។

ដានី ៈ ចិននៅខ្មែរ?

សារ៉ាត់ ៈ បាទ!

ដានី ៈ ឈ្មោះអីទៅពូនៅចាំឈ្មោះចិនដែលអ្នកបកប្រែ?

សារ៉ាត់ ៈ ខ្ញុំចាំ ឈ្មោះសាន ។

ដានី ៈ ឈ្មោះសាន?

សារ៉ាត់ ៈ សាន ហៅ លីម ។

ដានី ៈ គាត់ចេះចិន ចេះអីច្បាស់?

សារ៉ាត់ ៈ ចេះភាសាប្រាកដប្រជារបស់គាត់ ។

ដានី ៈ ប៉ុន្តែសាន លីមនឹង អ្នកនៅស្រុកខ្មែរយើង កូនចិន នៅស្រុកខ្មែរយើង?

សារ៉ាត់ ៈ បាទ!អ្នកនៅស្រុក ថៅកែនៅកំពង់ឆ្នាំង ។

ដានី ៈ នៅរស់ដែលអត់?

សារ៉ាត់ ៈ ប្រហែលជាមិនរស់ទេ ។

ដានី ៈ ប្រហែលជាស្លាប់ពេលណាទៅមើលទៅ?

សារ៉ាត់ ៈ ខ្ញុំបាត់គាត់ឆ្នាំ៧៧ ។

ដានី ៈ តែម្នាក់នឹងទេ អ្នកបកប្រែ?

សារ៉ាត់ ៈ មានច្រើននឹងទៀត ។

ដានី ៈ ប៉ុន្តែពូចាំតែម្នាក់នឹង?

សារ៉ាត់ ៖ បាទ!នារីនោះក៏មាន៤នាក់ ។

ដានី ៖ ពូចាំឈ្មោះនារីខ្លះទេ?

សារ៉ាត់ ៖ ចាំខ្លះ ធាមួយ មិត្តអេង មិត្តជីង ហើយប្រុសភ្លេចឈ្មោះ មាន៥នាក់ ។

ដានី ៖ ប៉ុន្តែនៅក្នុងចំណោមនឹងមានអ្នកនៅរស់អត់?

សារ៉ាត់ ៖ ប្រហែលជាគាត់មកស្លាប់ព្រំដែន គាត់ធ្វើដំណើរមក ។

ដានី ៖ ប៉ុននៅខាងតំបន់យើងនឹងមានអ្នកបកប្រែ?

សារ៉ាត់ ៖ អត់ៗមានទេ គាត់មកស្លាប់ៗនៅភ្នំខាងត្បូងនេះ ។

ដានី ៖ ឈ្មោះអីគេដែលស្លាប់?

សារ៉ាត់ ៖ ដែលស្លាប់មិត្តជីង មិត្តធាអីគាត់ស្លាប់នៅនឹង នារី ។

ដានី ៖ ស្លាប់ដោយសារ?

សារ៉ាត់ ៖ ស្លាប់ដោយសារធ្វើដំណើរដាច់ស្បៀង ។

ដានី ៖ ពេលដែល៧៩?

សារ៉ាត់ ៖ បាទ!៧៩ ។

ដានី ៖ កាលនឹងពូទៅចូលរៀនជាមួយគេដែរ?

សារ៉ាត់ ៖ ខ្ញុំរៀនដែរ ។

ដានី ៖ ពូរៀនខាងផ្នែកអី?

សារ៉ាត់ ៖ បើក ។

ដានី ៖ រៀនខាងបើកបរ?

សារ៉ាត់ ៖ ខាងប្រធាននាវាបញ្ជា ប៉ុនប្រធាននឹងគេត្រូវរៀនបច្ចេកទេសបើកបរ ។

ដានី ៖ យើងប្រធាននាវាមួយៗអ្នកនេះទៅ?

សារ៉ាត់ ៖ ត្រូវស្គាល់ទាំងអស់ ។

ដានី ៖ ចុះចិនដែលមកបង្រៀនយើង ពូនៅចាំឈ្មោះគាត់ទេ?

សារ៉ាត់ ៖ ចាំ ប៉ុនយើងមិនអាចថាយកត្រកូលគាត់បានទេ ។

ដានី ៖ បាទៗចាំឈ្មោះ ។

សារ៉ាត់ ៖ ឈ្មោះនែក!គ្រូបង្រៀនខ្ញុំឈ្មោះគ្រូលីន ។

ដានី ៖ ដូចឈ្មោះលីន ដែលមួយមកពីកំពង់ឆ្នាំង?

សារ៉ាត់ ៖ បាទៗ ។

ដានី ៖ គាត់រៀនម៉េច ឈ្មោះលីននឹង?

សារ៉ាត់ ៖ រៀនខ្ពស់ ធ្មេញឆ្កឹស នៅខេត្តណាដូចខេត្តខ្ញុំចាំមិនបាន ជាំងស៊ី ឬកុងស៊ី ប៉ុនស៊ីចុង មិនដឹង អាមួយណាទេ ខ្ញុំភ្លេចទៅ ។

ដានី ៖ ជាំងស៊ី ឬកុងស៊ី?

សារ៉ាត់ ៖ បាទ!

ដានី ៖ គាត់មកបង្រៀនទូទៅ ក៏គាត់រៀនបន្ថែម?

សារ៉ាត់ ៖ នឹងគាត់បង្រៀនខ្ញុំ ព្រោះផ្នែកទាំងអស់ដូចជាបែកតាមបច្ចេកទេស បើកបរគេបើកបរ រ៉ាដាៗ ម៉ាស៊ីនគឺម៉ាស៊ីន ។

ដានី ៖ អញ្ចឹងពេលដែលរៀនផ្នែកបើកបរនឹងមានគ្នាប៉ុន្មាននាក់?

សារ៉ាត់ ៖ រៀនមានគ្នា៤នាក់ ៥នាក់ ។

ដានី ៖ ៥នាក់ទាំងប្រធាន ម៉ាផ្នែកបើកបរនឹងមានគ្នា៤ ៥នាក់ទាំងប្រធានៗគឺពូ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ពូអ្នកប្រធានបើកបរនឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ផ្នែកបើកបរនឹងមានគ្រូតែម្នាក់ឈ្មោះលីននឹងទេ?

សារ៉ាត់ ៖ មាន២ ឬ៣នាក់តាមបច្ចេកទេស ។

ដានី ៖ ឈ្មោះអីគេ?

សារ៉ាត់ ៖ ព្រោះមានបើកបរវាបែកបច្ចេកទេសទៀត ខាងដែនទី ខាងត្រីវិស័យ ខាងខគុនិយម ចូលក្នុង ។

ដានី ៖ អញ្ចឹងក្នុង៥នាក់នឹង មានគេបែងចែកផ្សេងៗគ្នា មានអ្នក?

សារ៉ាត់ ៖ រៀនសរុប យកវិជ្ជារួម ទាំងអស់គ្នានឹងគឺត្រូវក្តាប់រូប ក្តាប់បច្ចេកទេសប៉ុន្មាននឹងរួមរៀនៗ ដូចជាត្រីវិស័យៗទាំងអស់ រៀបបើកបរៗទាំងអស់ រៀនមើលខគុនិយមដឹងទាំងអស់គ្នា ។

ដានី ៖ រៀនក្នុងកូនសិស្សយើងត្រូវរៀនចំរុះ ប៉ុនគ្រូមកបង្រៀន ផ្នែកមួយៗ?

សារ៉ាត់ ៖ បាទៗផ្នែកមួយៗ ហើយសាលាបន្ទប់ខុសគ្នា បើកគឺបើកបរណា គ្រូដែនទីមក គាត់បង្រៀនខាងដែនទី គ្រូសញ្ញា អឺ!នែកគ្រូមេដែក ត្រីវិស័យមក គាត់បង្រៀនត្រីវិស័យ ។

ដានី ៖ ចុះប្រធានវរមួយ មានមករៀនដែរអត់?

សារ៉ាត់ ៖ មក ក្នុងនឹង គឺប្រធានវរគាត់មក ។

ដានី ៖ ចូលរៀនដែរ?

សារ៉ាត់ ៖ បាទ!ចូលរៀនដែរ បច្ចេកទេស ។

ដានី ៖ ប្រធានវរមួយនឹងមករៀន ប៉ុន្តែមករៀនខាងអីគេ?

សារ៉ាត់ ៖ តួនាទីជាប្រធាននាវាដែរ រៀនបច្ចេកទេសនឹងដូចគ្នា ។

ដានី ៖ រៀបបច្ចេកទេសបើកបរដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះប្រធានវរមួយនឹងមករៀនបើកបរជាមួយពូ ក្នុងពេលជាមួយពូនឹងដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ប៉ុន្តែប្រធានវរនឹងមិនមែនមានតួនាទីជាប្រធាននាវាទេ គ្រាន់ប្រធានគ្រប់គ្រងលើនាវា?

សារ៉ាត់ ៖ បាទ!គ្រប់គ្រងរួម ។

ដានី ៖ ប៉ុន្តែប្រធាននាវា ដូចពូប្រធាននាវាដដែល?

សារ៉ាត់ ៖ បាទ!

ដានី ៖ ប្រធាននាវាការពារមួយ ដូចរៀបរាប់មិញថាមាន៨នាវានឹង?

សារ៉ាត់ ៖ បាទ!ប្រធាននាវានឹង ខ្ញុំគ្រប់គ្រងតែមួយនាវាទេ ហើយសមាជិកដែលនៅលើនាវានឹង ៣៨នាក់ ក្រោយមកាគ្រប់គ្រងរបស់ខ្ញុំ ការប្រជុំការរៀនសូត្រ ការដោះស្រាយបញ្ហាអី ទាំងអស់ ខ្ញុំជាអ្នកគ្រប់គ្រង ។

ដានី ៖ ចុះប្រធានវរ?

សារ៉ាត់ ៖ ប្រធានវរគាត់គ្រាន់តែដូចជាទីប្រឹក្សា ផ្តល់មតិនឹងជូនយោបល់បន្ថែមពីលើ ។

ដានី ៖ អញ្ចឹងពូចាប់ផ្តើមធ្វើប្រធាននាវាពេលចូលរៀននឹង ចាប់ផ្តើមធ្វើប្រធាននាវា?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះក្នុងនាវារបស់ពូៗមានប្រធាននាវាខាងបើកបរ ចុះខាងបច្ចេកទេសផ្សេងៗទៀតក្នុងនាវា របស់ពូមានឈ្មោះអីខ្លះទៅ?

សារ៉ាត់ ៖ នែក!មានផ្នែកម៉ាស៊ីនៗមានឈ្មោះគាត់ប្រធានរួម គាត់ឈ្មោះណម ហើយប្រធានកាំភ្លើង គាត់ឈ្មោះស៊ុំ ឈឹម ស៊ុំ ហើយប្រធានទូរលេខឈ្មោះ ណុក ប្រធានសញ្ញាអីតែម្នាក់ៗ ជាផ្នែកមួយតូចនៅក្នុងនឹង ហើយវ៉ាដា ។

ដានី ៖ ចុះពេលដែលយើងកំពង់រៀននឹង ដូចថាពេលដែលនាវាល្បាតគាមកន្លែងគេនៅមានដំណើរ ការធម្មតាហើយក៏យ៉ាងម៉េច?

សារ៉ាត់ ៖ នាវាល្បាតតាមពេលនោះយើងមកដឹបូងអត់ទាន់មាន ។

ដានី ៖ ៧៦អត់មាននាវាល្បាតទេ?

សារ៉ាត់ ៖ អត់ទេ ។

ដានី ៖ អត់មាននាវាការពារយាមអីទេ?

សារ៉ាត់ ៖ អត់ទេ ចូល៧៧បានចេញទៅយាម ។

ដានី ៖ អញ្ចឹងពេលដែល៧៦នឹង ពូមករៀននៅកន្លែងអូរឈើទាលនឹង រៀន៦ខែរៀនជាប់រាល់ថ្ងៃរហូត?

សារ៉ាត់ ៖ បាទ!រៀនរាល់ថ្ងៃ ។

ដានី ៖ ម៉ាថ្ងៃប៉ុន្មានម៉ោងទៅ?

សារ៉ាត់ ៖ ម៉ាថ្ងៃបង្រៀនតាមកម្មវិធី គឺថាព្រឹកល្ងាច ប៉ុន្តក្នុងម៉ាព្រឹកនឹងយើងរៀនតែ២ម៉ោងកន្លះអីទេ សិស្សក្តាប់បច្ចេកទេសបាន ។

ដានី ៖ ពេលរៀនហើយ គេអនុវត្តបើកលើនាវាបើក?

សារ៉ាត់ ៖ ដាក់ស្តែង ទ្រឹស្តីហើយដាក់ស្តែងៗហើយមកទ្រឹស្តី ប្តូរចុះ ប្តូរឡើង ។

ដានី ៖ រយៈពេល៦ខែពេញម៉ង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ក្នុងរយៈពេល៦ខែនឹង ពេលដែលរៀនអីនឹង តាមុតអីគាត់ធ្លាប់ចុះទៅ មើលចុះទៅណែនាំអី?

សារ៉ាត់ ៖ គាត់ទៅចុះជាប់ទៅមើលការហាត់ហ្វឹកហ្វឺនសិស្ស ហាត់ហើយយ៉ាងណាល្អអាក្រក់ សិស្សកម្រិតណាទទួលបាន ដើម្បី ។

ដានី ៖ គាត់មានដែលស្តីឲ្យពួកអ្នកដែលមាននេះ?

សារ៉ាត់ ៖ ហ៉េ!អត់ដឹងទេ ព្រោះបច្ចេកទេស គាត់មិនអាចជ្រៀតជ្រែកបានទេ ។

ដានី ៖ គាត់អត់មានមករៀនអីជាមួយទេ?

សារ៉ាត់ ៖ ប៉ុន្តគ្រាន់តែដឹងជាគោលៗ ។

ដានី ៖ ពេលនឹងដូចថាខាងគ្រូចិនគេនឹង គេស្នាក់នៅកន្លែងណាទៅ?

សារ៉ាត់ ៖ គេនៅកំពង់សោម ។

ដានី ៖ នៅកំពង់សោមនឹង ក្រៅពីកងពល១៦៤ មានខាងណាទៀតគេនៅ?

សារ៉ាត់ ៖ ខាងកំពង់ផែ ។

ដានី ៖ មានតែ២នឹងទេ?

សារ៉ាត់ ៖ កងការពារអាកាសរបស់៥០២ ។

ដានី ៖ កងការពារអាកាសនៅនឹងដែរ?

សារ៉ាត់ ៖ បាទ!កាំភ្លើងធំ ។

ដានី ៖ កងការពារអាកាសខាងណា?

សារ៉ាត់ ៖ ឈ្មោះ ខ្ញុំចាំមិនបាន ផ្អែក ។

ដានី ៖ មិនមែនតាម៉េតទេ?

សារ៉ាត់ ៖ មិនមែនទេ ។

ដានី ៖ ដូចថាខាងកំពង់ផែ ពីណាគេ?

សារ៉ាត់ ៖ កំពង់ផែ កាលដំបូង៧៦ ឈ្មោះបងផុច រិន ។

ដានី ៖ បាទ!

សារ៉ាត់ ៖ ផុច រិន ។

ដានី ៖ សព្វថ្ងៃគាត់នៅដែរ?

សារ៉ាត់ ៖ ប្រហែលជានៅបារាំង ព្រោះគាត់ចេញពីចលនាកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៨៥ គាត់ទៅបារាំង ។

ដានី ៖ ៨៥ គាត់ទៅបារាំងឆ្នាំ៨៥?

សារ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងអ្នកគ្រប់គ្រងធំជាងគេនៅកំពង់សោមនឹងពីណាគេទៅ?

សារ៉ាត់ ៖ គ្រប់គ្រងធំនៅកំពង់សោមមានតែគណៈកម្មការ ។

ដានី ៖ គណៈកម្មការណាទៅ?

សារ៉ាត់ ៖ គណៈកម្មការមានបងមុត មានគណៈកំពង់ផែនឹង កាលមុនដាក់ពីណាៗខ្ញុំចាំមិនបាន វាផ្អែកខាងលើនោះ ។

ដានី ៖ មានតាមុត មានខាងកំពង់សោម?

សារ៉ាត់ ៖ កំពង់ផែ ។

ដានី ៖ មានតែ២នឹងទេ?

សារ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងគ្រប់គ្រងកំពង់សោមទាំងមូល មានគណៈខាងកងទ័ពនៅកំពង់សោម ប៉ុន្តែ?

សារ៉ាត់ ៖ បាទ!តា ប៊ីប នឹង ខាងកម្មករ ។

ដានី ៖ ខាងកម្មករខាងកំពង់ផែ ជាគណៈកម្មការ?

សារ៉ាត់ ៖ កាលនោះបង ផុច រិន គាត់ទៅភ្នំពេញបានដាក់មនុស្សថ្មីទៀត មិនដឹងអ្នកណា ។

ដានី ៖ តាក្រិនអីកាលនឹង?

សារ៉ាត់ ៖ នឹងហើយតាក្រិននឹង ផុច រិននឹង ហៅក្រិន ស្គាល់ទេ ។

ដានី ៖ ខ្ញុំធ្លាប់ឃើញនៅក្នុងចម្លើយគេសរសេរ ពូក្រិនគាត់ខាងភស្តុភារ ។

សារ៉ាត់ ៖ កំពង់ផែចែកចាយ ចេញនឹងចូល ដូច៧៨បានចេញ ។

ដានី ៖ ចុះពូពេលដែលយើងរៀននៅជាមួយចិនចប់ហើយយ៉ាងម៉េចទៅអានឹង?

សារ៉ាត់ ៖ ចិនចប់ហើយ ខាងចិនគាត់ប្រគល់បច្ចេកទេសនឹងឲ្យយើងគ្រប់គ្រងដោយយើងប្រើប្រាស់ខ្លួនយើង ។ ការអ្វីដែលមិនទាន់អស់ឲ្យយើងបំពេញ ។

ដានី ៖ ចប់ឆ្នាំណា?

សារ៉ាត់ ៖ ចប់ក្នុងរយៈពេល៦ខែនឹង ។

ដានី ៖ យើងចូលរៀន៧៦ ប៉ុន្តែចប់វិញ ប្រហែលជាចប់នៅក្នុងឆ្នាំ៧៦ដែរ ក៏៧៧?

សារ៉ាត់ ៖ បាទ!៧៦ ។

ដានី ៖ ប្រហែលខែប៉ុន្មាន ដែលរៀនចប់ ដែលយើងបាន?

សារ៉ាត់ ៖ ក្នុងរយៈខែ៨ខែ៩នឹង ។

ដានី ៖ ដល់ពេលចប់ហើយយ៉ាងម៉េចទៅ យើងចេញមកធ្វើការងារយ៉ាងម៉េច?

សារ៉ាត់ ៖ ចេញមកធ្វើការងារនៅលើនាវា ប្រចាំការជាប់នៅលើនាវាទៅ ។

ដានី ៖ កាលនឹងនាវារបស់ពូនៅកន្លែងណាទៅ?

សារ៉ាត់ ៖ ខ្ញុំនៅមុខអូរឈើទាល ។

ដានី ៖ នៅចតមុខ អញ្ចឹងនាវាទាំងអស់នៅមុខអូរឈើទាល ហើយនៅកន្លែងណាខ្លះ?

សារ៉ាត់ ៖ នៅតាមចំនុចខ្លះៗទៅនៅកោះរ៉ុងសន្លឹម ព្រោះកន្លែងនឹងវាស្ងាត់ខ្យល់ស្ងាត់រលកអី ខែនេះយើងត្រូវទៅនៅនឹង វាធម្មតាកោះរ៉ុងសន្លឹម រៀងចេះ ។

ដានី ៖ គេហៅកោះរ៉ុងសន្លឹម?

សារ៉ាត់ ៖ កោះរ៉ុងសន្លឹម ។

ដានី ៖ រៀងម៉េចទៅ?

សារ៉ាត់ ៖ រៀងវាចេះ រៀងដង្កៀមក្តាមនោះ ដូចដង្កៀបក្តាមគ្រោងអញ្ចឹង ក្តាមឈ្មោល ។

ដានី ៖ ពេលនឹងយើងចូលទៅនឹង?

សារ៉ាត់ ៖ បាទ!ចូលទៅប្រឡោះ ទឹកវាទៅខាងលិចចេះវាមានកោះ វាមានភ្នំបាំង ហើយខាងក្នុងចេះវាមានទឹក ។

ដានី ៖ អញ្ចឹងយើងចូលទៅនៅក្នុងប្រឡោះនឹង អាប្រឡោះនឹងគេហៅកោះរ៉ុងសន្លឹម?

សារ៉ាត់ ៖ កោះរ៉ុងសន្លឹម ហើយមានតែកោះនឹងមួយកោះពិសេសដែលយើងស្រួលជ្រក ខ្យល់ខែនឹងខែភ្លៀងអញ្ចឹង គឺថាយើងទៅនៅនឹងស្រួលណាស់ ព្រោះកាលណាព្យុះ ខ្យល់មកពីទិសខាងនារតី ទិសខាងលិចនឹង វាបកទៅជិតកោះនឹងរលកនឹងវាផុតហើយណា អត់មានរលកចូលទេ ។

**កាសែ្សតទី២ ផ្នែក«ក»**

សារ៉ាត់ ៖ ទៅរៀនចប់នាវា៤គ្រឿងហើយ ត្រូវបន្ថែមមក៤ទៀត ។

ដានី ៖ ថែមមក៤ទៀត?

សារ៉ាត់ ៖ ៤ទៀត ។

ដានី ៖ ៤នឹងសុទ្ធតែនាវាការពារទាំងអស់?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះ៤ទៀតមក មានគេយ៉ាងម៉េចទៅ?

សារ៉ាត់ ៖ មានប្រធានតទៅទៀត ទៅជ្រើសរើសប្រធានទៀត ។

ដានី ៖ ប៉ុន្តែនៅក្នុងវរគ្រប់គ្រងដដែល?

សារ៉ាត់ ៖ បាទ!វរគ្រប់គ្រងដដែល ។

ដានី ៖ អញ្ចឹងបាន៤ទៀត វរម្នាក់គ្រប់គ្រង២?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះពួកន្លែងខ្ញុំធ្លាប់ដឹងពីមុនមក ដែលខ្ញុំធ្លាប់ជួបពូពីមុនមក គាត់ប្រាប់ថាក្នុងកន្លែងកាប៉ាល់នឹងវាមានប្រភេទដូចជាប្រភេទការពារ ប្រភេទប្រឆាំង ប្រភេទផ្តាច់មីន បណ្តែត ដូចពួកPGF អានឹងយ៉ាងម៉េចដែរពូ?

សារ៉ាត់ ៖ អានឹងវាក្របខ័ណ្ឌនាវា៤ប្រភេទនឹង អានឹងក្រោមការគ្រប់គ្រងរបស់១៤០ ហើយPGF អានឹងក្រោមការគ្រប់គ្រងរបស់កងពល ។

ដានី ៖ ចុះប្រភេទបណ្តែត ប្រភេទផ្តាច់មីនអី?

សារ៉ាត់ ៖ អានឹង១៤០ ។

ដានី ៖ នៅក្នុង៤គ្រឿងនឹងដែរ ហើយម៉េចប្រភេទ?

សារ៉ាត់ ៖ ហើយពេលនឹងយើងចែកជាជំនាញហើយ ជំនាញនាវាការពារមួយអង្គភាពរបស់ការពារ ជំនាញរបស់នាវាបណ្ដែត វាមួយអង្គភាពរបស់បណ្ដែត ។ ហើយជំនាញរបស់នាវាដោះមីនវាមួយអង្គភាពដោះមីន ។

ដានី ៖ មានប៉ុន្មានអង្គភាព ដូចអង្គភាពបណ្ដែត អង្គភាពការពារ អង្គភាពប្រឆាំង មានដោះមីន?

សារ៉ាត់ ៖ បាទ!

ដានី ៖ មានប៉ុននឹងទេ?

សារ៉ាត់ ៖ បាទ!មាន៥ ការពារ បណ្ដែត ដោះមីន ដឹកប្រេង ហើយប្រឆាំង ។

ដានី ៖ មានដឹកប្រេងទៀត?

សារ៉ាត់ ៖ បាទ!ដឹកប្រេងមួយ ។

ដានី ៖ ដឹកប្រេង ដឹកពីណាមក?

សារ៉ាត់ ៖ ដឹកនៅនឹងកំពង់សោមនឹង សម្រាប់ផ្គត់ផ្គង់ដូចថានាវាទៅចាក់ប្រេងទៅកោះរ៉ុង នាវាដឹកប្រេងយកទៅហើយ ដឹកប្រេងសម្រាប់បំពេញ ។

ដានី ៖ ទៅចាក់ប្រេងនៅកោះរ៉ុង?

សារ៉ាត់ ៖ បាទ! នាវានៅកោះ ឧទាហរណ៍ថានាវាប្រចាំនៅកោះប៉ូឡូវៃ ហើយយកនាវាដឹកប្រេងដែរគេចាក់នៅកោះប៉ូឡូវៃ ។

ដានី ៖ ចុះប្រធានដូចប្រធាននាវាមួយ ដូចប្រធាននាវាខាងប្រឆាំង ពីណាគេ?

សារ៉ាត់ ៖ ប្រធាននាវាប្រឆាំងមានមនុស្ស ខ្ញុំទៅរៀននៅចិននឹងខ្ញុំមកវិញមានខ្មោច ជន នេះមួយ ហើយមិត្តឡុននេះ ញ៉ែម ឡុន ២នឹងមកវិញដំបូង ២គ្រឿង ។

ដានី ៖ អានឹងខាងប្រឆាំង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះពេលចន្លោះគាត់ទៅរៀននៅស្រុកចិន ពីណាគេអ្នកប្រធាន?

សារ៉ាត់ ៖ អត់ទាន់មានទេ ទៅរៀនស្រុកចិនទាំងអស់ នាវាប្រឆាំងនឹងទៅរៀនស្រុកចិន ។

ដានី ៖ ចុះទៅដល់ចុងជិតឆ្នាំ៧៨ហើយ បានមាននាវាប្រឆាំង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះពីដំបូងមកអត់ទាន់មាននាវាប្រឆាំងទេ?

សារ៉ាត់ ៖ អត់ទេៗ ។

ដានី ៖ ទាន់តែពួកគាត់មកវិញ ដូចអ៊ីឡូននឹង ហើយនិង ជននឹងមកវិញបានមាន គាត់កាន់ខាងនាវាប្រឆាំង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះខាងការពារ?

សារ៉ាត់ ៖ ការពារ ប្រធាននឹងវា ដល់នឹងគេថាប្រធាននាវាមួយៗឡើងត្រង់ទៅវរសេនាតូច ឡើងទៅវរសេនាធំហើយ វាការពារទាំងអស់១០គ្រឿងៗ

ដានី ៖ នាវាការពារទាំងអស់១០គ្រឿង?

សារ៉ាត់ ៖ បាទ!ពី០១រហូតដល់១០ ៗ

ដានី ៖ នាវាការពារមួយមានគ្នាប៉ុន្មាននាក់?

សារ៉ាត់ ៖ ៣៨នាក់ៗ

ដានី ៖ ចុះប្រឆាំង?

សារ៉ាត់ ៖ ប្រឆាំង៥៧ ៗ

ដានី ៖ ប្រឆាំង៥៧?

សារ៉ាត់ ៖ បាទ!

ដានី ៖ ប្រឆាំងមានប៉ុន្មានគ្រឿង?

សារ៉ាត់ ៖ ២គ្រឿងៗ

ដានី ៖ ២គ្រឿង ដែលឈ្មោះ ឡូននឹង ហើយនឹងឈ្មោះ ជននឹង គាត់ធ្វើប្រធាន?

សារ៉ាត់ ៖ បាទ!២ ត្រៀម២គ្រឿងទៀត តែអត់ទាន់បានមកៗ

ដានី ៖ អត់ទាន់ប្រើ?

សារ៉ាត់ ៖ មានត្រៀម គង់ដែរ គាត់ទៅរៀននៅស្រុកចិនៗ

ដានី ៖ អញ្ចឹងទាន់តែឆ្នាំ៧៨ជិតបែកហើយ ជិត៧៩ហើយបានមាននាវាប្រឆាំង?

សារ៉ាត់ ៖ មកបាទ! មកអត់ទាន់បាន៣ខែទេ ទៅៗ

ដានី ៖ ចុះបើការពារមានយូរហើយ?

សារ៉ាត់ ៖ មានយូរ មានតាំងពីចុង៧៦មករហូតដល់៧៧នោះៗ

ដានី ៖ ទាំង១០គ្រឿងនឹង?

សារ៉ាត់ ៖ អត់ទេ មកវគ្គទី១ គឺ៧៦អាចបានតែ៤គ្រឿងទេ ដល់៧៧បានថែមមក៦ទៀតៗ

ដានី ៖ ថែមមក៦ទៀត ១០ ក្នុង១០គ្រឿងនឹងមានប្រធានមួយៗ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ចុះខាងដូចថានាវាការពារនឹងយើងមានភារកិច្ចធ្វើម៉េចខ្លះទៅ?

សាវ៉ាត់ ៖ ភារកិច្ចការពារអត់មានអីទេ យប់ឡើងចេញទៅឧទាហរណ៍ថានាវាខ្ញុំចេញទៅប្រចាំការ បោះ ល្បាតនៅកោះបុស្សី អានឹងខ្ញុំ ។

ដានី ៖ ពូនៅកោះបុស្សី?

សាវ៉ាត់ ៖ បាទ!កោះបុស្សី ហើយបើករ៉ាដាឃ្លាំងចាំមើល តើមានទូកមានកាណូតអីមកពីទិសខាងត្បូង ដោយគេថា ពាក្យថាខ្មាំងសត្រូវមកចូលដែនទឹកយើងប្អត់ ហើយរួមផ្សំជាមួយរ៉ាដានៅ បូលគោគេជួយផ្តល់ពត៌មានផង ។

ដានី ៖ មានរ៉ាដាពីភ្នំបូលគោមួយអ្នកផ្តល់ពត៌មាន ហើយយើងបើករ៉ាដានៅលើ?

សាវ៉ាត់ ៖ បាទ!យើងក៏មានគេក៏មាន ក្នុងនឹងយើងសង្កេតដូចគ្នា ។

ដានី ៖ ពូមើលទៅទិសខាងណា?

សាវ៉ាត់ ៖ ខ្ញុំទិសទៅខាងត្បូង ។

ដានី ៖ ទិសខាងត្បូងទិសទៅខាងណាវិញ?

សាវ៉ាត់ ៖ ពីបោះយុថ្កាខាងលិចកោះតាគៀវ ខាងត្បូងកោះតាគៀវ បើកទៅមើលទិសកោះបុស្សី អាបុស្សីនៅស្រុកយួន អានឹងរោងចក្រប្រេងកាតរបស់យួននៅសព្វថ្ងៃ ។

ដានី ៖ ពូនៅខាងទិសនឹង ត្រូវមើលទៅខាងទិសនោះវិញ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ប៉ុនអានឹងយើងមើលនៅពេលយប់ ហើយពេលថ្ងៃ?

សាវ៉ាត់ ៖ យប់ ។

ដានី ៖ ចុះពេលថ្ងៃ?

សាវ៉ាត់ ៖ ពេលថ្ងៃរ៉ាដាបូលគោ ហើយថ្ងៃឡើងខ្ញុំត្រឡប់មកវិញ ។

ដានី ៖ ត្រឡប់មកនៅណាវិញ?

សាវ៉ាត់ ៖ ហើយយប់ឡើងពេលដែលទៀបភ្លឺនឹង ខ្ញុំត្រូវវិញមកមូលដ្ឋានខ្ញុំអូរឈើទាលវិញ ។

ដានី ៖ ចុះក្នុង?

សាវ៉ាត់ ៖ អានឹងក្នុងចន្លោះឆ្នាំ៧៧ទេ បានៗធ្វើការដំណើរការ ប្រើប្រាស់ពេញសិទ្ធិ ។

ដានី ៖ ដល់ពេលនាវា៣ ៤ផ្សេងទៀតទៅនៅណា?

សាវ៉ាត់ ៖ ប្រចាំតាមទឹក មានប៉ូឡូវៃចាស់ ប៉ូឡូវៃថ្មី កោះតាំង ។

ដានី ៖ កោះតាងនាវាមួយណា?

សារ៉ាត់ ៖ នាវាផ្លាស់ប្តូរដែលនាវា មាន១៧-៤ ១៧-៧ ។

ដានី ៖ ចុះពួចាំថានៅខាងកោះៗ ពួនៅចាំប្រកកោះឫស្សីទៅខាងកោះ?

សារ៉ាត់ ៖ ត្រល់ ។

ដានី ៖ ពីខាងកោះតាគៀវទៅ?

សារ៉ាត់ ៖ បាទ!ចេញតាមទឹក ។

ដានី ៖ ចុះនាវាផ្សេងទៀត ដូចខាងប៉ូឡូវៃ មាននាវាពីណាគេទៅ?

សារ៉ាត់ ៖ នាវាមានប៉ុននឹងក៏៤គ្រឿង ។

ដានី ៖ ពីណាខ្លះទៅនាវានឹង?

សារ៉ាត់ ៖ នាវា១៧-៤ ១៧-៧ ១៧-៦ ១៧-៥ ។

ដានី ៖ ពួប្រធាននាវាមួយដែលមើលទៅខាងកោះឫស្សីដល់ពេលអ្នកដែលយើងចេះពីកោះតាគៀវ កោះត្រលល់ខាងស្រុកយួន ដល់ពេលអ្នកដែលនៅខាងកោះនេះ ដូចថាប្រចាំកោះប៉ូឡូវៃ មើលទៅខាងទិសណាទៅ?

សារ៉ាត់ ៖ មើលអានឹងមើលផ្តោតមកខាងកើតដូចគ្នា ។

ដានី ៖ ចុះប្រធាននាវាឈ្មោះអីទៅ?

សារ៉ាត់ ៖ គាត់ឈ្មោះខន ឈ្មោះអឺ ឈ្មោះខន ឈ្មោះសេង ប៉ុនខនអីគាត់ស្លាប់ហើយ ។

ដានី ៖ ចុះសេង?

សារ៉ាត់ ៖ សេង មិនដឹងជានៅណាបច្ចុប្បន្នមិនដែលជួប ។

ដានី ៖ ប៉ុនមុនធ្លាប់ជួបទេ?

សារ៉ាត់ ៖ តាំងពី៧៩មក អត់ម៉ង មិនដឹងជាស្លាប់ឬរស់ ប៉ុនខនខ្ញុំចាំបាន ។

ដានី ៖ ខន ស្លាប់ពីអន្កាល់?

សារ៉ាត់ ៖ ស្លាប់កាលគាត់វាយ ។

ដានី ៖ នាវានឹងមើលពីកោះប៉ូឡូវៃមួយណា ប៉ូឡូវៃចាស់ឬ?

សារ៉ាត់ ៖ ប៉ូឡូវៃចាស់និង ប៉ូឡូវៃថ្មីប្រចាំតែ២នឹងទេ ពេលខ្លះនៅកោះចាស់ ពេលខ្លះទៅកោះថ្មី ។

ដានី ៖ ប៉ុន្តែគាត់មើលទៅទិសខាង?

សារ៉ាត់ ៖ កើត ទិសអាគ្នេយ៍ ។

ដានី ៖ ទិសអាគ្នេយ៍ ទៅមើលទៅខាងស្រុកយួនដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះទៅខាងកោះសេះ កោះថ្មី?

សារ៉ាត់ ៖ កោះសេះ កោះថ្មី អានឹងនាវាខ្ញុំ ។

ដានី ៖ កោះសេះ កោះថ្មី អានឹងនាវាពូដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះកោះរ៉ុង?

សារ៉ាត់ ៖ កោះរ៉ុងអត់ទេ ព្រោះនៅចំណុចកណ្ដាល ប៉ុន្តែគ្រាន់បានទីសំចតរបស់នាវាដែលមិនបានធ្វើសកម្មភាព ត្រូវតែចតនៅកន្លែងនឹង ។

ដានី ៖ កោះតាង?

សារ៉ាត់ ៖ កោះតាងមាន ប៉ុនមើលទៅទិសខាងលិច ។

ដានី ៖ មើលទៅខាង?

សារ៉ាត់ ៖ ទិសមកនឹង ។

ដានី ៖ ទិសខាងលិចមកខាងស្រុកថៃ?

សារ៉ាត់ ៖ បាទ!មកថៃ សមុទ្រថៃ មកកោះ ដល់កោះគុត កោះអីនឹង ។

ដានី ៖ កោះគុត កោះអី កោះតាងៗនាវាប៉ុន្មានគ្រឿងនៅនឹង?

សារ៉ាត់ ៖ កោះតាងមាន២ដែរ ។

ដានី ៖ នាវាលេខប៉ុន្មានខ្លះនៅកោះតាង?

សារ៉ាត់ ៖ នាវា១៧-៤ និង១៧-៥ ។

ដានី ៖ ១៧-៤ ១៧-៥?

សារ៉ាត់ ៖ កោះប៉ូឡូវៃចាស់ ប៉ូឡូវៃថ្មី ១៧-៦ និង១៧-៧ ។

ដានី ៖ ១៧-៦ ១៧-៧ ចុះកន្លែងខាងពូ១០ប៉ុន្មាន ខាងកោះសេះនឹង?

សារ៉ាត់ ៖ នឹងតែខ្ញុំមួយគ្រឿងទេ ។

ដានី ៖ អានឹង១០ប៉ុន្មាន?

សារ៉ាត់ ៖ ១៧-១០ ។

ដានី ៖ ចុះ១៧-៨ ១៧-៩?

សារ៉ាត់ ៖ អានឹងនៅប្រចាំកោះរ៉ុង ពេលខ្លះកោះរ៉ុង ពេលខ្លះអូរឈើទាល ចល័ត ។

ដានី ៖ ១៧-៨ ១៧-៩ កោះរ៉ុង ហើយនឹងអូរឈើទាល ។ ចុះដូចជាមិញប្រធាន១៧-៦ ១៧-៧ ឈ្មោះខន ឈ្មោះសេង ១៧-១០ ពូ ចុះ ១៧-៨?

សារ៉ាត់ ៖ ១៧-៨ រ៉ន ។

ដានី ៖ ១៧-៩?

សារ៉ាត់ ៖ ១៧-៩ ហេន ។

ដានី ៖ ចុះពួកគាត់នៅអត់ ឈ្មោះរ៉េន អឺ!ចុះឈ្មោះរ៉ន?

សារ៉ាត់ ៖ គាត់ស្លាប់ហើយ ។

ដានី ៖ រ៉ន ស្លាប់ហើយ?

សារ៉ាត់ ៖ រ៉ន មិនដឹងជាស្លាប់ ឬរស់ទេ អត់ដឹង ប៉ុនហេនអត់ដឹង ១៧-៧នោះសឿន ។

ដានី ៖ ចុះខន ហើយសេង?

សារ៉ាត់ ៖ ខននឹងស្លាប់ហើយ ប៉ុនសេងមិនដឹងជាស្លាប់ឬរស់ ។

ដានី ៖ ខន ហើយសេងនៅក្នុង១០ប៉ុន្មាន?

សារ៉ាត់ ៖ សេង ៦ ។

ដានី ៖ ចុះខន?

សារ៉ាត់ ៖ ខន៥ ១៧-៥ សេង ១៧-៦ ។

ដានី ៖ ខន ១៧-៥ អញ្ជឹងគាត់នៅទិសខាងកោះ?

សារ៉ាត់ ៖ កោះនែក! គាង ។

ដានី ៖ ចុះ១៧-៤?

សារ៉ាត់ ៖ ១៧-៤ឈ្មោះនួន ។

ដានី ៖ គាត់នៅដែលអត់?

សារ៉ាត់ ៖ គាត់នៅ ។

ដានី ៖ គាត់នៅណាទៅ?

សារ៉ាត់ ៖ ស្រែអំបិល ។

ដានី ៖ ស្រែអំបិល ម្តុំណាទៅ?

សារ៉ាត់ ៖ ម្តុំយើង នៅផ្លូវអាផ្លូវយើងបែកពីនែកដើងគោមកលិចនេះ តាមផ្លូវនឹង ។

ដានី ៖ ម្តុំផ្លូវបែក?

សារ៉ាត់ ៖ មកស្រែអំបិលមក ប៉ុនតាមផ្លូវមកស្រែអំបិល មិនមែនជាប់ផ្លូវលេខ៤ទេ ឆ្ងង ។

ដានី ៖ ប៉ុនតែផ្លូវបត់ចូល?

សារ៉ាត់ ៖ ចូលមកក្នុងស្រុកស្រែអំបិល ។

ដានី ៖ ស្រុកស្រែអំបិល ម្តុំដើមគោ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ជិះទៅរកគាត់ បើទៅរកម្តុំនឹង សួរគេថាម៉េចទៅ?

សារ៉ាត់ ៖ សួរគេថាឈ្មោះនួន អតីតប្រធាននាវាការពារនៅកំពង់សោម ។

ដានី ៖ ប្រពន្ធគាត់ពូស្គាល់ដែរ?

សារ៉ាត់ ៖ ឈ្មោះញ៉ៅ ។

ដានី ៖ ទៅសួរគេម្តុំដើមគោ គេស្គាល់អត់?

សារ៉ាត់ ៖ ប្រហែលជាអត់ ។ ទាល់តែសួរម្តុំណាមើលទៅ សួរម្តុំផ្លូវបែកនេះ ចូល ៗ មកក្នុងមក
យើងចូលអាផ្លូវបែក ស្រែអំបិល ប្អូនធ្លាប់ធ្វើដំណើរមក ។

ដានី ៖ បាទ! ដូចថាផ្លូវនេះផ្លូវកំពង់សោម ផ្លូវនេះជាតិលេខ៤?

សារ៉ាត់ ៖ ដើមគោអញ្ចឹង ផ្លូវបំបែកល ចេញពីដើមគោមកលិចចូលមក ។

ដានី ៖ នេះផ្លូវកំពង់សោម ៗ នេះដល់ផ្លូវបែកស្រែអំបិល កោះកុង ដល់ពេលយើងសួរម្តុំណា?

សារ៉ាត់ ៖ សួរអ្នកចូលមកនេះ សួរចូលនេះចាំសួរ ។

ដានី ៖ ចូលមកដល់?

សារ៉ាត់ ៖ ចូលដល់ផ្លូវស្រែអំបិលចាំសួរ ។

ដានី ៖ ចូលដល់ផ្លូវស្រែអំបិលចូលដល់ខាង?

សារ៉ាត់ ៖ ម្តុំភ្នំរៀងបទបែនបន្តិច មានចំការម្រេច ចំការអីនឹងចាំសួរកន្លែងនឹង ។

ដានី ៖ សួរកន្លែងចំការម្រេច សួរនឹងគេអាចគេស្គាល់ ប៉ុន្តែគាត់មកនៅនឹងយូរដែរ?

សារ៉ាត់ ៖ នឹងហើយ សួរមនុស្សម្នាក់ទៀតក៏គេមានឈ្មោះដែលនៅនឹង ឈ្មោះដែល បូ ។

ដានី ៖ បូនឹងគាត់នៅក្រោមនាវាណាដែរ?

សារ៉ាត់ ៖ គាត់នៅនាវាបណ្តែត ។

ដានី ៖ បូ ប្រពន្ធគាត់ឈ្មោះអីដែរ?

សារ៉ាត់ ៖ ឈ្មោះធឿន ។

ដានី ៖ មិនដឹងភូមិគាត់ភូមិអី?

សារ៉ាត់ ៖ ខ្ញុំអត់ចាំបានទេ ។

ដានី ៖ យុំម៉ុំយុំ ស្គាល់យុំ?

សារ៉ាត់ ៖ មិនដឹងជាយុំដើងគោ អ៊ីត្រង់ណា ខ្ញុំវាខាងទៅយូរ ហើយម៉ុំនឹងខ្ញុំចេះទៅហួស មកហួសបើបាន។

ដានី ៖ ធឿនហើយ បូ ហើយនឹងឈ្មោះនួន នឹងគាត់នៅផ្ទះជិតគ្នាទេ?

សារ៉ាត់ ៖ អាចសួររកមួយហើយ ឃើញ២ហើយ ហើយឃើញ២អាចទៅដល់ឃើញ៣ មានអ្នកខ្លះនៅនឹងទៀត៣ ៤ឬ៥ទៀតក៏មិនដឹង។

ដានី ៖ បណ្ដែត ប្រធាននាវាបណ្ដែត ហើយបូ?

សារ៉ាត់ ៖ បាទ! ប្រធានវរសេនាធំ ក្នុងក្រុមវ័ណ្ឌបណ្ដែតនេះមួយវរសេនាធំ ការពារមួយវរសេនាធំដល់ពេលនឹងយើងរៀបហើយ។

ដានី ៖ វ.ធំ បណ្ដែត ទៅដល់កន្លែងម៉ុំ ចម្ការម្រេចនឹងសួរទៅអាចគិតមើល បើឃើញក្នុងចំណោម២នឹងអាចឃើញហើយ?

សារ៉ាត់ ៖ បាទ!ឃើញ។

ដានី ៖ ម៉ុំចម្ការម្រេច បើសួរកន្លែងម៉ុំចម្ការម្រេចគេអត់ស្គាល់ យើងអាចទៅសួរម៉ុំណាទៀត?

សារ៉ាត់ ៖ ហួសនឹងបន្តិចទៅ។

ដានី ៖ ហួសទៅខាងកោះកុង?

សារ៉ាត់ ៖ ឬយើងកិលមកក្រោយបន្តិចទៅ។

ដានី ៖ កិលមកខាង?

សារ៉ាត់ ៖ ហើយសួរចេះ ដើម្បីយើងដឹងថាមនុស្សនឹងយើងងាយរកណា អតីតកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលធ្លាប់ធ្វើសកម្មភាពតំបន់នឹង បូ ហើយនឹង នួននឹង។ បើសួរអាប្រវត្តិមុនគេអត់ស្គាល់ទេ អាប្រវត្តិខ្ញុំនិយាយណា។

ដានី ៖ នៅខាងកំពង់សោម។

សារ៉ាត់ ៖ បើយើងសួរថាអតីតកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលធ្លាប់ប្រចាំការធ្វើសកម្មភាពនៅចំណុច ពេជ្រនិលមកស្រែអំបិល។

ដានី ៖ អានឹងក្រោយ៧៩?

សារ៉ាត់ ៖ បាទ!៧៩ហើយនឹង យើងទៅធ្វើសកម្មភាពនៅនឹង។ ហើយសព្វថ្ងៃ គាត់មានទឹកមានដីនៅដូចយើងនេះដែរ កន្លែងគឺនៅកន្លែងនឹង។

ដានី ៖ សកម្មភាពពេជ្រនិល?

សារ៉ាត់ ៈ ស្រែអំបិល ជាទឹកដីរបស់គាត់ធ្វើសកម្មភាពហើយ ។

ដានី ៈ អញ្ចឹងនាវា១៧-៤ ១៧-៥នឹង ហើយអានឹងគាត់ប្រចាំនៅកោះ?

សារ៉ាត់ ៈ កោះតាង ។

ដានី ៈ ២នាវានឹងបានន័យថាវ៉ាដាបាញ់មកខាងលិច?

សារ៉ាត់ ៈ បាញ់ទៅទិសខាងលិច ក្នុងនឹងមានសហការជាមួយវ៉ាដាកោះតាងផង ។ កោះតាងក៏មានវ៉ាដាដែរ ។

ដានី ៈ មានវ៉ាដានៅលើកោះតាងទៀត?

សារ៉ាត់ ៈ បាទ!

ដានី ៈ ចុះវ៉ាដាមួយ វ៉ាដានៅបូលគោ ហើយនឹងវ៉ាដានៅកោះតាងនឹង វ៉ាដានឹងគេមានអង្គភាពគេម៉េចដែរអានឹង?

សារ៉ាត់ ៈ ជាអង្គភាពប្រព័ន្ធសហការកិច្ចបញ្ជាការរបស់កងពល១៦៤ខាងជើងទឹក ខាងផ្នែកផ្ទៃទឹកនិយាយរួម ។

ដានី ៈ ប៉ុន្តែដូចថាវ៉ាដានីមួយៗនឹងនៅក្នុងអង្គភាព នៅក្នុងវរសេនា ក្នុងស៊ីដែរអានឹង?

សារ៉ាត់ ៈ អានឹងវាជាផ្នែកមួយណា វ៉ាដាមួយវាមានប្រធានមួយគ្រប់គ្រងរបស់វាមួយវ៉ាដាមួយមានប្រធានមួយគ្រប់គ្រងមួយ ។

ដានី ៈ ពូស្គាល់ថានៅបូលគោ ប្រធានវ៉ាដាគេឈ្មោះអីទៅ?

សារ៉ាត់ ៈ នែក! ឈ្មោះអ៊ីវ៉ន ប៉ុនគាត់ស្លាប់ហើយ ប៉ុននៅម្នាក់សព្វថ្ងៃនៅត្រែង ។

ដានី ៈ នៅត្រែឈ្មោះអីទៅ?

សារ៉ាត់ ៈ ឈ្មោះអ៊ុក ណង ។

ដានី ៈ អ៊ុក ណង?

សារ៉ាត់ ៈ គាត់បច្ចេកទេសវ៉ាដានៅបូលគោ ។ ហើយកងវិស្វកម្មនៅខាងកើតវត្តត្រែង ដែលមានរបងនាទីសព្វថ្ងៃជាកងទ័ពពាក់សក្តិ៥ ។

ដានី ៈ បូលគោសព្វថ្ងៃ គាត់សក្តិ៥?

សារ៉ាត់ ៈ វិស្វកម្មនៅជិតត្រែង ជាប់ត្រែង ខាងកើតឃុំត្រែងនឹងណា ។

ដានី ៈ នៅខាងកើត សួរគេនៅខាងកើតឃុំត្រែងនឹង?

សារ៉ាត់ ៈ ទៅឃើញហើយ ទៅឲ្យតែមើលក្រលេកមើលនៅខាងស្តាំដៃ គឺឃើញផ្លាក ចូលទៅសួរ ។

ដានី ៈ ខាងកើតភូមិត្រែង ផ្ទះគាត់នៅនឹងម៉ង ហើយគាត់?

សារ៉ាត់ ៖ ទីបញ្ចារការ ។

ដានី ៖ ពូខ្ញុំឃើញហើយ មានកន្លែងវិស្វកម្មនឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ គាត់ប្រធាននៅនឹង ហើយក៏គាត់?

សារ៉ាត់ ៖ គាត់ប្រធាន ។

ដានី ៖ គាត់ឈ្មោះអ៊ុក ណាង ប៉ុន្តែគាត់កាលជំនាន់នឹង គាត់មិនមែនប្រធានវ៉ាដាទេ?

សារ៉ាត់ ៖ គាត់ជាប្រធានផ្នែកមួយ ប្រធានគាត់ឈ្មោះវនទឹងស្លាប់ហើយ ប្រធានរួម គ្រប់គ្រងរួម ។

ដានី ៖ កោះតាង?

សារ៉ាត់ ៖ កោះតាង ភ្លេចប្រធានវ៉ាដាកោះតាង ទៅសួរអ៊ុក ណាង គាត់យល់បានខាងវ៉ាដា ខ្ញុំភ្លេចនិយាយរួមភ្លេច ។

ដានី ៖ ភ្លេចតែម្តងកោះតាង?

សារ៉ាត់ ៖ បាទ!

ដានី ៖ អត់ចាំអ្នកដែលមាន?

សារ៉ាត់ ៖ នឹងហើយចាំអ្នកបច្ចេកទេសនៅគ្រប់គ្រងនៅនឹង ខ្ញុំភ្លេចឈ្មោះគាត់ ។

ដានី ៖ ប៉ុន្តែគាត់នៅដែរអត់ មើលទៅ?

សារ៉ាត់ ៖ មិនដឹងជាស្លាប់ឬរស់ បាត់មកដល់ថ្ងៃនេះ ។

ដានី ៖ ចាំទៅសួរ?

សារ៉ាត់ ៖ អ៊ុក ណាង ជាសាខារបស់គាត់ ។

ដានី ៖ អញ្ចឹងខាងវ៉ាដានឹង ប្រហែលជាគេមានវរអើផ្សេងដាច់ពីវរដែល?

សារ៉ាត់ ៖ ដាច់ៗក្រុម ដូចថានោះជាក្បាលសំណាញ់មួយៗ ខុសគ្នាណាំ វរសេនាធំការពារក៏ក្បាលសំណាញ់មួយ វរសេនាធំបណ្តែតក៏ក្បាលសំណាញ់មួយ វរសេនាធំវ៉ាដាក៏ក្បាលសំណាញ់មួយកោះក៏ក្បាលសំណាញ់មួយ ។

ដានី ៖ តែគ្រប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល?

សារ៉ាត់ ៖ កងពលរួម ១៦៤ ។

ដានី ៖ បើតាមពូមានប្រសាសន៍មិញ អញ្ចឹងមានវរសេនាធំច្រើន?

សារ៉ាត់ ៖ ច្រើននៅក្នុងចំណុះកងពល១៦៤កម្លាំងជាងម៉ឺន ទាំងប្រុសទាំងស្រី គិតទាំងកូននៅក្នុងបន្ទុកគ្រួសារទៀត ។

ដានី ៖ អញ្ចឹងដូចថាគាមដែលពូមានប្រសាសន៍មិញ មានកាប៉ាល់១៧-?

សាវ៉ាត់ ៖ នៅតែ២ទៀតទេមិនទាន់មានឈ្មោះណា នៅតែ១៧-៧ៗនឹង ។

ដានី ៖ ឈ្មោះសឿនហើយ?

សាវ៉ាត់ ៖ ឈ្មោះសឿន ។

ដានី ៖ សឿននឹងគាត់នៅដែរអត់?

សាវ៉ាត់ ៖ ស្លាប់ហើយ ស្លាប់ពេៗលវាយដើងទឹកនឹង ។

ដានី ៖ ១៧-៦ ឈ្មោះខន ស្លាប់ដែរ?

សាវ៉ាត់ ៖ មើល មានអ្នកណាម្នាក់ទៀតភ្លេចឈ្មោះហើយ ។

ដានី ៖ ១៧-៦ឈ្មោះសេង ១៧-៥ឈ្មោះខន ស្លាប់ ១៧-៤ឈ្មោះនួនថានៅខាងស្រែអំបិល ១៧-៨ឈ្មោះរ៉ន,១៧-៩ឈ្មោះហេន ចុះ១៧-១ ១៧-២ អត់មានទេ ១៧-៣អី?

សាវ៉ាត់ ៖ ១៧-៧ឈ្មោះសឿនស្លាប់ ១៧-១ម៉ាន សេង១៧-៦ ។

ដានី ៖ ១៧-៦?

សាវ៉ាត់ ៖ ក្នុងនឹងខ្ញុំអាចច្រឡំឈ្មោះខ្លះ បើមានការលើសលួស ក្នុង១០នាវានឹង វាអាចខ្ញុំច្រឡំមួយ ឬ២ មិនមែនជាប្រធាននាវាដោយច្រឡំឈ្មោះ មិនដឹងអ្នកណាមួយនៅ១៧-១០ អឺ! ១៧-៦ទេ ដូចឥឡូវបានត្រឡប់មកវិញ បានខ្ញុំនឹកឃើញថា បងនួននេះ គាត់មិនមែននៅ ១០៤ទេ ។

ដានី ៖ មិនមែននៅ១៧-៤ទេ?

សាវ៉ាត់ ៖ នឹងហើយ គាត់នៅ១៧-៣វិញ បានខ្ញុំចាំវិញ ក្រលេកមក ។

ដានី ៖ ១៧-៣នឹងនៅខាងណាទៅ?

សាវ៉ាត់ ៖ អានឹងនៅកោះតាងដែរ ។

ដានី ៖ ចុះ១៧-៤នៅកោះណា?

សាវ៉ាត់ ៖ ១៧-៤នៅកោះរ៉ុង ប្រចាំការណ៍កោះរ៉ុង និងអូរឈើទាល ។

ដានី ៖ ពីណាគេកាន់ ៤?

សាវ៉ាត់ ៖ ៤ រ៉ននឹង រ៉នវិញ ។

ដានី ៖ ១៧-៤ឈ្មោះរ៉ន កោះរ៉ុង អូរឈើទាល ។ ១៧-៥?

សាវ៉ាត់ ៖ ១៧-៥ខន ។

ដានី ៖ ១៧-៦?

សាវ៉ាត់ ៖ ១៧-៦ សេង ។

ដានី ៖ ១៧-៧ ឈ្មោះសឿន?

សាវ៉ាត់ ៖ ឈ្មោះសឿន ស្លាប់ហើយ ។

ដានី ៖ ១៧-៨ពីណាគេ?

សាវ៉ាត់ ៖ ១៧-៨ បាត់មួយហើយអៀ ។

ដានី ៖ ១៧-៨ឈ្មោះអៀ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ១៧-៨នឹង គាត់នៅកន្លែងណាវិញ?

សាវ៉ាត់ ៖ នៅអូរឈើទាលជាមួយគ្នា ចល័តណាពីកំពង់ផែនឹង គឺជាចល័តចេញចូល ផ្នែកនៅខាង ។

ដានី ៖ រ៉ុងអូរឈើទាល ។ ១៧-៩នៅខាងណា?

សាវ៉ាត់ ៖ ១៧-៩ ក៏នៅនឹងដែរ ប៉ុនមានប្រធាន ។

ដានី ៖ ប្រធានឈ្មោះហេន អញ្ចឹងហ៎?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ១៧-១០ ពូនៅខាង?

សាវ៉ាត់ ៖ មុខសញ្ញាតូច ។

ដានី ៖ នៅខាងជិតកោះថ្មី កោះសេះ កោះថ្មី នៅខាងជិតកោះតាគៀវ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ចុះ១៧-២ ១៧-៣ អឺ!១៧-១ ១៧-២?

សាវ៉ាត់ ៖ ១៧-១ ១៧-២ ប្រចាំនៅក្នុងបុកកោះរ៉ុងនិងអូរឈើទាល ។

ដានី ៖ ១៧-១ពីណាគេប្រធាន?

សាវ៉ាត់ ៖ ភ្លេចបាត់ហើយ ។

ដានី ៖ អញ្ចឹង១៧-២ស្គាល់ដែរ?

សាវ៉ាត់ ៖ អឺ!សិត ប៉ុនក្រោយមកជ្រៀនៗទៅគ្រប់គ្រង សិតគាត់ស្លាប់ៗពេលប្រយុទ្ធ ភ្លេចមួយចាំ
មិនអស់ ភ្លេចមួយខ្ញុំភ្លេចមួយបាត់ ។

ដានី ៖ អញ្ចឹងខាងកោះតាងមានតែឈ្មោះ មានតែ១៧-៣?

សាវ៉ាត់ ៖ បាទ!១៧-៣ និង ១៧-៥ ។

ដានី ៖ ១៧-៥ ច្បាស់ម៉ង ពូច្បាស់ម៉ង នួននឹង ដឹងថាគាត់នៅកោះតាងហើយ បើខាងកោះរ៉ុង មានឈ្មោះរ៉ន មានឈ្មោះអៀ ឈ្មោះហេននឹង គាត់ខាង១៧-៤ ១៧-៩ ១៧-៨ នឹងដឹងថាច្បាស់ថានៅខាងកោះរ៉ុង អូរឈើទាល បើខាងកោះថ្មី កោះសេះរបស់ពូមានខាង ១៧-១០?

សារ៉ាត់ ៖ ១៧-៧មួយទៀត ។

ដានី ៖ ១៧-៧ឈ្មោះសឿន តែ២នឹងទេ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ក្រៅពីនឹងនៅខាងអូរឈើទាល នៅខាងអីធម្មតា?

សារ៉ាត់ ៖ ចល័តៗ ។

ដានី ៖ បើ១៧-៣ របស់នួន ១៧-៥របស់ខននឹង ដឹងប្រចាំនៅកោះតាង?

សារ៉ាត់ ៖ បាទ!

ដានី ៖ រហូតគាត់ៗនៅប្រចាំគាត់រហូតដល់៧៩ម៉ង?

សារ៉ាត់ ៖ ថ្ងៃ ដល់ថ្ងៃ៧មករំដោះ មកទាំងរហេតរហប ។

ដានី ៖ ដល់ថ្ងៃ១៧មកវាបានចេញ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ប៉ុន្តែឈ្មោះខននឹង គាត់ស្លាប់ក្រោយនឹងទេ?

សារ៉ាត់ ៖ ស្លាប់ក្រោយ ។

ដានី ៖ ចំពោះអញ្ចឹងខ្ញុំបែបមករបស់ពូវិញ មកនៅកន្លែងការពារ ពេលថ្ងៃយើងត្រឡប់មកខាងរាម ពេលយប់យើងទៅការពារ យើងបើករ៉ាដានៅចាំ ។ ដល់ពេលយប់នឹង ពេលដែលការពារនឹង ពូដូចថាធ្លាប់ជួបប្រទះព្រឹត្តិការណ៍អី ឃើញសកម្មភាពស្អីខ្លះដែរ?

សារ៉ាត់ ៖ ពេលដែលយើងទៅការពារអីនឹង មិនឃើញអីទេ ពេលបើករ៉ាដាទៅ ដួនកាលយើងមើលតំបន់សមុទ្រ នៅក្នុងតំបន់សមុទ្រនឹង វាមានតំបន់ខ្លះប្រជាជនចេញនេសាទហើយប្រជាជនក្រុមវ័ណ្ឌនេសាទត្រឹមម៉ាយើងមានតំបន់យើង ។ ហើយប្រជាជនខាងយួនគេនេសាទត្រឹមម៉ាវាមានតំបន់វា ។ ឯសកម្មភាពណាដែលប្លែកយើងត្រូវតែទៅពិនិត្យ និងអង្កេត ។

ដានី ៖ ពេលដែលឃើញសកម្មភាពណាប្លែកអញ្ចឹង កាប៉ាល់យើងបើកទៅមើលម៉ង?

សារ៉ាត់ ៖ បាទ! ព្រឹត្តិការណ៍ដែលប្លែកៗដែល៣ថ្ងៃទេ គឺថ្ងៃ៥ ថ្ងៃ៦ និងថ្ងៃ៧ ។

ដានី ៖ ថ្ងៃ៥ ថ្ងៃ៦ ថ្ងៃ៧ មានព្រឹត្តិការណ៍អីទៅ?

សារ៉ាត់ ៖ ព្រឹត្តិការណ៍គឺថាសកម្មភាពច្របូកច្របល់ រវាងទូកនេសាទនិងទូកវាយលុកចូលមកដល់តែម្តង ។

ដានី ៖ ខាងណានឹង?

សារ៉ាត់ ៖ ខាងយួន ។

ដានី ៖ ថ្ងៃ៥ ថ្ងៃ៦ ថ្ងៃ៧នឹង ខែណាឆ្នាំណា?

សារ៉ាត់ ៖ ឆ្នាំ៧៩ នឹងហើយ៧៩ ។

ដានី ៖ អាពេលបែក ពេលដែលគេវាយលុក៧៩ ៧មករានឹង?

សារ៉ាត់ ៖ បាទ!គឺថាខ្ញុំបើករ៉ាដាទៅឃើញគ្រប់ប្រភេទតែម្តង ធំ តូច និងតូចបំផុត ធម្មតាយើងមើលក្នុងរ៉ាដាវាឃើញដូចថាមានខ្លះប៉ុនគ្រាប់ស្រូវ ខ្លះធំជាងគ្រាប់ស្រូវ ទំហំអីប្រហាក់ប្រហែលគ្រាប់ស្រូវ ហើយរហូតដល់តូចយើងមើលតូចបំផុត ។

ដានី ៖ ពេលដែលពូឃើញអញ្ចឹង យ៉ាងម៉េចទៅពេលនឹង?

សារ៉ាត់ ៖ ពេលនឹងខាង មានបងហ៊ិននឹងគាត់បញ្ជាឲ្យខ្ញុំទៅសង្កេត ហើយដោយមានការត្រៀមប្រយុទ្ធដឹងថាសភាពការណ៍អត់ស្រួលហើយ ។ ហើយពេលនោះ ខ្ញុំទៅជួបការប្រយុទ្ធមែនរវាងកាប៉ាល់យោធានិងយោធា ។

ដានី ៖ ប្រយុទ្ធយ៉ាងម៉េចខ្លះទៅកាលនឹង?

សារ៉ាត់ ៖ វាយដោយជើងទឹកនិងជើងទឹកប្រយុទ្ធ ប៉ុនថ្ងៃ៦ហើយទេ ។

ដានី ៖ ចុះពីមុននឹង?

សារ៉ាត់ ៖ ថ្ងៃ ពីមុននឹងមិនឃើញអីប្លែកទេ ជាធម្មតាៗ ។

ដានី ៖ ដូចថាចន្លោះចាប់ពីពូការពារពីចុងឆ្នាំ៧៦ រហូតដល់៧៩នឹង ដូចថាមានពេលនឹងយើងបើករ៉ាដាទៅមានទូកនេសាទ ពួកអីរត់ចូលមកទេ?

សារ៉ាត់ ៖ មានចេះដែរ មានព្រឹត្តិការណ៍របៀបប្រភេទដូចនាវាលឿនរបស់មីន វាមកឆាបខាងត្បូងកោះតាគៀវអីអញ្ចឹងទៅ ដោយប្រើរ៉ាដាចាប់បានម៉ាត្រាច ក៏បាត់ទៅ ។

ដានី ៖ ប៉ុនដល់ពេលមានអញ្ចឹងយើងធ្វើម៉េចទៅ មានតាមគេ?

សារ៉ាត់ ៖ យើងៗ តាមក៏តាមមិនទាន់ដែរ គ្រាន់តែ ។

**កាសែតទី៧ ផ្នែក«ខ»**

សារ៉ាត់ ៖ មានទូកមានអីមកអែបនឹងទៅ ហើយដល់ពេលទៅមើលទូកនឹងទៅវាជាជនជាតិយួន ។

ដានី ៖ ដល់ពេលយើងឃើញទូក យើងទៅមើលឃើញជនជាតិយួន ហើយអញ្ចឹងម៉េច?

សារ៉ាត់ ៖ យើងចាប់គេមក ។

ដានី ៖ ចាប់គេមកនៅណា?

សារ៉ាត់ ៖ ហើយប្រភេទជនជាតិយួននឹងខ្លះគេភៀសខ្លួន ហើយខ្លះគេជាយុវជន ជាឯកសណ្ឋានកំម៉ុង ដូរម៉ង់ ។

ដានី ៖ នឹងជ្វាកជាទាហានរបស់យួន?

សារ៉ាត់ ៖ បាទ!ជាទាហានរបស់យួន ។

ដានី ៖ អញ្ចឹងឧបមាថាយើងចាប់ យើងឃើញទូកអញ្ចឹង យើងចាប់ដូចថាពួកទូកដែលយើងចូលមកកន្លែងកោះយើងអីអញ្ចឹង យើងចាប់យកទៅណា?

សារ៉ាត់ ៖ យើងចាប់យកមកសួរៗពត៌មាន បើថាគេអ្នកភៀសខ្លួន យើងលែងទៅ ហើយបើគេជាប្រភេទគេមិននិយាយ មិនធ្វើដឹងមិនធ្វើព្រជាមួយយើងៗបញ្ជូនមកកន្លែងសន្តិសុខ ។

ដានី ៖ កន្លែងសន្តិសុខនៅណាទៅ?

សារ៉ាត់ ៖ ទៅភ្នំពេញ ។

ដានី ៖ សន្តិសុខភ្នំពេញ?

សារ៉ាត់ ៖ បាទ!

ដានី ៖ កន្លែងស្អីគេ បានសន្តិសុខភ្នំពេញ?

សារ៉ាត់ ៖ ស-២១ ។

ដានី ៖ កាលនឹងពេលដែលអ្នកណា ដូចថាយើងសង្ស័យដែលយើងសួរទៅយើងសង្ស័យយើងអត់ដូចថា?

សារ៉ាត់ ៖ គេអត់ដឹងអ្នកណាជាអ្នកណាទេ ហើយគេមិននិយាយ ពេលខ្លះគេធ្វើជាឆ្កួតករនឹង ហើយនឹងធម្មតាមនុស្សឆ្កួតបើកកាណូត បើកទូកក្នុងសមុទ្របាន មិនអាចទេ ហើយមិនអាចនៅលើទូកនៅមួយមានមនុស្សឆ្កួត២ ៣នាក់ យើងអត់ដឹងទេ យើងទទួលស្គាល់មិនបានទេ អានឹងមិនអញ្ចឹង ។ ដូច្នេះ ត្រូវតែបញ្ជូនឲ្យអ្នកមានសមត្ថកិច្ច គេរាប់រង ។

ដានី ៖ អញ្ចឹងពេលដែលពូដូចថាពេលពូចាប់នឹង បញ្ជូនមកកន្លែងណាដែលដំបូង?

សារ៉ាត់ ៖ ទៅមកកងពលមក កងពលបញ្ជូនបន្ត ។

ដានី ៖ ចុះពូដែលឃើញអញ្ចឹង យើងថាសួរនាំទៅដូចអត់ដឹងនឹង ពួកណាគេ?

សារ៉ាត់ ៖ ជនជាតិយួន ។

ដានី ៖ សុទ្ធតែជនជាតិយួន?

សារ៉ាត់ ៖ បាទ!ជាយុវជន ។

ដានី ៖ សុទ្ធតែយុវជន?

សារ៉ាត់ ៖ បាទ!យុវជន ក្នុង២០ ២១ ។

ដានី ៖ ច្រើនដែលអត់ ពួកនៅនឹង?

សារ៉ាត់ ៖ ច្រើន ។

ដានី ៖ ច្រើន?

សារ៉ាត់ ៖ ច្រើនសឹងតែរាល់ខែ ។

ដានី ៖ ចាប់រាល់ខែ?

សារ៉ាត់ ៖ បាទ!ក្នុងរយៈពេល២ឆ្នាំ សឹងតែរាល់ខែម៉ង ចូលមកកោះតាង កោះវៃ ។

ដានី ៖ ពេលនឹង ពេលដល់ពេលចូលមកកោះតាង កោះវៃ យើងអ្នកការពារនឹងយើងចាប់យកមក កន្លែងកងពលម៉ង?

សារ៉ាត់ ៖ កន្លែង ពេលខ្លះយើងចាប់បាន ប៉ុនពេលខ្លះគេរត់រួចណា ។

ដានី ៖ ពេលដែលរត់នឹងយើងមានសិទ្ធិបាញ់?

សារ៉ាត់ ៖ ដេញៗ ។

ដានី ៖ ដេញនឹងយើងបាញ់ដែរអត់?

សារ៉ាត់ ៖ យើងនែក!បាញ់ក៏បាញ់មិនត្រូវវាឆ្ងាយ ដឹងបាញ់ធ្វើអី ភាគច្រើនអញ្ចឹង ។

ដានី ៖ ពិតដូចថាខាងកងពលគេបញ្ជាមក ដូចថាពេលដែលឃើញអញ្ចឹង ឧបមាថាអ្នកនឹងអញ្ចឹងយ៉ាងម៉េច យើងត្រូវបាញ់ពេលនឹង យ៉ាងម៉េចបានយើងត្រូវចាប់?

សារ៉ាត់ ៖ បាទ!

ដានី ៖ គេមានបញ្ជាយ៉ាងម៉េច?

សារ៉ាត់ ៖ បើថារត់យើងចាប់ យើងបាញ់ ប៉ុនបើគេមិនរត់យើងចាប់ ប៉ុនភាគច្រើនគេវិធីប្រយុទ្ធរបស់គេ ពេលនឹងគេច្រើនតែគេចមិនឲ្យយើងចាប់បានទេ ។

ដានី ៖ តាមមើល បើតាមពូប៉ាន់ស្មានមើល ពួកនឹងដែលមកនឹងគេមកក្នុងគោលបំណងអីទៅ?

សារ៉ាត់ ៖ ខ្ញុំមិនដឹងជាគោលបំណងអីដែរ ប៉ុនបើមើលលក្ខណៈជាអាហារហូបចុក ជារបស់ប្រើប្រាស់ក្នុងលក្ខណៈដែលមកស៊ើប ។

ដានី ៖ មកស៊ើប?

សារ៉ាត់ ៖ បាទ!មកស៊ើប ។

ដានី ៖ ពួកស៊ើបការណ៍?

សាវ៉ាត់ ៖ មកស៊ើប តើកោះនឹងមានមនុស្សហើយអត់ មានទាហានឬអត់ វាត្រូវការអញ្ចឹង ហើយដល់អ្នកដែលចាប់បាននឹង មិនមែនទៅចាប់ក្នុងទឹកទេ ចាប់ពេលកាណូតបុកគោកទឹកបាន យើងភ្ជង់យលបណ្ដោយ ។ ពួកនៅកោះអ្នកចាប់ ហើយបើថាយើងក្នុងទឹកហើយយើងប្រើនាវាយើងទៅចាប់គេរត់ គេមិនឲ្យយើងចាប់ទេ ។

ដានី ៖ អញ្ចឹងទាល់តែកាណូតនឹងមកបុកកោះនឹង បានគេភ្ជង់ចាប់?

សាវ៉ាត់ ៖ បានចាប់ម៉ង ។

ដានី ៖ ពួកនាវា ពួកពូនឹងអ្នកភ្ជង់ចាប់ដែរ?

សាវ៉ាត់ ៖ អត់ទេ ខ្ញុំអត់ទេ ខាងនាវាអត់មានសិទ្ធិទេ អានឹងខាងដើងទឹក ប៉ុន្តែប្រយុទ្ធលើគោក មានភារកិច្ចការពារកោះ អ្នកចាប់ពួកនឹង ។

ដានី ៖ ចាប់ហើយប៉ុន្តែបញ្ជូនទៅតាមនាវារបស់ពូ?

សាវ៉ាត់ ៖ អត់ទេ តាមនាវាមិនចាំតែនាវាខាងខ្ញុំទេ មាននាវាណាដែលចាំបាច់ទៅមកនឹង គេចេញចូលក៏បញ្ជូន ជួនកាលបញ្ជូនតាមនាវាដឹកស្បៀងដឹកអីអញ្ចឹងមកនឹង ។

ដានី ៖ អញ្ចឹងតាំងពីពូចេញទៅល្បាតនឹង ចាប់បានរាល់ខែ?

សាវ៉ាត់ ៖ រាល់ខែ ។

ដានី ៖ ម៉ាខែប៉ុន្មាននាក់ទៅ?

សាវ៉ាត់ ៖ យ៉ាងអន់ក៏២ ៣នាក់ដែរ ។

ដានី ៖ ចាប់ពីល្បាតនឹងតាំងពីចុង៧៦មក យើងចាប់បានរហូត?

សាវ៉ាត់ ៖ បាទ!

ដានី ៖ នឹងច្រើនតែពួកយួនម៉ង?

សាវ៉ាត់ ៖ បាទ!ពួកយួន ។

ដានី ៖ តើមានពួកណាផ្សេងទៀតទេ?

សាវ៉ាត់ ៖ អត់ទេ លែងមានទេ ។

ដានី ៖ ប៉ុនមានទេ មានពួកផ្សេងទៀតដែរអត់?

សាវ៉ាត់ ៖ មានខ្លះ តែយើងស្គាល់លក្ខណៈ ដូចថាជនជាតិបរទេសដែលមកអញ្ចឹង យើងស្គាល់ថានេះជាយួន នេះជាខ្មែរ ជាឥណ្ឌាអញ្ចឹង ព្រោះពួកនឹងច្រើនដើរចន្លោះ ។ ប៉ុន្តែ យើងចាប់ពួក

នឹង មិនមែនគេបុកកោះដូចយើងទេ អត់ដូចយួនទេ ខុសគ្នា ។ គេច្រើនបើកនៅសមុទ្រ ដែលជិតកោះយើងអញ្ចឹងទៅ ។

ដានី ៖ មានដែលអញ្ចឹង អានឹងពួក?

សាវ៉ាត់ ៖ មានៗ ។

ដានី ៖ មានពួកស្បែកសដែរអត់?

សាវ៉ាត់ ៖ ខ្ញុំចាំមិនបាន ប៉ុនប្រហែល ដូចមិនដែលមានទេ មានពួកខ្មឹង ពួកអីមាន ។

ដានី ៖ ខ្មឹងនឹងវៀនម៉េចទៅ?

សាវ៉ាត់ ៖ ខ្មឹងនឹងឥណ្ឌូនីងណា ។

ដានី ៖ ពួកឥណ្ឌូនីង?

សាវ៉ាត់ ៖ បាទ!

ដានី ៖ បើកយ៉ាងម៉េច អានឹង?

សាវ៉ាត់ ៖ វាបើករបៀបទូកទេសចរណ៍ៗ ក្តោងវាមកអញ្ចឹងទៅ ដល់ពេលព្យុះខ្លាំងនឹងវារត់មករកកោះ ធម្មតាប្រទេសគេសន្តិភពមិនអញ្ចឹង ឯប្រទេសយើងវាសន្តិភាពដែរតែសន្តិភាពក្នុងលក្ខណៈ សង្គ្រាមព្រំដែន ។

ដានី ៖ កាលពីជំនាន់នឹង ពូមានដែលឃើញគេចាប់បានទូកចេះអត់?

សាវ៉ាត់ ៖ អត់ ដូចអត់ទាក់ទិនទេ ខ្ញុំអត់ដឹងទេ ក្រែងលរផ្នែកណាគេចាប់ហើយគេ ព្រោះធម្មតាគេមិន សូវនិយាយ ។

ដានី ៖ នេះទូករបៀបទេសចណ៍ដែលតើពូ?

សាវ៉ាត់ ៖ បាទ!នឹងហើយ ទូកទេសចរណ៍ បច្ចុប្បន្នវាប្រើ អានេះក្តោងហើយនេះ ក្តោងគេទម្លាក់ ។

ដានី ៖ ប៉ុន្តែពូឃើញ ធ្លាប់ឃើញគេចាប់ទូកប្រភេទនឹងដែរ?

សាវ៉ាត់ ៖ អត់ទេ អត់ដែលជួបទេ ព្រោះកន្លែងនៅវាខុសគ្នា ។

គី ៖ ចុះពូនិយាយថាទូកថាចាប់មើលថាពួកខ្មឹងអីគេចុះ បើកមកចតនៅលើកោះយ៉ាងម៉េច?

សាវ៉ាត់ ៖ អានឹងគេចាប់ពួកអា គាត់ជិះអាកាណូតធម្មតា អាកាណូតយើង៣៧សេសអីនឹង ដូចថា ចេញអាទៀងអីអញ្ចឹងមកសំដៅត្រាចថៃអញ្ចឹងទៅណា គេអត់ចូលខាងយើងទេណា គេជិះ ខាងត្បូងប៉ូឡូវៃអញ្ចឹង មើលឃើញទូកតូចទឹកៗ ដល់ឃើញព្យុះ ដូចខែនឹងព្យុះខ្លាំង គេរត់ មករកកោះហើយ ។

ដានី ៖ ដល់ពេលរត់មករកកោះមកជួបយើង?

សាវ៉ាត់ ៖ បាទ!មកជួបយើង ។

ដានី ៖ ជួបយើងៗមានឃាត់គេ ហើយឲ្យបញ្ជូនមកកន្លែងកងពលដែរអត់?

សាវ៉ាត់ ៖ មាន ប៉ុនយើងខ្ញុំ ។

ដានី ៖ ពូមានចាំអត់ដូចថា គេមកចាប់បញ្ជូនមកឆ្នាំ?

សាវ៉ាត់ ៖ ក្នុងចន្លោះឆ្នាំ៧៦ ៧៧ នឹងមាន ក្នុងសភាពការណ៍កម្ពុជាមិនទាន់នឹងនរ ។ ក្រោយសកម្មភាពនឹង វាច្រើនភាគច្រើនក្រោយម៉ាយ៉េហ្គុស កាប៉ាល់ម៉ាយ៉េហ្គុសចូលមក ។ ៧៥ភ្លាម មិននាវាម៉ាយ៉េហ្គុសចូលមកៗ ទម្លាក់គ្រាប់បែកទម្លាក់អីនៅកំពង់ផែ នៅកន្លែងខ្ញុំនៅរាមកង កេងនឹង ទម្លាក់ ។ ក្រោយមកនឹងមាន បន្ទាប់នឹងមក ក្រោយមកតទៅទៀតខ្ញុំមិនដែលព្នទេ ។

ដានី ៖ ដល់ពេលក្រោកយៗមក ព្ញថាពេលដែល ដូចថាពួកនាវាដែលគេធ្វើដំណើរដូចពូមានប្រសាសន៍មិញ ថាពីអាទៀង ទៅខេត្តត្រាចណា ដូចដល់ពេលមានព្យុះអីអញ្ចឹង?

សាវ៉ាត់ ៖ គេគេចចូល ។

ដានី ៖ គេគេចចូលមកអញ្ចឹង យើងពេលដែលចូលមកកោះយើងៗបញ្ជូនមកកន្លែងកងពល?

សាវ៉ាត់ ៖ បាទ! ហើយយើងអត់ដឹងថាទិសដៅគេទៅណា ។

ដានី ៖ កាលដែលបញ្ជូនមកកងពលនឹងពួកនឹងជា?

សាវ៉ាត់ ៖ តាមការដែលខ្ញុំដឹង ខ្ញុំធ្លាប់ដឹងតែមួយទេ គឺថាជនជាតិខ្វឹងនឹង ខ្វឹងនឹងគឺខ្វឹងពិត ឬខ្វឹងអីទេ វាថាខ្វឹងៗ ។

ដានី ៖ ចេះនិយាយភាសាខ្មែរ?

សាវ៉ាត់ ៖ អត់ទេ វានិយាយតែភាសាវានឹង ។

ដានី ៖ ចុះម៉េចយើងស្តាប់បាន?

សាវ៉ាត់ ៖ យើងដឹង ប្រើពាក្យថាខ្វឹង យើងចាំបានវាខ្វឹង វាថាមែន ។

ដានី ៖ ប៉ុននិយាយកាលនោះនិយាយស្តាប់គ្នាអត់?

សាវ៉ាត់ ៖ អត់ទេ ។

ដានី ៖ ឆ្នាំណា?

សាវ៉ាត់ ៖ រ៉ុលៗ ដូចឥណ្ឌូនិយាយរាល់ថ្ងៃនឹង យើងស្តាប់អត់បាន ។

ដានី ៖ សម្បុរៗគាត់?

សាវ៉ាត់ ៖ សម្បុរខ្មៅៗពុកមាត់ ។

ដានី ៖ ជិះទូកអីអានឹង?

សារ៉ាត់ ៖ ជិះទូកធន់ខ្នារ២២០សេស ។

ដានី ៖ គ្នាប៉ុន្មាននាក់?

សារ៉ាត់ ៖ គាត់បើកតែ២នាក់ ។

ដានី ៖ ប្រុសទាំង២?

សារ៉ាត់ ៖ បាទ!ប្រុសមកពីទិសខាងលិច ។

ដានី ៖ បើកពីណាទៅណា?

សារ៉ាត់ ៖ ពីកើតទៅលិច ពីយួនទៅថៃ ។

ដានី ៖ កាលនឹងយើងចូលមកកោះណា យើងចាប់បាននៅកោះ?

សារ៉ាត់ ៖ ប៉ូឡូវៃ ។

ដានី ៖ យើងចាប់នៅកោះប៉ូឡូវៃ កាលនឹងពូបានជួបឃើញផ្ទាល់ម៉ង?

សារ៉ាត់ ៖ ពូអ្នក កាណូតពូអ្នក ចាប់បានហើយក៏?

ដានី ៖ ខ្ញុំអត់ទេ ខ្ញុំអត់ចាប់ទេ គេខាងកោះគេអ្នក ។

សារ៉ាត់ ៖ គេអ្នកខាងកោះគេអ្នកចាប់ ។

ដានី ៖ ហើយគេបញ្ជូនទៅណាទៅ?

សារ៉ាត់ ៖ គេបញ្ជូនមកកំពង់សោម ។

ដានី ៖ ឆ្នាំណានឹង?

សារ៉ាត់ ៖ ក្នុងឆ្នាំ៧៧ ។

ដានី ៖ ពូចាំខែដែរអត់?

សារ៉ាត់ ៖ អត់ទេ អត់ចាំ ខ្ញុំវានៅណា ។

ដានី ៖ ដូចថាពេលនឹង ដូចថាខែប្រាំង ហើយក៏ខែវស្សា ពេលដែលគេ?

សារ៉ាត់ ៖ ក្នុងរដូវប្រាំង មុនខ្យល់នារតី ។

ដានី ៖ មុនខ្យល់នារតី គេហៅខ្យល់អីទៅពីមុនៗខ្យល់នារតីនឹង?

សារ៉ាត់ ៖ មុនខ្យល់នារតីវាក្នុងចន្លោះ មើលយើងគិតទៅខ្យល់ឥសានៗវាមកពីខាងកើតនឹងខាងឥសាន ហើយខ្យល់នារតីចាប់ពីខែ៣មក អាចក្នុងចន្លោះខែ២នឹង ។

ដានី ៖ ចន្លោះខែ២ហេ៎?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចន្លោះខែ២ បានន័យថានៅក្នុងចន្លោះខ្យល់ទិសឥសាននៅឡើយ?

សារ៉ាត់ ៖ បាទ!ក្នុងចន្លោះចែករដូវ ។

ដានី ៖ បានន័យថាខ្យល់ពីមកសមុទ្រនឹង បកមកពីទិសឥសាន?

សារ៉ាត់ ៖ បាទ!នៅក្នុងចន្លោះ ។

ដានី ៖ ចាប់បានៗពេលស្មានណា ពេលយប់ហើយពេលថ្ងៃ?

សារ៉ាត់ ៖ ពេលថ្ងៃ ។

ដានី ៖ ពេលព្រឹកហើយក៏ល្ងាច?

សារ៉ាត់ ៖ ខ្ញុំ គេចាប់ខ្ញុំទៅដល់ម៉ោង២រសៀលហើយ គេចាប់ពីយប់តាមមើល ប៉ុនគេយកមកដាក់នៅដៃនគេបញ្ជូនមក ។

ដានី ៖ ពូជាប់នៅដៃ?

សារ៉ាត់ ៖ បាទ!

ដានី ៖ មិនមែនលជួបនៅកោះរ៉ុងទេ មិនមែនជួបនៅកោះប៉ូឡូវៃទេ?

សារ៉ាត់ ៖ ខ្ញុំជួបនៅកោះតាង ខ្ញុំធ្វើដំណើរទៅកោះតាង ។

ដានី ៖ ពូធ្លាប់ធ្វើដំណើរទៅកោះតាង?

សារ៉ាត់ ៖ បាទ!ទៅហាត់ហ៊ឹកហ៊ឺននាវា ធម្មតាការហាត់ហ៊ឹកហ៊ឺនយើងធ្វើផែនការ យើងត្រូវធ្វើដំណើរទៅកោះតាង យើងធ្វើផែនការមួយ បញ្ជូនមកកងពលៗសម្រេចថានាវាដឹកទៅហាត់ហ៊ឹកហ៊ឺននៅកោះតាង ដូច្នេះមកប៉ុន្មាន ត្រូវប្រេងប៉ុន្មានៗអីត្រៀមរបស់យើងណាហើយយើងចេញដំណើរមកវិញ ទៅហើយនឹងមកទេអានឹង ។

ដានី ៖ ពេលពូនេះ ពូនៅកំពុងហាត់ហ៊ឹកហ៊ឺននៅឡើយទេ?

សារ៉ាត់ ៖ បាទ!ហ៊ឹកហ៊ឺនផង ដាក់ស្តែងផង ។

ដានី ៖ កាលនឹងពូនៅរៀននៅឡើយ?

សារ៉ាត់ ៖ ធ្វើការងារផង បាទ! ។

ដានី ៖ បានន័យថារៀនចប់ហើយ ពូរៀនចប់?

សារ៉ាត់ ៖ ក្នុងពេលនឹងគេថាយើងសិក្សាបន្ថែមៗ បើកបរចេញចូល កាលណាយើងបើកបរនាវាជិតពេក កាលចាំចងចាំរបស់យើងក្នុងផែនទី យើងអត់ច្បាស់ ។ អញ្ចឹងដើម្បីយើងចងចាំបានយើងត្រូវគូរផែនទី ហ៊ឹកហ៊ឺនក្នុងខួរក្បាលយើងផង ដាក់ស្តែងផង បើអញ្ចឹងកាលចងចាំស្ដីពីកោះមួយទៅកោះមួយមានចំងាយប៉ុន្មានគីឡូម៉ែត្រ ហើយកន្លែងណាមានដុំថ្ម កន្លែងណា

មានអីយើងខស្សវាហ៍មើលហ៊ីកហ៊ឺនដែនទីទៅវាស្គាល់ ។ ដល់ស្គាល់កាលប្រើប្រាស់យើងអត់ចេះគ្រោះថ្នាក់ ។

ដានី : បានន័យថាពេលដែលយើងចេញរៀនចប់ហើយ ពេលយើងមកធ្វើការយើងនៅហ៊ីកហ៊ឺនបើកទៅកោះនេះកោះនោះ?

សាវ៉ាត់ : ដោយវិធីបើកបរផ្លូវជិតផ្លូវឆ្ងាយៗ តំបន់ខបស័គ្គច្ច ខ្សាច់អីនឹង ទឹករាកទឹកជ្រៅយើងត្រូវតែហ៊ីកហ៊ឺន ។

ដានី : ពេលពូហ៊ីកហ៊ឺននឹងពូឃើញដែល ដូចថាចាប់បានពួកខ្មែរ ២នាក់ ទាំងទូកទាំងអីគេយកមកអូរឈើទាលទាំងអស់នឹង?

សាវ៉ាត់ : ប្រហែលជាជូនបញ្ជូនមកដឹង ព្រោះខ្ញុំពេលនឹងខ្ញុំទៅដល់ហើយ ដឹងថាគេមានជនបរទេសដឹងទៅណា ចុះតួនាទីនឹងមិនមែនយើងទេណា កាលណាគេចាប់បានយើងអត់មាននាទីទេ យើងគ្រាន់ថាភារកិច្ចហ៊ីកហ៊ឺន យើងដឹងថាឃើញម៉ង ។

ដានី : គ្រាន់តែឃើញ?

សាវ៉ាត់ : បាទ!គ្រាន់តែឃើញទេ គ្រាន់ដឹងថាអានឹងគេជាជនជាតិអី សួរគេអញ្ចឹង គ្រាន់យើងហូបបាយហូបទឹកអីជាមួយពួកយើងជាមួយនាវិកនឹង ហូបស្រួលបួលហើយ ។

ដានី : ចុះពេលពូឃើញនឹងឃើញនៅណា?

សាវ៉ាត់ : ឃើញនៅកំពង់ផែ នៅផែកោះតាងនឹង ។

ដានី : ឃើញនៅកំពង់ផែកោះតាងនឹង?

សាវ៉ាត់ : បាទ!

ដានី : ពេលពូឃើញនឹង ឃើញទិដ្ឋភាពអ្នកទោះនឹងយ៉ាងម៉េច?

សាវ៉ាត់ : គេអង្គុយធម្មតា ហូបបាយ ។

ដានី : គេហូបបាយដែរ?

សាវ៉ាត់ : បាទ!គេហូបបាយ ។

ដានី : ហូបបាយពេលស្មានណា?

សាវ៉ាត់ : ហូបបាន អាចគេហូបបាយយើងទៅនឹងម៉ោង២ហើយ ដូច្នេះគេកំពុងហូប មិនដឹងជាគេហូពបាយពេលណាយើងអត់ដឹងទេ ។

ដានី : ប៉ុន្តែថាសជនជាតិបរទេសដែលហូបបាយនេះ គេហូបបាយតែគ្នាគេ២នាក់?

សាវ៉ាត់ : បាទ!គ្នាគេ២នាក់ ហូបត្រីស្ងោរ ហូបត្រីអាំងយើងធ្វើឲ្យនឹង ។

ដានី ៖ មានហូបត្រីស្ងោរ ត្រីអាំងយើងដែរ?

សារ៉ាត់ ៖ បាទ!ហូប ។

ដានី ៖ ប៉ុន្តែយើងហូបដាច់ដោយឡែកពីគ្នា?

សារ៉ាត់ ៖ បាទ!ហូបដាច់ដោយឡែក ។

ដានី ៖ ហូបជាមួយទ័ពខាងយើងទេ?

សារ៉ាត់ ៖ អត់ទេ ។

ដានី ៖ ដល់ពេលអញ្ចឹងគេហូបនៅកំពង់ផែ ដល់ពេលចុះយើង ពូឃើញចំងាយប្រវែងប៉ុន្មាន?

សារ៉ាត់ ៖ ខ្ញុំនឹង ចុះយើងដើរលើផែ យើងចតផែនអញ្ចឹង គេក៏ឃើញយើងដែរ នាវាយើងទៅដល់គេ បរទេសនឹងគេឃើញថានាវាយើងទៅហើយ ។

ដានី ៖ ដល់ឃើញនៅកំពង់ផែនឹងហើយ ពូឃើញហើយយ៉ាងម៉េចទៀតទៅ ហូបបាយហើយរួចទៅយ៉ាងម៉េចទៀត?

សារ៉ាត់ ៖ ខ្ញុំៗគេហូបបាយ ខ្ញុំក៏ហូបៗហើយខ្ញុំចេញពីនាវាចរមកត្រឡប់មកដល់កន្លែងវិញ ។

ដានី ៖ ចុះ២នាក់នឹងយ៉ាងម៉េច?

សារ៉ាត់ ៖ ២នាក់នឹង មិនគេមកតាមក្រោយ ប្រហែលជាគេមកតាមក្រោយ អត់ដាក់មនុស្សលើខ្ញុំទេ ព្រោះភារកិច្ចខុសគ្នា ។

ដានី ៖ ប៉ុន្តែពូមកដល់កន្លែងអូរឈើទាល មានមកជួបនៅអូរឈើទាលដែរអត់?

សារ៉ាត់ ៖ អត់ គេមិនបញ្ចូលទេកន្លែងនឹង ព្រោះសម្រាប់កាប៉ាល់យោធាគេចត អត់ឃើញអ្នកណាមកជិត ។

ដានី ៖ ចុះគេចុះនៅណាវិញ?

សារ៉ាត់ ៖ មិនដឹងជាចូលរាម ឬចូលណាខ្ញុំអត់ដឹងដែរ ។

ដានី ៖ ចុះកាលជំនាន់នឹង កំពង់ផែមានប៉ុន្មានកន្លែង?

សារ៉ាត់ ៖ យើងប្រើប្រាស់មានកំពង់ផែយោធាមានតែអូរឈើទាល ហើយកំពង់សោមបានកំពង់ផែពាណិជ្ជកម្ម មានចិន យូហ្គូសាវី មានហុងគ្រី ប្រទេសណាដែលគេចេញចូលគេមានកំពង់ផែ ។

ដានី ៖ ប៉ុន្តែកំពង់ផែយោធាមានតែអូរឈើទាលទេ?

សារ៉ាត់ ៖ អូរឈើទាល កោះរ៉ុង តែ២កន្លែងនឹងទេគេចត ។

ដានី ៖ កន្លែងគេចត ចុះរាម?

សាវ៉ាត់ ៈ ចេញចូលធម្មតា ជួសជុលរប៉េះរប៉ោះ ។

ដានី ៈ កន្លែងជួសជុល?

សាវ៉ាត់ ៈ បាទ!

ដានី ៈ អញ្ចឹងកន្លែងរាមគេអត់ដែលមានប្រើប្រាស់អីយ៉ាងម៉េចទៅ?

សាវ៉ាត់ ៈ អានឹងកន្លែងរាមប្រើប្រាស់ជាកន្លែងផ្ទុកមីន អាមីនបាញ់គ្រាប់បណ្តែត ។

ដានី ៈ សម្រាប់ផ្ទុកមីន ផ្ទុននាវា?

សាវ៉ាត់ ៈ គេធ្វើដៃមួយសម្រាប់ឲ្យនាវាចេញចូល ទុកបញ្ចេញ បញ្ចូលគ្រាប់ ។

ដានី ៈ បើកន្លែងអូរឈើទាល អានឹងកន្លែង?

សាវ៉ាត់ ៈ កន្លែងនាវាការពារ ហើយនឹងនាវាប្រឆាំង ប៉ុននាវាប្រឆាំងមិនអាចចូលដៃអូរឈើទាលបានទេ ព្រោះវាដៃតូច ។ នាវាប្រឆាំងបោះយុថ្កា ហើយទូកជញ្ជូនស្បៀក ទូកកាណូតជញ្ជូនស្បៀងដាក់ទៅ ។ ហើយពេលរលកពេលខ្យល់មកទៅសំចតកោះវិញ ។

ដានី ៈ ចុះពូពេលអញ្ចឹង ជនជាតិបរទេស២នាក់នឹង ពូប្រហែល ប្រាកដថាគេបញ្ជូនមកកន្លែងកងពលហើយក៏យ៉ាងម៉េចបើតាមពូ?

សាវ៉ាត់ ៈ តាមខ្ញុំចាំពេលនោះបញ្ជូនមកកងពល។បញ្ជូនតទៅទៀត យ៉ាងម៉េចអានឹងខ្ញុំ ។

ដានី ៈ ដែលកងពល ប្រហែលបញ្ជូនតទៅទៀត ឬក៏យ៉ាងម៉េច?

សាវ៉ាត់ ៈ ខ្ញុំអត់ដឹង ។

ដានី ៈ ឬក៏ប្រលែង?

សាវ៉ាត់ ៈ បាទ!

ដានី ៈ ប៉ុន្តែបើតាមពូចាំ ដឹងថាបញ្ជូនមកកងពលហើយ?

សាវ៉ាត់ ៈ បាទ!

ដានី ៈ បញ្ជូនមកតាមកំពង់ដៃអូរឈើទាលនឹង?

សាវ៉ាត់ ៈ មិនមែនទេ ។

ដានី ៈ តាមណាទៅវិញទៅ?

សាវ៉ាត់ ៈ តាម មិនដឹងជាចូលរាម ឬចូលកំពង់សោម គេដឹកមិញនឹង ប្រហែលជារាមក៏មិនចូលដែលតាមមើល អាចគេចូលទៅកំពង់សោម ។

ដានី ៈ ចូលកំពង់សោម បានមកកងពលវិញ?

សាវ៉ាត់ ៈ បាទ! រួចចូលកំពង់សោម បើបញ្ជូនទៅភ្នំពេញ បញ្ជូនតតាមឡាន ។

ដានី ៖ ពួកភ្នំពេញគេមកទទួល ឬក៏យ៉ាងម៉េច?

សារ៉ាត់ ៖ ប្រហែលជាមកទទួល ។

ដានី ៖ ពូកាលជិនាន់នឹង ដែលដឹងថាពួកភ្នំពេញ ពួកខាងសន្តិសុខ ស-២១នឹង គេមកទទួល នឹងពូមានដែលបានជួបគ្នាអត់?

សារ៉ាត់ ៖ អត់ទេ ។

ដានី ៖ ចុះម៉េចបានពូដឹងថាពួកនឹងគេមកទទួលយក?

សារ៉ាត់ ៖ ព្រោះអដឹងថាគេមកទទួល មកពីការងារសន្តិសុខជាផ្លូវការ ឲ្យខ្ញុំជួបជាមួយខាងនឹង ខ្ញុំអត់តួនាទីអត់មានទេ ។

ដានី ៖ ប៉ុន្តែពូនឹងទេ?

សារ៉ាត់ ៖ ដឹង ។

ដានី ៖ ដឹងយ៉ាងម៉េចបានដឹង?

សារ៉ាត់ ៖ ដឹងតាមរយៈ ការស្គាល់គ្នា មិត្តភ័ក្តិៗ ។

ដានី ៖ មិត្តភ័ក្តណាទៅ?

សារ៉ាត់ ៖ មិត្តភ័ក្តដែលធ្លាប់នៅជាមួយគ្នានឹង ។

ដានី ៖ គេនិយាយថាម៉េច?

សារ៉ាត់ ៖ គេនិយាយថា បើមានរឿងតូចធំអី ផ្នែកសន្តិសុខរបស់ស-២១នឹង គេរាប់រងទទួលហើយ យើងដឹងតែប៉ុននឹងទេ ។ ហើយគេយកមនុស្សនឹងទៅណា យើងអត់ដឹង ។

ដានី ៖ បាទ! បានន័យថាយើងមិនមែនជាអ្នកបញ្ជូនទៅដល់ភ្នំពេញ គេមកទទួលគាត់?

សារ៉ាត់ ៖ អត់ទេ ខ្សែរបស់យើងអត់មានសិទ្ធិអីហៅស-២១ទេ ។

ដានី ៖ ប៉ុន្តែពូអត់ដែលមានស្គាល់ខាងសន្តិសុខអីមកពីស-២១ មិនដែលស្គាល់គ្នា និយាយគ្នាអី?

សារ៉ាត់ ៖ អត់ទេ សូម្បីតែបងឌុចនឹង ក៏ខ្ញុំទើបនឹងឮឈ្មោះពេលឥឡូវនេះដែរ ខ្ញុំមិនបានដឹងទេ ។

ដានី ៖ ប៉ុន្តែឧបមាថាការធ្វើការមកយើងនៅកាប៉ាល់អីអញ្ចឹង ដូចពូមានប្រសាសន៍លើកមុនថាដើរចូលបុកទូកមកកោះអីអញ្ចឹង ដឹកចូលមកអីអញ្ចឹង យើងបញ្ជូនមកកន្លែងកងពលៗហើយ យើងហៅខាងសន្តិសុខអីឲ្យមកយក?

សារ៉ាត់ ៖ បាទ!

ដានី ៖ ខាងកងពលអ្នកហៅ ឬក៏ខាងហើយ?

សារ៉ាត់ ៖ កងពល ។

ដានី ៖ ប៉ុនពេលនឹង ពូមានដែលបានជួបគ្នាដែរអត់ ដូចថាជួបពួកគេបើកឡានពីភ្នំពេញទៅ?

សារ៉ាត់ ៖ អត់ទេ ខ្ញុំអត់ទេ ។

ដានី ៖ ប៉ុនដឹងថា ដូចថាពូដែលបុកទូកពួកយួនមកធ្វើប្រុងមកស៊ើបការណ៍កន្លែងយើង ធ្វើអត់ដឹងអី នឹង ពួកនឹងដែលពេលមក ពេលដែលយើងបញ្ជូនមកដល់កន្លែងកងពលនឹង គេហៅមកយក ភ្លាម ឬក៏រយៈពេលប៉ុន្មានគេទុក?

សារ៉ាត់ ៖ គេអត់ទុកយូរទេ ត្រូវតែហៅ ។

ដានី ៖ គេទុកក្នុងរយៈពេលប៉ុន្មាន?

សារ៉ាត់ ៖ យ៉ាងខ្ពស់២៤ម៉ោង តាមចំងាយផ្លូវ ឧទាហរណ៍បាននៅកោះថ្មី គេបញ្ជូនមកកំពត ។

ដានី ៖ កោះថ្មីគេបញ្ជូនមកកំពតវិញ?

សារ៉ាត់ ៖ អឺ!ខ្សែខាងកំពតគេហៅទៅ បើថានៅយើងកោះតាងខាងអី អានឹងខាងកំពង់សោមហៅទៅ ហៅមកភ្នំពេញមក ហើយភ្នំពេញគេឡើងមក ។

ដានី ៖ ចុះឡានដែលគេមកយក ច្រើនឡានអីទៅ?

សារ៉ាត់ ៖ ថាខ្ញុំអត់ដែលឃើញទៀត ។

ដានី ៖ អត់ដែលឃើញឡាននឹង?

សារ៉ាត់ ៖ បាទ!អត់ មិនដឹងថាប្រភេទឡានបែបម៉េច ។

ដានី ៖ ប៉ុនពូដឹងថាគេហៅមក អ្នកដែលគេចាប់បានពីតាមកោះអីនឹង គេមិនដែលទុកយូរទេ?

សារ៉ាត់ ៖ បាទ!

ដានី ៖ អ្នកដែលគេ ឧបមាយើងចាប់ពីកោះមកអញ្ចឹង យកមកដល់គេយកមកទុកនៅកន្លែងណាទៅ បើពូដឹងកន្លែងជាក់ស្តែងនៅកន្លែងកងពល?

សារ៉ាត់ ៖ ខ្ញុំក៏មិនដឹងថាគេទុកកន្លែងណា ដូច្នេះ ពេលនោះយើងធ្វើម៉េច យើងដឹងតែការងាររបស់ យើងជាសំខាន់បំផុត ។

ដានី ៖ ប៉ុន្តែ ពូថាគេបញ្ជូនមកអញ្ចឹង យើងប្រគល់ឲ្យគេនៅណា?

សារ៉ាត់ ៖ អានឹងវាមិនអាចដឹងទេ ព្រោះប្រព័ន្ធកងពលនឹងកន្លែងដែលមានភារកិច្ចដឹងនឹង គឺថាគេទាក់ ទងគ្នាបញ្ជូនមកកន្លែងណា អានឹងយើងមិនអាចដឹង ព្រោះវាអត់ទាក់ទិន យល់ទេ ។ យើង ដឹងថាតែការងាររបស់យើងបំពេញភារកិច្ចរបស់យើង ខ្លួនយើង ធ្វើម៉េចគ្រប់គ្រងឲ្យការ ជាប់លាប់ និងគត់មុត ត្រឹមត្រូវនិងល្អ អានេះជាការប្រពៃរបស់ខ្លួនយើង ។ ឯសម្រាប់ ភារកិច្ចអ្នកផ្សេង និងការងារអ្នកផ្សេង យើងអត់មាន ដូចថាប្អូនឯងហើយអ៊ំនេះមកសួរអី

អត់ទេ អានេះអត់មានត្រូវការសួរគ្នាទេ ។ ឧទាហរណ៍ឃើញ២នាក់នោះគេដើរៗតែគេទៅ ហើយការសួរគ្នា យើងស្គាល់អី!ទៅណា គេបានប៉ុននឹង ហើយអ្នកនោះឆ្លើយមកថាទៅស្រែ ឬទៅចំការ ឬទៅមន្ទីរនេះ មន្ទីរនោះ វាជារឿងរបស់គេ ។

ដានី : កាលនឹងយើងអត់បាននិយាយគ្នាដូចឥឡូវទេ?

សារ៉ាត់ : បាទ!និយាយបាន កាលនិយាយមនុស្សស្គាល់គ្នា មិនស្គាល់គ្នាអី កាលលេងសើចអីបាន តែលេងសើចក្នុងក្របខ័ណ្ឌមួយគឺថា លេងចំលេង កុំឲ្យលេងប្រឡំមាន ។

ដានី : ចុះកន្លែងឧបមាថាអ្នកដែលគេចាប់មកអីអញ្ចឹង អ្នកនឹងមើលទៅគេចាប់មកដូចតែៗគ្នាទាំងអស់ទាំងជនដូចថា យួន បរទេស ដូចជាខ្មែរអញ្ចឹង?

សារ៉ាត់ : ឲ្យតែបរទេស ។

ដានី : គេចាប់មកដូចថាការ ដឹកមក ការបញ្ជូនអីយ៉ាងម៉េចៗដូចគ្នាទេយ៉ាងម៉េច ឬក៏ខុសគ្នា បើតាមពូដឹង?

សារ៉ាត់ : លក្ខណៈនឹងខ្ញុំអត់ដឹង ការទទួលនឹងយកនឹង បុគ្គលបញ្ជូន និងបុគ្គលទទួលនឹង ខ្ញុំមិនអាចដឹងទេ ។

ដានី : ប៉ុន្តែបើគេចាប់ពីកោះមក ចាប់មកដូចគ្នា?

សារ៉ាត់ : បាទ!

ដានី : ចាប់មករបៀបថាគេបញ្ជូនមកដាក់កងពលដូចៗគ្នា?

សារ៉ាត់ : បាទ!

ដានី : គេអត់មានដាក់នៅកន្លែងណាផ្សេងក្រៅពីកងពលទេ?

សារ៉ាត់ : មិនដឹងគេរៀបចំ ព្រោះខ្សែផ្សេង មិនដឹងជាខ្សែសន្តិសុខនឹង កងពលមានប៉ុន្មាន មិនអាចដឹងទេ ។ ថ្នាក់មជ្ឈិមមានប៉ុន្មាន យើងអត់អាចដឹងទេ ហើយអ្នកណាខ្លះយើងអត់ដឹង ។

ដានី : ចុះកាលកន្លែងនឹងមានមន្ទីរឃុំឃាំងអីគេដែរអត់?

សារ៉ាត់ : ខាងខ្ញុំ ។

ដានី : បាទ!ខាងកំពង់សោម?

សារ៉ាត់ : ខាងកំពង់សោមខ្ញុំអត់មានផង ។

ដានី : ខាងកងពល១៦៤?

សារ៉ាត់ : បាទ!អត់មាន ហើយកន្លែងរបៀបអញ្ចឹងៗ ដូចថាខ្ញុំក្របខ័ណ្ឌអនុសេនាធំ ឬប្រធាននាវាដូច្នេះខ្ញុំធ្វើការងារអីក៏ដោយ ដូចថាខ្ញុំនិយាយពីសកម្មភាពដែលខ្ញុំកំពុងតែធ្វើ ហើយយើង

បន្តធ្វើៗ ដោយយកស្មារតីណា  បានន័យថាខត្តមគតិពេលនោះយើងសំរួចតែពីរឿងការងារ ឲ្យវារីកចំរើន  អ្វីដែលមិនរីកចំរើនយើងកំចាត់  លះបង់ៗក្នុងខ្លួន  មិនមែនលះបង់ឲ្យអ្នកដទៃយើងស្លាប់ទេណា ។

ដានី :  យើងសំអាតខ្លួនយើង?

សារ៉ាត់ :  បាទ!សំអាតខ្លួនយើងឲ្យស្អាត  ដូច្នេះ  ដូចថាយើង  ដូចយើងថែរក្សាបេះដូងយើងឲ្យវាស្ថេរភាពក្នុងជីវិតអញ្ចឹងណា  បានន័យថាជីវិតរបស់យើងក៏ដោយ  រុក្ខជាតិក៏ដោយវាត្រូវការថែរក្សាដោយមានការដាក់ជីបាញ់មិនអញ្ចឹង ។

ដានី :  ចុះពូនៅខាងដូចថាច្រកខាងកើតនឹង  យើងមានដូចថាមានពួកស៊ើបការណ៍នឹថ  ចុះខាងថៃគេមានមកស៊ើបការណ៍នេះដែរអត់?

សារ៉ាត់ :  ខាងថៃ  វាច្រើនតែប្រើទូកនេសាទធំៗ ។

ដានី :  ទូកនេសាទធំៗ ?

សារ៉ាត់ :  និងយោធាវាមក ។

ដានី :  ទូកនេសាទធំៗនឹង  មានយោធានៅក្នុងនឹងទៀត?

សារ៉ាត់ :  យោធាកាប៉ាល់ម៉ង  កាប៉ាល់យោធាដូចខ្ញុំនិយាយតាមឡានឹងមានកាប៉ាល់យោធាគេហៅ PSON11នឹង  វាមកជួនកាល៣គ្រឿងមកកាងអញ្ចឹងទៅ  មកកោះតាងប្រហែលជា៥  ៦គីឡូអញ្ចឹងមក  ៥  ៦គីឡូទឹកពីកោះតាង ។

ដានី :  អញ្ចឹងយើងធ្វើម៉េចទៅអញ្ចឹង?

សារ៉ាត់ :  អានឹងគេប្រើកាប៉ាល់ប្រើអីអញ្ចឹង  កាលណាវាឃើញយើងអញ្ចឹង  វាបាញ់មកៗយើងចេះតែរ៉ុលទៅទៀតទៅ  ហើយយើងប្រើតេអូចិត្តសាស្ត្រវា ។

ដានី :  តេអូចិត្តសាស្ត្រម៉េច?

សារ៉ាត់ :  ចិត្តសាស្ត្រដោយគំរាមថាយកនាវាយើងប្រយុទ្ធទៅៗវាយទៅអីអញ្ចឹងយើងទៅវិញ  បើថាយើងអត់ប្រើអញ្ចឹងវាអត់ ។  កាប៉ាល់ចាប់ត្រីវាចាប់  កាលនោះត្រីសំបូរណាស់ ។

ដានី :  បាទ!ខ្ញុំធ្លាប់ដឹងតាមឡាន  អីគាត់និយាយថាកាលនឹងមានឃើញកាប៉ាល់ធំៗដូចថានេសាធំៗអា១២០០សេសអី  អាធ្ងន់ធំៗ  ដូចថាមាន?

សារ៉ាត់ :  វាចេញម្តងបានចូលមកស្រុកវិញម្តង  កាប៉ាល់ចាប់ត្រីវានឹង ។

ដានី :  យើងមានចាប់បានទេ?

សារ៉ាត់ :  អានឹងខ្ញុំធ្លាប់ឃើញបានមួយ ។

ដានី ៈ ចាប់នឹងយើងបញ្ជូនមកកន្លែងណា?

សារ៉ាត់ ៈ បញ្ជូនមកកំពង់សោម ។

ដានី ៈ បញ្ជូនមកភ្នំពេញ ឬក៏មកកំពង់សោម?

សារ៉ាត់ ៈ មកកំពង់សោម ។

ដានី ៈ អានឹងដូចថាកាប៉ាល់នឹងមានកន្លែងនេសាទ ចូលមកលើ ដែលសមុទ្រយើង ចូលក្នុងសមុទ្រយើងឬយ៉ាងម៉េច?

សារ៉ាត់ ៈ ចូលដល់ក្នុងដែនសមុទ្រយើង ព្រោះធម្មតាដែនសមុទ្រវាមាន៦ម៉ៃពីដែនកោះ អ្នកណាចូលហួសពីនឹង អ្នកនោះរំលោភ ក្រៅពីនឹង៧គីឡូ ៧ម៉ៃ ទៅបានន័យថាអ្នកឯងទៅខាងតអន្តរជាតិ អានឹងមានក្របខ័ណ្ឌអញ្ចឹង ។ ប៉ុន្តែអ្នកឯងចូលហួសមកគេត្រូវឃាត់ភ្លាម ។

ដានី ៈ ចុះដូចជាកាប៉ាល់ ដូចថាខាងទូកនេសាទអីអញ្ចឹង ដែលចូលមក អញ្ចឹងយើងឃាត់ខ្លួននឹងដូចថាជារបៀបលក្ខណៈយ៉ាងម៉េច ជាទូកនេសាទថៃអីអញ្ចឹង យើងឃាត់?

សារ៉ាត់ ៈ យើងឃាត់ខ្លួនក្នុងលក្ខណៈជាជួរទូត ។

ដានី ៈ ជួរទូតយើងចាប់គេមក?

សារ៉ាត់ ៈ ជាជួរទូតយើងចាប់មក ហើយឲ្យទូតគេចរចាយ៉ាងម៉េច គេយកមនុស្សគេបានទៅវិញ ។

ដានី ៈ ចុះអ្នកនេសាទថៃនឹង តាមមើលគេបញ្ជូនទៅភ្នំពេញដែរ ដើម្បីចរចាគ្នា?

សារ៉ាត់ ៈ អានឹងខ្ញុំអត់យល់ ព្រោះអានឹងវាចូលដល់ក្នុងកិច្ចការបរទេស ។

ដានី ៈ យើងដឹងថាយើងឃាត់មក យើងបញ្ជូនមកកន្លែងកងពល?

សារ៉ាត់ ៈ គាត់ណែនាំថា បើកាលណាមានទូកគេមកអញ្ចឹង យើងចាប់បានគេយើងត្រូវរាយការណ៍មកដើម្បីដោះស្រាយជាជួរទូត ។

ដានី ៈ យាមុត គាត់ថាអញ្ចឹង?

សារ៉ាត់ ៈ បាទ!គាត់ថាអញ្ចឹង នេះជាការងារមួយដែលយើងសម្រាប់អនុវត្ត ចុះបើកាលណាគេមកអញ្ចឹងយើងឃាត់ខ្លួនគេបាន ជួរទូតគេនិយាយគ្នាយ៉ាងម៉េចយើងអត់ ហើយគេយកតាមណាក៏យើងអត់ដឹង ។

ដានី ៈ យើងមានតួនាទីប្រាប់គ្រាន់តែយើងឃាត់ខ្លួនគេ បញ្ជូនមកកំពង់សោម?

សារ៉ាត់ ៈ បាទ!

ដានី ៈ ចុះពេលដូចថាថៃៗពួកភាគច្រើនជាអ្នកនេសាទ តែបើយួនវិញវាមានដូចពូមានប្រសាសន៍មិញថាមានដូចជាពួកទំនងជាអ្នកធ្វើការមានអ្នកភៀសខ្លួន មានអ្នកនេសាទដែរ អត់ទេ?

សារ៉ាត់ ៖ អានឹងក៏មាន ។

ដានី ៖ អញ្ចឹងដូចមានលក្ខណៈផ្សេងៗគ្នាអញ្ចឹង អ្នកនឹងដូចថាខាងកងពលមានបញ្ហា មានការណែនាំអីទេ?

សារ៉ាត់ ៖ ណែនាំ គឺថាជនស៊ីវិលមិនអាចប៉ះពាល់ទេ ប៉ះពាល់ដោយរបៀបជាឃាត់ខ្លួនស៊ើបអង្កេតល្អិតល្អន់ណា ថាអ្នកឯងជាជនក្បត់ខ្លួន ប៉ុន្មានអ្នកឯងចង់ទៅដោយសុវត្ថិភាព ដល់កន្លែងខ្លះពេលខ្លះអត់ស្បៀងបញ្ជូនឲ្យទៀត បញ្ជូនដោយសុឆន្ទៈ អ្នកឯងទៅដោយទៅរកខាងលិចគឺថាទៅតាមទូក តែធ្វើម៉េចលើកក្រោយកុំឲ្យមក ។ ប៉ុន្តែធម្មតាអ្នកទៅអញ្ចឹង គ្នាមិនត្រឡប់ទេតែទៅៗហើយ ធម្មតាទូកមួយជិត៨នាក់អី កូនទូកណា ផ្សេងព្រេង យើងឃើញរបៀបនេះមានតែអាណិត ហើយទូកគ្នាតូចៗ ។

ដានី ៖ ហើយចុះបើខាងពួកអ្នកស៊ើបការណ៍ចូលមកកោះយើងអី ខាងកងពលគេណែនាំអីយើង?

សារ៉ាត់ ៖ គេណែនាំឲ្យឃាត់ខ្លួនហើយ បើយើងចាប់បានរបៀបនេះ គេត្រូវបញ្ជូនទៅស-២១ ។

ដានី ៖ បញ្ជូនទៅស-២១ កងពលណែនាំអញ្ចឹង?

សារ៉ាត់ ៖ បាទ!ណែនាំអញ្ចឹង ។

ដានី ៖ ប៉ុន្តែពួកអ្នកដែលឃាត់ខ្លួនរបៀបជាអ្នកស៊ើបអង្កេត ហើយបញ្ជូនទៅស-២១នឹង នឹងគេបញ្ជូនត្រង់មកអូរឈើទាល មករាម អឺ!មកន្លែងកងពលនៅកំពង់សោម ឬបញ្ជូនមករាមហើយបានបញ្ជូនតាមឡានមកកងពល?

សារ៉ាត់ ៖ ដូចនែក!អានឹងដូចខ្ញុំនិយាយអញ្ចឹង រវាងបញ្ហាថាតើចូលរាម ឬចូលកំពង់សោម នៅពេលនឹងគឺថាដាច់ពីគ្នាយើង ដូចមិនអាចមើលឃើញគ្រប់ពេលណា ពេលដែលយើងឃើញៗប៉ុន្តែដល់ចេញផុតៗ ។

## **កាសែ្សតទី៣ ផ្នែក«ក»**

ដានី ៖ ចុះក្រោយមកទៀតដូចជាចន្លោះ ក្នុងចន្លោះឆ្នាំ៧៨ មានកាប៉ាល់ណាផ្សេងៗ ដូចកាប៉ាល់ដូចថាត្រូវព្យុះ ឬក៏វង្វេង ហើយបើកចូលកោះតាង ។ អានឹងពូមានដឹងថាមានកាប៉ាល់ណាវង្វេងចូលមក?

សារ៉ាត់ ៖ ដូចខ្ញុំអត់ដែលបានជួប ។

ដានី ៖ ពូដែលដឹងអត់?

សារ៉ាត់ ៖ តែពត៌មានក៏អត់ ។

ដានី ៖ ចុះនៅក្នុងទូកយើងមានវិទ្យុទាក់ទង?

សារ៉ាត់ ៖ មានវិទ្យុទាក់ទង តែអាវលេកទាក់ទងកោះ និងទីបញ្ជាការផ្សេង ហើយយើងវលេកផ្សេង គេវលេកផ្សេង អត់ឲ្យចូលមកទេ ។

ដានី ៖ អត់មានជួបគ្នាទេនោះ?

សារ៉ាត់ ៖ បាទ! វលេករួមមាន ដល់ហៅឆ្នេងស្តាំង វលេកតេអូយើងតេអូរបស់អាមេរិចខុសគ្នា ។

ដានី ៖ តេអូរបស់អាមេរិចម៉េច?

សារ៉ាត់ ៖ តេអូរបស់អាមេរិច អា៨៦៧ធំៗ ០២៥អឹនឹង អានឹងខុសពីតេអូចិន ហើយពេលនឹងវាជួបអត់ចូលគ្នាទេវលេក ផ្សេងគ្នាហើយ ។

ដានី ៖ អញ្ចឹងបានន័យថាតេអូចិន ហើយនឹងតេអូនេះនឹងទាក់ទងគ្នា?

សារ៉ាត់ ៖ អត់ទេ អត់ចូលម៉ង ។

ដានី ៖ បើហៅគ្នាទៅវិញទៅមកបាន?

សារ៉ាត់ ៖ អត់បាន អានឹងក៏អត់បាន ដូចសេវា១២ និង៩២នឹង ខុសគ្នាអញ្ចឹង ។

ដានី ៖ ប៉ុន្តែបើយើងហៅផ្ទាល់គ្នាមកពីមួយទៅៗ ដូចថាយើងចង់ហៅទៅកងពល ហៅចេះហៅទៅមកបាន?

សារ៉ាត់ ៖ ខ្ញុំប្រើប្រព័ន្ធតេអូចិន គេមានជំនាញមួយ ដូច្នេះដាច់ពីគ្នា ។

ដានី ៖ តែនៅជំនាន់នឹងពូ មិនដែលបានឮ ឬដែលដឹងថាមានដូចថាកាប៉ាល់ជនជាតិបរទេស ជនជាតិស្បែកស ពួកច្រមុះស្រួច ពួកសក់ក្រហមអីនឹង ឮដំណឹងថាមានមក ចូលដល់កោះគាងហើយមាន?

សារ៉ាត់ ៖ អាត្រង់នឹងហើយ ដែលខ្ញុំនិយាយថាប្រព័ន្ធតេអូយើងវាអត់មានទាក់គ្នាណា ផ្នែកខាងនាវាប្រើតេអូចិន ផ្នែកខាងកោះ ផ្នែកខាងកងពលប្រើតេអូអាមេរិច ។ ដូច្នេះវាអត់ទេ សម្លេងក៏អត់ឮភ្នែកក៏វាអត់ឃើញ ព្រោះវានៅឆ្ងាយ អត់ដឹងៗថាម៉េចៗ ចន្លោះនឹងគឺអត់ដឹង ។ ពេលនឹងបន្ទុកខ្ញុំមានតែតេអូ៦៣ និងតេអូទូរលេខរបស់ចិន ។

ដានី ៖ ពេលដែលពូឡើងមកកន្លែងកងពល ពូមានដែលដឹងអត់ មានដូចថាធ្លាប់និយាយ ថាមានបរទេសផ្សេងៗ?

សារ៉ាត់ ៖ អានឹងវាចេះ គឺថាពេលដែលឡើងមកធ្វើការ ជួបគ្នាក្នុងកងពល វាអត់មាននិយាយអីពីរឿងការងារទេ ។ និយាយពីរឿងកិច្ចការដែលយើងធ្វើម្នាក់ ប្រាប់ខ្ញុំរៀនខាងបច្ចេកទេសអញ្ចឹងទៅ គាត់ហៅខ្សែមួយៗ ឧទាហរណ៍ខាងកោះគេហៅមកខ្សែមួយ មិនអញ្ចឹងនៅខាងការងារកោះ ផ្នែកខាងការមាននាវា គាត់ធ្វើដោយឡែក អត់មានប្រព័ន្ធជួបគ្នាទេ ។

ដានី ៖ អត់ទេខ្ញុំគ្រាន់ថាចង់ដឹងថា ពេលយើងនិយាយលេង ពេលដែលជួបគ្នា សំនេះសំនាល?

សារ៉ាត់ ៖ បាទ!ខ្ញុំយល់ ប៉ុនអាពេលវេលាដូចខ្ញុំបញ្ជាក់មិញអញ្ចឹង ពេលដែលធ្វើការងារជើងទឹកខាងនាវា គាត់ហៅនាវាមក ដូច្នេះជួបខាងជើងទឹកគ្នាឯង ដូច្នេះនិយាយលេងធម្មតាខាងជើងទឹកឯគេខាងគោកគេធ្វើការងារខាងគោក គេនិយាយគ្នាគេទៅ ។ ដូច្នេះ វាផ្នែកខុសគ្នាៗ ពេលវេលាខុសគ្នា ។

ដានី ៖ អត់ដែលបានជួបគ្នាទេអញ្ចឹង?

សារ៉ាត់ ៖ អត់ទេ ។

ដានី ៖ ចុះពេលប្រជុំសន្និបាតកងពលធំៗនេះអី មានដែលមករួមគ្នាទេ?

សារ៉ាត់ ៖ អានេះតាមភារកិច្ច ឧទាហរណ៍ថាធ្វើបុណ្យធំជួបគ្នាៗទៅជួបនៅភ្នំពេញតែម៉ង ។

ដានី ៖ ទៅជួបគ្នានៅភ្នំពេញម៉ង?

សារ៉ាត់ ៖ បាទ!ថាជួបមនុស្សច្រើនម៉ង ដឹងណាណែទេ ។

ដានី ៖ ចុះពូតាមុត ដូចថាធ្លាប់ជិះកាប៉ាល់អី ដូចថាកាប៉ាល់យើងកាប៉ាល់ការពារកាប៉ាល់អី មានធ្លាប់ជិះដើរមើលកោះមើលអីអត់?

សារ៉ាត់ ៖ ធ្លាប់ ។

ដានី ៖ គាត់ធ្លាប់ទៅជាមួយពូដែរអត់?

សារ៉ាត់ ៖ ទៅ ។

ដានី ៖ កាលនឹងគាត់ទៅកោះណាដែរ?

សារ៉ាត់ ៖ គាត់ចេញចូលអញ្ចឹងទៅ ពេលខ្លះគាត់ទៅប៉ូឡូវៃ ពេលខ្លះគាត់ទៅកោះរ៉ុងអញ្ចឹងទៅ ។

ដានី ៖ កោះតាងអី គាត់ធ្លាប់ទៅដែរ?

សារ៉ាត់ ៖ ទៅ ។

ដានី ៖ ដូចគាត់ច្រើនតែគ្នាទៅនឹង ក្នុងនាមដូចថាទៅយ៉ាងម៉េច?

សារ៉ាត់ ៖ ក្នុងនាមអ្នកគ្រប់គ្រង បំពេញភារកិច្ចរបស់គាត់ ដែលគេហៅថាគាត់ក្តាប់រួម ។

ដានី ៖ កាលទៅជាមួយពូក្នុងឆ្នាំណា?

សារ៉ាត់ ៖ ក្នុង៧៧ ៧៦ ៧៨ ។

ដានី ៖ ៧៨គាត់ធ្លាប់ទៅដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ អញ្ចឹងគាត់នៅកំពង់សោមជាប់រហូតម៉ង?

សារ៉ាត់ ៈ  តាមុត គាត់ដាច់ក្រោយពេលក្នុងចុះ៧៨ គាត់ដកមកភ្នំពេញ ។

ដានី ៈ  ចុះគាត់ដកមកភ្នំពេញនឹង ពីណាគេអ្នកគ្រប់គ្រងវិញទៅ?

សារ៉ាត់ ៈ  គ្រប់គ្រងបងសេង បងសារឿន គាត់គ្រប់គ្រងនាវា ហើយគ្រប់គ្រងក្របខ័ណ្ឌដែនកោះនឹង នឹងគាត់គ្រប់គ្រង ។

ដានី ៈ  ឈ្មោះសេង ឈ្មោះសារឿន?

សារ៉ាត់ ៈ  បាទៗ ។

ដានី ៈ  ប៉ុន្តែពួកគាត់ទាំង២នឹង ទៅណាម៉េចទៅ?

សារ៉ាត់ ៈ  ពួកគាត់ទាំង២នឹង មកស្លាប់កាលសម័យយើងមកព្រំដែរ ។

ដានី ៈ  ចុះដូចជាក្នុងកងពល ដូចតាមុតគាត់ដកទៅភ្នំពេញទៅ ដូចថាអ្នកក្តាប់រួម កងពលរួមពីណាគេវិញទៅ?

សារ៉ាត់ ៈ  អានឹងបងសារឿនគាត់ទទួលបណ្តោះអាសន្ន ។

ដានី ៈ  ចុះតាញាន់?

សារ៉ាត់ ៈ  ហ្នឹងហើយ តាញាន់ បងសារឿន ប៉ុនពេលនឹងគាត់ប្រគល់ វរសេនាធំជើងទឹកគាត់ទទួលរួម ។ ហើយចន្លោះឆ្នាំ ដល់ឆ្នាំ៧៨ចូល៧៩នឹង ក៏បងសារឿន គាត់ឡើងទៅភ្នំពេញទៀតកុនៗហើយ ពេលគេហៅថាក្នុងចន្លោះខែ១២ខែអីនឹង ។

ដានី ៈ  ចុះតាមុតគាត់ទៅចន្លោះតាំងពីខែប៉ុន្មានៗ?

សារ៉ាត់ ៈ  ក្នុងអាចមុនគ្នា២ ៣ខែ អត់មានពេលវេលាឆ្ងាយទេ ពេលវេលាខ្លី ទទួលនឹងសភាពការណ៍ប្រឹបមក ។

ដានី ៈ  ថាទៅមុនបែក២ ៣ខែនឹង?

សារ៉ាត់ ៈ  បាទ!២ ៣ខែកាត់តាមមេមត់ កាត់អីអញ្ចឹង ។

ដានី ៈ  តាមុត គាត់ទៅដល់មេមត់ដែរ?

សារ៉ាត់ ៈ  គាត់ជំនួសឲ្យតាសុន សេន ។

ដានី ៈ  គាត់ទទួលខាងសេនាធិការដែរ?

សារ៉ាត់ ៈ  បាទ!

ដានី ៈ  ចុះតាសុន សេន គាត់មានដែលចុះមកដល់?

សារ៉ាត់ ៈ  គាត់មក ។

ដានី ៈ  ពូដែលបានឃើញគាត់មកដែរអត់?

សារ៉ាត់ ៖ ឃើញ ។

ដានី ៖ កាលនឹងគាត់ជាសេនាធិការ?

សារ៉ាត់ ៖ បាទ! សេនាធិការ អគ្គមេបញ្ជាការ ។

ដានី ៖ តាមុត អញ្ចឹងគាត់អគ្គមេបញ្ជាការរង?

សារ៉ាត់ ៖ បាទ! មេបញ្ជាការរង ។

ដានី ៖ ចាប់ពី៧៥មកដែរ?

សារ៉ាត់ ៖ ហ៎! ទើបនឹងឡើងទេ ទើបនឹងទៅក្នុងចន្លោះ៧៨ទេ ពី៧៥ដល់៧៧ ៧០អី គាត់នៅក្របខ័ណ្ឌ តួនាទីរបស់គាត់ជាជើងទឹក គ្រប់គ្រង១៦៤ ។

ដានី ៖ ៧៨បានគាត់ឡើង?

សារ៉ាត់ ៖ ចុង៧៨ ។

ដានី ៖ អញ្ចឹងគាត់ ពេលដែលគាត់ទៅនឹង គាត់អត់មានដកកម្លាំងពីជើងទឹកទៅ?

សារ៉ាត់ ៖ ទៅ ដកពួកកោះមួយចំនួន ។

ដានី ៖ ដកទៅប្រហែលជាបានរយៈពេលប៉ុន្មានដែរ?

សារ៉ាត់ ៖ ពេលវេលាខ្លីណា ។

ដានី ៖ ខ្លីនឹងប្រហែលជាខ្វង់ប៉ុន្មាន?

សារ៉ាត់ ៖ អត់ហួសពីមួយត្រីមាសផង ។

ដានី ៖ អត់ហួសពីម៉ាត្រីមាសទេ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចន្លោះពី៣ខែ ២ខែ ៣ខែបែកបណ្តោយ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះកងពលពីណាគេដែលនៅជាប់រហូត ដល់រត់បណ្តោយ នៅកន្លែងកងពល នៅសមុទ្រ នៅកំពង់សោមនឹង នៅជាប់រហូត?

សារ៉ាត់ ៖ ជាប់រហូតម៉ែងដូចមិនមានទេ ខ្ញុំចាំបានច្បាស់ពីខែ៩មក តាមុតអត់នៅទេខែ៩ ៧៨ ដូច្នេះប្រគល់ឲ្យបងញ៉ាន់ និងបងសារឿន។ ក្រោយមកបងសារឿន បងញ៉ាន់ គាត់វិលទៅប្រយុទ្ធនៅភ្នំពេញ កំពង់សោមដែរ ។

ដានី ៖ គាត់មកភ្នំពេញដែរ?

សារ៉ាត់ ៖ មានវត្តមានតែបងញាទ់មួយទេ ប៉ុន្តែបងញាទ់គាត់មិនមានអីគេហៅថាការ បណ្តាញទាំងអស់ដឹងដែរ មានកម្រិត ។

ដានី ៖ ដោយសារតែយ៉ាងម៉េច ដោយគាត់?

សារ៉ាត់ ៖ ដោយសារ អានឹងវាគ្មានអីទេ សំខាន់ឧទាហរណ៍ថាការយល់ដឹងបច្ចេកទេសរបស់គាត់ឧទាហរណ៍ថាឥឡូវគ្រប់គ្រងកោះយ៉ាងម៉េច គ្រប់គ្រងនាវាយ៉ាងម៉េច ការយល់ដឹងរបស់គាត់តិចតួច ដូច្នេះអានឹងហើយ ។

ដានី ៖ ធ្វើឲ្យគាត់អត់សូវបានទទួលពត៌មាន អត់សូវបាន?

សារ៉ាត់ ៖ ហ្នឹងហើយ អាបទបញ្ជាផ្សេងៗវាមិនចំ ។

ដានី ៖ ចុះពីណាគេដែលដឹងច្រើនអាគ្រប់គ្រងៗ?

សារ៉ាត់ ៖ មានតែបងមុតទេកិច្ចការច្រើន ។

ដានី ៖ ទោះជាគាត់ទៅខាងមេមត់អីនឹង នៅតែនៅគ្រប់គ្រងកងពលដដែលបញ្ជា នៅតែ?

សារ៉ាត់ ៖ ជាសារទូរលេខអី ឆ្លងឆ្លើយ ។

ដានី ៖ ជាសារទូរលេខអី ឆ្លងឆ្លើយនៅតែគាត់ទទួលអញ្ជឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ដូចថាមានបញ្ហានៅដែនសមុទ្រអី បញ្ហាមានព្រឹត្តិការណ៍អីប្លែក?

សារ៉ាត់ ៖ អានឹងសារទូរលេខហើយ ។

ដានី ៖ សារទូរលេខ ប៉ុន្តែគាត់នៅតែបញ្ជាផ្ទាល់ ពីសារទូរលេខ?

សារ៉ាត់ ៖ បាទ!បញ្ជាបាន ។

ដានី ៖ ពូនៅច្រក ដូចថានៅ ពេលថ្ងៃនៅអូរឈើទាល ពេលយប់ទៅកន្ទែងកោះសេះ កោះថ្មីដាក់បើកវ៉ាដានឹង រហូតដល់៧/៩ម៉ោង?

សារ៉ាត់ ៖ ទៅដល់ថ្ងៃ៥ ថ្ងៃ៦ ព្រឹកថ្ងៃ៧បានដាច់ ព្រឹកថ្ងៃ៧ស្មានតែនឹងខ្ញុំនៅប្រយុទ្ធក្នុងទឹកវេលាម៉ោង ១០ម៉ោងអីនឹងខ្ញុំកំពុងប្រយុទ្ធ ហើយបានខ្ញុំដឹងសភាពការណ៍ វាអស់ពេលវេលាអនុគ្រោះអត់មានទេ ខ្ញុំត្រូវ នាវាខ្ញុំត្រូវយកមកទុកកោះរ៉ុង សំលឹងវិញទាំងអស់ប្រមូលផ្តុំ ។ បានមានបទបញ្ជាមក បងមុតមក ទូរលេខឲ្យនាវាមិត្តធ្វើដំណើរទៅកោះកុង ។

ដានី ៖ ឲ្យធ្វើដំណើរមកកោះកុង ធ្វើដំណើរមកទាំងអស់គ្នាដែរ?

សារ៉ាត់ ៖ ទាំងអស់គ្នាម៉ង ទាំងតូចទាំងធំមកម៉ង ។

ដានី ៖ អានឹងគាត់ទូរលេខមក?

សាវ៉ាត់ ៖ បាទ!ទូរលេខ ។

ដានី ៖ យ៉ាងម៉េចទៅ កាលនឹងមកកោះកុង?

សាវ៉ាត់ ៖ ចូលមកកោះកុងមានអីយើងត្រូវកំទេចសម្ភារៈនឹងចោល កំទេចចោលទាំងអស់ ។

ដានី ៖ ហេតុអីបានយើងចាំបាច់កំទេច?

សាវ៉ាត់ ៖ អានឹងយើងធ្វើម៉េចកុំឲ្យពួកខ្មាំងយកបាន កុំឲ្យយួនយកវិញ កុំឲ្យយួនយកទៅប្រើ ។

ដានី ៖ ដល់ពេលបើថាយួនយកមកប្រើវាធ្វើឲ្យយើងពិបាក?

សាវ៉ាត់ ៖ បាទ!នាវាយើងវាថ្លៃ ហើយសំខាន់ យកចេញពីកោះ ហើយស្អាតមែនទែន ស្អាតត្រង់ថា នាវាខ្ញុំត្រូវបើកទឹកបញ្ចូលពន្លិចម៉ង ដល់ធ្លាក់ក្រោមទៅវាទឹកហូរចូលលិចដ្ឋីមៗម៉ង ។ ដល់កម្មេចដាច់មាំត់ម៉ងខែ៨ឆ្នាំ៧៩ ដាច់ម៉ាត់ទាំងអស់ ។

ដានី ៖ បានន័យថាយើងអត់មានកន្លែងឈរជើងទៀតទេ?

សាវ៉ាត់ ៖ អត់មានកន្លែងទៀតទេ ។

ដានី ៖ ខែ៨៧៩នឹង កម្ទេចអស់ម៉ង?

សាវ៉ាត់ ៖ បាទ!ទាំងអស់ ។

ដានី ៖ ពេលនឹងដូចថារបៀប ពូខាងការពារ នាវាការពារ ចុះនាវាខាងបណ្ដែត នាវាខាងសំអាតមីន ខាងអីនឹង មីនយ៉ាងម៉េច គេបណ្ដែត គេបាញ់អីយ៉ាងម៉េចទៅ?

សាវ៉ាត់ ៖ ព្រោះបណ្ដែតនឹង គេជានាវាខ្នាតតូចប្រយុទ្ធខ្នាតធំ បានន័យថាខ្លួនតូចកំទេចនាវាធំ ហើយនាវាបោសមីន គេសម្រាប់ប្រឆាំងមីនដែលខ្មាំងគេចូលមកដាក់កាត់នៅចំនុចខទាហរណ៍កំពង់ផែ ។ ខទាហរណ៍ឥឡូវកំពង់ផែយើង មានជម្រៅទឹក២៥ម៉ែត្រ នាវាដែលត្រូវចូលលើនឹងព្រោះនាវានឹងវារត់លើទឹក វាស៊ីទឹកតែ៨ទឹក ដូច្នេះការរំដួយនិងការបុករបស់មីនពន្លិច ដូចថាមីនបណ្ដែតក្នុងទឹកនឹងវាអត់មកប៉ះវាទេ វាដឹងវាជាពេលវាជាស៊ួណាចាប់បានថា កន្លែងនឹងមានមីន មានគេដាក់ ។ អញ្ចឹងនាវានឹងវាជាន់មីង សម្រាប់កម្ទេចមីនក្នុងទឹកនឹង វាជាន់ទម្លាក់កន្លែងនឹងទៅ វាផ្ទុះទៅវាទៅផុតទៅ ។

ដានី ៖ អានឹងវាលើនខ្លាំងម៉ងអញ្ចឹង?

សាវ៉ាត់ ៖ លឿនវា៤០ ៥១គីឡូទឹក ក្នុងមួយម៉ោង វាជិត១០០គីឡូគោក ។

ដានី ៖ ជិត១០០គីឡូគោក?

សាវ៉ាត់ ៖ បាទ!

ដានី ៖ អូ!ទៅបាត់ទៅមីងផ្ទុះអត់ទាន់ទេ?

សារ៉ាត់ ៖ អត់ទេ អាមីនខ្លួនវាដែលជាន់នឹង វាផ្ទុះកំទេចមីន ឯវាផុតៗប្រហែលជា១៨០ម៉ែត្រអី អញ្ចឹងបានវាផ្ទុះ ។

ដានី ៖ អានឹងមានដែលជាជួបហេតុការណ៍នឹងដែរ?

សារ៉ាត់ ៖ សាកល្បង ។

ដានី ៖ មានសាកល្បងទេ?

សារ៉ាត់ ៖ បាទ!ហាត់ហ៊ឹកហ៊ឺនសាក់ល្បង ។

ដានី ៖ ប៉ុនជាក់ស្តែងមានដែលបានកម្ទេចអញ្ចឹងទេ?

សារ៉ាត់ ៖ អត់ទេ ពេដែលប្រយុទ្ធជាក់ស្តែង ពេលដែលនាវារបស់យួនចូលមក ហើយនាវាខ្ញុំប្រយុទ្ធជាក់ស្តែងទៅ ហើយវាស្ទាក់ដំណើរការក្នុងថ្ងៃ៧នឹង អត់មកទៀតទេ ។ វាត្រូវគេថានាវានៅត្រឹង វាឈប់រុល ដល់ថ្ងៃ៨បានវាកិល ថ្ងៃ៩បានកិល ប៉ុនខ្ញុំមកលិច ។

ដានី ៖ នាវារបស់យួនបានកិល?

សារ៉ាត់ ៖ បាទ!កិលចូល ។

ដានី ៖ ចុះពួកអាបណ្តែតអាខ្លួនតូចបាញ់កាប៉ាល់?

សារ៉ាត់ ៖ ថ្ងៃ៨យើងទៅបាញ់វាលិចម៉ាគ្រឿង បណ្តែតបាញ់ បងប្អូនទៅសួរគាត់ ។

ដានី ៖ គាត់អ្នកកាន់នាវាបណ្តែតនឹង?

សារ៉ាត់ ៖ បាទ!នាវាបណ្តែត ។

ដានី ៖ គាត់អ្នកបាញ់?

សារ៉ាត់ ៖ បាញ់ ពីយប់ខ្ញុំ ហើយនាវា១០៧ ខ្ញុំលិចម៉ាគ្រឿងនាវា១០៧ស្លាប់ទាំងអស់ ។

ដានី ៖ ១០៧ម៉េច?

សារ៉ាត់ ៖ ១៧-៧នឹង ត្រូវលិចម៉ង ។

ដានី ៖ ១៧-៧ដែលរបស់?

សារ៉ាត់ ៖ របស់សៀននឹង ។

ដានី ៖ របស់សៀននឹងលិច?

សារ៉ាត់ ៖ បាទ!ទាំងសៀននឹងរហូតមកដល់ថ្ងៃនេះ ។

ដានី ៖ គេបាញ់ត្រូវ ហើយម៉េច?

សារ៉ាត់ ៖ បាទ!គេបាញ់ត្រូវ ។

ដានី ៖ ក្នុងនឹង៣៨នាក់នឹង លិចបាត់?

សាវ៉ាត់ ៖ បាទ! បាត់នៅសល់៧ ។

ដានី ៖ ៧នឹងហែលទឹកហើយយ៉ាងម៉េច?

សាវ៉ាត់ ៖ ហែលទឹក ហែលពងឡើង បានមកជួបខ្ញុំនៅនេះ ព្រំដែន បែកគ្នារហូត ។

ដានី ៖ ប៉ុន្តែសឿននឹងបាត់ពេលនឹងដែរ?

សាវ៉ាត់ ៖ បាត់ ស្លាប់ពេលនឹង ។

ដានី ៖ ស្លាប់ដោយសារមើលទៅត្រូវគ្រាប់ ឬក៏?

សាវ៉ាត់ ៖ ត្រូវគ្រាប់ ព្រោះវាបាញ់ចំអាទីបញ្ជាការបើកបរ ធម្មតានាវាយើងរូបវាអញ្ចឹង កាលណាមានតួនាវាអញ្ចឹង វាមានទីបញ្ជាការមួយនឹង គេបាញ់មកចំនៅនឹងម៉ង ចំនឹងវាត្រូវដាច់ជា២ហើយ ព្រោះគេបាញ់ៗអាប្រភេទកាំជ្រួចទឹកជ្រៅ គ្រាប់វាទំហំ១២២ និង១៣០មីលីម៉ែត្រ បាញ់មកស្រីបៗនឹងផ្ទុះ៧ ៨ គ្រាប់ម៉ង ។ ដូច្នេះនាវាយើងទទឹង៧ម៉ែត្រវាហែកដូចយើងចាប់ក្រដាសបត់អញ្ចឹង ចាប់ក្រដាសបត់ហែកម៉ាឆ្នាត់ ។

ដានី ៖ អញ្ចឹងលិចតែម៉ាគ្រឿងនឹងទេ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ លិចនៅម្តុំណានឹង?

សាវ៉ាត់ ៖ លិចនៅខាងលិចកោះថ្មី ។

ដានី ៖ ខាងលិចកោះថ្មីចំងាយប្រហែលប៉ុន្មាន?

សាវ៉ាត់ ៖ ចន្លោះកោះថ្មី និងកោះតាគៀវ ។

ដានី ៖ ឆ្នាំថ្ងៃខ្ញុំប៉ុន្មានអានឹង?

សាវ៉ាត់ ៖ ថ្ងៃ៦ យប់ថ្ងៃ៦ ៧៩ ។

ដានី ៖ អញ្ចឹងពេលដែលបានប្រយុទ្ធនឹង ភាគច្រើនប្រយុទ្ធនៅក្នុងចន្លោះថ្ងៃ៥ ថ្ងៃ៦ ថ្ងៃ៧នឹងទេ?

សាវ៉ាត់ ៖ បាទ! ចន្លោះតែ២ថ្ងៃនឹងទេ យប់ថ្ងៃ៦ ព្រឹកថ្ងៃ៧ចប់ ។

ដានី ៖ កាលពីមុនៗមក អត់ដែលបានប្រយុទ្ធគ្នាអីទេ?

សាវ៉ាត់ ៖ អត់ទេ ។

ដានី ៖ ពួកដ្ឋាច់មីន ពួកសំអាត់មីងអី ក៏មិនដែលបាន?

សាវ៉ាត់ ៖ អត់ទេ ដល់គេវាយចូលទ្រង់ទ្រាយធំហើយបានយើងដឹងខ្លួនថា តូចចិត្ត ប៉ុនពេលនោះគេក៏អត់ធ្វើដែលសកម្មភាពខាងទឹក គេធ្វើតែសកម្មភាពស៊ើបការណ៍តិចតួចៗ ហើយគេភាគ

ច្រើនគេប្រយុទ្ធថ្ងៃ៥ ថ្ងៃ៦នឹង ដោយសារភ្នំពេញ នេះហើយបានគេយកនាវាឡើង កាន់កាប់ខាងទឹកណា ។

ដានី : កន្លែងនេះ ដូចថាកាលនឹងចូលពី១៨០នឹងមានបញ្ជូនពួកបូកាំ៧០០ ពួកខាងយើង៧០០ ចូលគ្នា ចុះពួកនឹងរហូត នៅរហូតដែលប្រយ៉ាងម៉េច?

សារ៉ាត់ : នៅរហូត ។

ដានី : ចុះឪមគេបញ្ជូនទៅវាយព្រំដែនដែរ ហើយក៏?

សារ៉ាត់ : ទៅៗព្រំដែន ។

ដានី : គាត់ទៅពេលណាដែរ?

សារ៉ាត់ : ទៅក្នុងចន្លោះមុន បងមុត ។

ដានី : ម៉េចបានគេបញ្ជូនគាត់ទៅមុន?

សារ៉ាត់ : ព្រោះបញ្ហាការយោធា ត្រូវមានជំហានមុន ។

ដានី : ទៅឆ្នាំណា ទៅពេលណា?

សារ៉ាត់ : ក្នុងសង្គ្រាមព្រំដែនថាទុំទៅហើយ វាវាយមកបារិកក៏ចូល វាយផ្លូវលេខ២ក៏ចូលមកហើយ បានបងឪមគាត់ទៅ ។

ដានី : ចុះកម្លាំង៧០០ផ្សេងទៀត?

សារ៉ាត់ : អានឹងយើងត្រៀមបំរុងគឺថា នាវាយើងមិនអាចមិនមានការប៉ុននឹងទេ ត្រូវការទុំនឹងដូច្នេះ វាមានកងនាវានឹងវារហូតដល់កងនឹង វាទៅជាកងពលជើងទឹកមួយ ។

ដានី : ខ្លាចជាកងពលទៀត?

សារ៉ាត់ : បាទ!

ដានី : កងពលតូច?

សារ៉ាត់ : បាទ!កងពលជើងទឹកក្នុងដែនសមុទ្ររបស់យើងរៀបមួយ រៀបចំមួយកងពល អានេះ ដោយមានគេហៅថាក្របខ័ណ្ឌរបស់វាគឺថា ៣វរសេនាធំពេញអគ្គជានាវា ។

ដានី : តែគ្រងគ្រប់គ្រងរបស់ពីណាគេ?

សារ៉ាត់ : អានឹង អនាគតទៅវាក្រោមកការគ្រប់គ្រងរបស់សេនាធិការ អានឹងវានេះអញ្ជើងកងពល ឡើងទៅសេនាធិការវិញ ។

ដានី : ប៉ុន្តែមិនទាន់បាន?

សារ៉ាត់ : អត់ទេ អត់ទាន់មានទេ គំរោងការមនុស្សនឹងត្រៀមបំរុងអានឹង ៧០០នាក់ប៉ូក៧០០នឹងត្រៀមបំរុងអានឹង ។

ដានី : ប្រុងត្រៀមបំរុងបង្កើត១កងពលៗមួយផ្សេងដាច់ពីកងពល១៦៤?

សារ៉ាត់ : បាទ!

ដានី : ប៉ុន្តែការងារនឹងមិនទាន់បានសម្រេច មិនទាន់បានបង្កើតជាកងពលនៅឡើយទេ?

សារ៉ាត់ : មិនមាន ។

ដានី : ចុះពួកបូព៌ាអីនឹងនៅធ្វើការរហូតបែក៧៩?

សារ៉ាត់ : បាទ!៧៩ ។

ដានី : បើអ៊ីចឹង គេដកទៅព្រំដែនមុនគាមុតទៀត?

សារ៉ាត់ : ធ្វើការព្រំដែនមិនអនុគ្រោះ ត្រូវយកបញ្ហាការមិនមានភូមិសាស្ត្រច្បាស់លាស់ខាងណាៗឲ្យច្បាស់ ។

ដានី : ចុះព្រឹត្តិការណ៍ម៉ាយេហ្គេសនឹងឆ្នាំណាទៅ?

សារ៉ាត់ : ៧៥ ខែ៥ ថ្ងៃ១៧ មេសា៧៥ ។

ដានី : បើយើងបែកភ្នំពេញថ្ងៃ១៧ មេសា ឆ្នាំ៧៥?

សារ៉ាត់ : បាទ!

ដានី : ចុះព្រឹត្តិការណ៍ម៉ាយេហ្គេសនឹង?

សារ៉ាត់ : ម៉ាយេហ្គេសនឹង ក្រោយនឹងក្នុងរដូវវស្សាមាត់សមុទ្រ វាប្រហែលជាខែនឹងដែរ ក្នុងចន្លោះខែ៦នឹងដែរៗឬដើមខែ៦ ម៉ាយេហ្គេសចូលមក ។

ដានី : ចូលមកយ៉ាងម៉េច មានព្រឹត្តិការណ៍ចូលមក?

សារ៉ាត់ : ព្រឹត្តិការណ៍ម៉ាយេហ្គេស វាចូលមកក្នុងតំបន់ចន្លោះខាងត្បូងកោះអាគ្នេយ៍ មានកោះមួយហៅកោះអាគ្នេយ៍ ។

ដានី : កោះអាគ្នេយ៍នឹងវានៅជិតកន្លែងណាទៅ?

សារ៉ាត់ : កោះអាគ្នេយ៍នឹងវានៅខាងកើតកោះតាង ។

ដានី : ជិតកោះតាងដែរ?

សារ៉ាត់ : អាគ្នេយ៍កោះ អាគ្នេយ៍របស់កោះប៉ូឡូវៃ ហើយក៏អី!ឥសានរបស់ប៉ូឡូវៃ អាគ្នេយ៍របស់កោះតាង ។

ដានី : អញ្ចឹងម៉ាយេហ្គេសនឹងវានៅម្តុំណា?

សារ៉ាត់ ៖ គេៗ ទៅឃាត់អីពួកPGFទេ ខ្ញុំអត់ដឹងទេ ព្រោះពេលនឹងអត់ទាន់មាននាវាទេ ខ្ញុំគ្រាន់តែនៅក្នុងក្របខ័ណ្ឌ ខ្ញុំអត់ទាន់ចូលកង១៨០ផង នៅនេះនៅធ្វើស្រែនៅកងកេង ។

ដានី ៖ នៅកងកេងនៅឡើយទេ ពេលនឹង?

សារ៉ាត់ ៖ បាទ!គ្រាន់ថាព្រឹត្តិការណ៍ម៉ាយេហ្គេសនឹង ម៉េចបានខ្ញុំដឹង ដឹងគ្រាន់ថាយន្តហោះទម្លាក់ៗ ហើយវិទ្យុប្រកាស វិទ្យុអាមេរិចក៏ប្រកាស វិទ្យុកម្ពុជាប្រជាធិបតេយ្យក៏ប្រកាស ហើយអាមេរិចវាសំលុតថាឲ្យដោះលែងនាវាវាភ្លាម បើមិនទេ គឺថាវានឹងប្រើដោយអំណាចយោធារបស់អាមេរិចកំទេសកម្ពុជាទាំងមូល ពេលនឹងណា ។

ដានី ៖ កាលនឹងវិទ្យុអាមេរិចប្រកាស វិទ្យុយ៉ាងម៉េច យើងស្តាប់វិទ្យុអាមេរិចម៉ង ហើយយ៉ាងម៉េច?

សារ៉ាត់ ៖ ខ្ញុំស្តាប់ ខ្ញុំមានវិទ្យុសម្រាប់តាមដានសភាពការណ៍សកលលោកដែរ ។

ដានី ៖ គេឲ្យយើងស្តាប់ដែរ?

សារ៉ាត់ ៖ ស្តាប់ពត៌មាន ។

ដានី ៖ ចុះចន្លោះពូធ្វើការនៅកង១៨០ ក្នុងចន្លោះ៣ឆ្នាំ ពូអាចស្តាប់ប៉ុស្តិ៍អាមេរិចបានដែរ?

សារ៉ាត់ ៖ បានទាំងអស់ ប៉ុស្តិ៍យួននិយាយខ្មែរក៏ខ្ញុំស្តាប់ យួនបង្កើតរណសិរ្សដោយមាន ហេង សំរិន ជាប្រធានអីខ្ញុំស្តាប់បានទាំងអស់ ។

ដានី ៖ ពេលពូស្តាប់អញ្ចឹង គេខាងកងពល ខាងអីគេអត់ថាអីទេ?

សារ៉ាត់ ៖ អត់ទេ ។

ដានី ៖ ប៉ុន្តែយើងប្រាប់ថាយើងបានស្តាប់ប៉ុស្តិ៍អីអញ្ចឹងអត់?

សារ៉ាត់ ៖ ប្រាប់ យុទ្ធជនក្នុងនឹងក៏ស្តាប់ៗដើម្បីដឹង ។

ដានី ៖ ស្តាប់ទៅ កាលពេលយើងស្តាប់ពត៌មានផ្សេងៗយើងមានអារម្មណ៍ម៉េច?

សារ៉ាត់ ៖ អារម្មណ៍មិនមានអីទេ នៅកម្ពុជាយើងអសន្តិសុខ បរទេស មានអំណាច មានការឈ្លានពានលុកលុយអីអញ្ចឹង រឿងវាប៉ុននឹងទេ ។

ដានី ៖ អាមេរិចគេប្រកាសអញ្ចឹងម៉ង បើថាយើងមិនដោះលែងនាវាគេទេ គេកំទេចកម្ពុជាទាំងមូលម៉ង?

សារ៉ាត់ ៖ បាទ!បើកគំរាមខាងយោធា ។

ដានី ៖ ពេលនឹងពូស្តាប់ពេលណា?

សាវ៉ាត់ ៖ ស្តាប់ពេលដែលព្រឹត្តិការណ៍ទម្លាក់យន្តហោះហើយ ពេលយប់ម៉ោង៨កន្លះ ប៉ុនក្រោយពីទម្លាក់យន្តហោះហើយ យើងក៏ឲ្យម៉ាយេហ្គេសគេចេញ ។ ខ្ញុំនិយាយថាឈ្មោះកុលនឹងបានទាក់ទងនិយាយភាសាអង់គ្លេសដោយអ្នកឯងត្រូវចេញឲ្យផុតពីដែនទឹក ដែនអីអញ្ចឹងណាកុំឲ្យមានរឿងទៀត ។

ដានី ៖ កុលនឹងអ្នកនិយាយភាសាអង់គ្លេស?

សាវ៉ាត់ ៖ បាទ!

ដានី ៖ កុលនឹងមានតួនាទីម៉េច?

សាវ៉ាត់ ៖ ជាអ្នកបច្ចេកទេសកាន់តេអូ ។

ដានី ៖ អ្នកបច្ចេកទេស កាន់តេអូនៅកន្លែងណា?

សាវ៉ាត់ ៖ កាន់តេអូនៅកន្លែងកងពល ។

ដានី ៖ ចេះអង់គ្លេសតែម្នាក់នឹងទេ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ អ្នកផ្សេងទៀតមានពីណាគេចេះអង់គ្លេសទៀតដែរ?

សាវ៉ាត់ ៖ អត់ទេមិនឆាយមាន ។

ដានី ៖ ចុះកុលនឹងយ៉ាងម៉េចដែរ កុលនឹងក្រោយមក?

សាវ៉ាត់ ៖ ក្រោយមក គាត់នៅនឹងតើ ។

ដានី ៖ គាត់នៅកន្លែងកងពលរហូត?

សាវ៉ាត់ ៖ បាទ!ដល់៧៩ដឹងយ៉ាងណា បានបែកគ្នា ។

ដានី ៖ បែកគ្នាឆ្នាំ៧៩?

សាវ៉ាត់ ៖ បាទ! ពេលដែលយើងធ្វើដំណើរមកលិច ។

ដានី ៖ មានដែលជួបគាត់ មានដែលដឹងដំណឹងពីគាត់?

សាវ៉ាត់ ៖ អត់ ។

ដានី ៖ មិនដែលដឹងថាគាត់មក?

សាវ៉ាត់ ៖ អត់ ព្រោះមនុស្សពេលនឹង គឺថារៀបចំអត់មានទេ ប្រព័ន្ធខ្សែចាត់គឺដាច់ អ៊ីដែលរស់បានលុះត្រាតែរស់ដោយខ្លួនឯង ៧៩ ហើយបើមិនជឿខ្ញុំសួរអ្នកទាំងអស់គ្នាដែលរស់នៅ គ្មានការចាត់តាំងទៀតទេ គឺដាច់ទាំងអស់ ។

ដានី ៖ ចុះកាលនឹងគាត់ជាមនុស្សយ៉ាងម៉េច បានគាត់ចេះភាសាអង់គ្លេស?

សារ៉ាត់ ៖ គាត់ជានិស្សិត រៀនយើងពីដើមបាក់ឌុប ។

ដានី ៖ ចុះនិស្សិតអញ្ចឹងម៉េចបានគេឲ្យគាត់ចូលធ្វើកងទ័ព?

សារ៉ាត់ ៖ នេះជាជំនាញរបស់គាត់ មានទេពកោសល្យរបស់គាត់ គាត់មានប្រជាប្រិយភាពខាងការរស់នៅ ដូច្នេះមានប្រជាប្រិយភាពអញ្ចឹងម៉្យាង ។ ប៉ុនម៉្យាងមនុស្សដែលគេចេះអញ្ចឹងត្រូវតែប្រើ ហើយក៏មិនមែនប្រើក្នុងនាមគេជាខ្ញុំកញ្ជះដែរ ជាមនុស្សស្មើភាព អត់មានមើលងាយ មើលថោកគាត់បានទេ ។

ដានី ៖ កាលនោះឈ្មោះគាត់ពេញឈ្មោះម៉េចទៅ?

សារ៉ាត់ ៖ ខ្ញុំចាំតែឈ្មោះគាត់តែប៉ុននឹង ឈ្មោះភោគ កុលៗ ។

ដានី ៖ ភោគ កុល គាត់ជាតួនាទីគាត់?

សារ៉ាត់ ៖ អ្នកកាន់គេអូ ។

ដានី ៖ អ្នកកាន់គេអូនៅ?

សារ៉ាត់ ៖ កន្លែងទីបញ្ជាការកងពល ។

ដានី ៖ គាត់នៅកន្លែងតាមុតផ្ទាល់ម៉ង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ពូម៉េចដឹងថាគាត់ចេះអង់គ្លេស?

សារ៉ាត់ ៖ ព្រោះខ្ញុំធ្លាប់ជួប ព្រោះធម្មតាមនុស្សស្រុកភូមិឃុំជាមួយគ្នា ។

ដានី ៖ កុលនឹង គាត់នៅណាទៅ?

សារ៉ាត់ ៖ នៅភូមិទន្លេនាង ។

ដានី ៖ ឃុំ?

សារ៉ាត់ ៖ ឃុំសំឡាញ ។

ដានី ៖ ស្រុក?

សារ៉ាត់ ៖ ស្រុកអង្គរជ័យ ខេត្តកំពត ។

ដានី ៖ ភោគ កុលគាត់?

សារ៉ាត់ ៖ បាទ!

ដានី ៖ ភោគ កុល ភូមិទន្លេនាង ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ។ អានឹងស្រុកកំណើតគាត់ពូស្គាល់ច្បាស់អញ្ចឹងម៉ង?

សារ៉ាត់ ៖ បាទ!ប៉ុនឪពុកម្ដាយគាត់ ខ្ញុំអត់ស្គាល់ ។

ដានី ៖ ឪពុកម្តាយគាត់អត់ស្គាល់?

សារ៉ាត់ ៖ ពេលដែលខ្ញុំស្គាល់គាត់ ស្គាល់ពេលដែលមកនៅកងពល ។

ដានី ៖ ពូម៉េចដឹង បានដឹងថាគាត់នៅខាងទន្លេនាង?

សារ៉ាត់ ៖ បាទ!សួរសំនេះសំនាល ។

ដានី ៖ ហើយដឹងថាគាត់ចេះអង់គ្លេសនឹង ដឹងតាមម៉េចទៅ?

សារ៉ាត់ ៖ ដឹងតាមរយៈប្រវត្តិរបស់គាត់ដែល គាត់រៀនៗជាមួយបងខ្ញុំអីនឹង ស្គាំតាមរយៈនឹង ។

ដានី ៖ អញ្ចឹងគាត់ចូលធ្វើកងទ័ព ចូលអីនឹងតាំងពីអង្កាល់?

សារ៉ាត់ ៖ ឆ្នាំ៧០ដែរ ។

ដានី ៖ ចូលតាំងពីឆ្នាំ៧០ដែរ គាត់ចេះអង់គ្លេសពីអង្កាល់?

សារ៉ាត់ ៖ គាត់ចេះ ពេលដែលគាត់រៀនជានិស្សិត ។

ដានី ៖ គាត់រៀននិស្សិត តាំងពីមុនឆ្នាំ៧០ទៀត?

សារ៉ាត់ ៖ បាទ!៧០ ៦៩ បាក់ឌុប គាត់បាក់ឌុប៦៩ ហើយមក៧០រដ្ឋប្រហារ ហើយបាក់ឌុប ពេលនឹង បានខ្ពស់ ។

ដានី ៖ បែកឆ្នាំ៧៩?

សារ៉ាត់ ៖ បាទ!

ដានី ៖ គាត់មានប្រពន្ធមានកូនដែលអត់?

សារ៉ាត់ ៖ នៅទេ ជាយុវជន ។

ដានី ៖ អញ្ចឹងគាត់នៅកាន់ខាងគេអូរហូតដល់បែកឆ្នាំ៧៩?

សារ៉ាត់ ៖ បាទ!

ដានី ៖ នៅក្នុងកន្លែងកងពលនឹង អ្នកចេះអង់គ្លេសមានតែគាត់ម្នាក់?

សារ៉ាត់ ៖ មានអ្នកផ្សេងចេះដែរ តែការប្រើប្រាស់នៅតិចតួច ជំនាញ់ ព្រោះធម្មតាកាលណាចេះ ហើយបើមិនហ្វឹកហ្វឺនអត់កើតទេ ។

ដានី ៖ ចុះមានពូឈ្មោះផល ហើយមានស្អីផ្សេងទៀតដែរអត់?

សារ៉ាត់ ៖ ផលនៅកងពលនឹងអត់មាន ។

ដានី ៖ ចុះនារសារបស់កងពលអី មានគេឈ្មោះអីខ្លះទៅ?

សារ៉ាត់ ៖ ដូចមានតែឈ្មោះអៀង ឈ្មោះ ង៉ៃ ប៉ុនគាត់ស្លាប់ហើយ ។

**កាសែតទី៣ ផ្នែក«ខ»**

ដានី ៖ ចុះនារសាកងពលដែលនៅរស់ ពូមានដឹងពីណាគេ កាលជំនាន់៣ឆ្នាំ?

សារ៉ាត់ ៖ ជំនាន់៣ឆ្នាំៗដូចមិនមាន អានក៏ស្លាប់ អៀងក៏ស្លាប់ អាងៃក៏ស្លាប់តាមព្រំដែននេះ អៀង គាត់ស្លាប់តាំងពីយួនចូលមក ។

ដានី ៖ អៀង ងៃ ២នាក់នឹង?

សារ៉ាត់ ៖ អាន ។

ដានី ៖ អៀង អានទៀត ស្លាប់នៅព្រំដែន ។ ចុះអ្នកនៅរស់?

សារ៉ាត់ ៖ អ្នកនៅរស់មានច្រើន តែខ្ញុំចាំមិនអស់ គ្រាន់តែឃើញដើរជិតៗគាត់នឹង គាត់ទៅអញ្ជើងទៅ ងៃបើកឡានអញ្ជើង ។

ដានី ៖ ដឹងថាអ្នកដើរជិតៗគាត់ហើយនៅរស់ សព្វថ្ងៃនៅរស់អី ចង់ទៅជួបគាត់ដែរ?

សារ៉ាត់ ៖ អត់និយាយ ។

ដានី ៖ ខ្ញុំចង់ដឹងពីរចនានៅក្នុងកន្លែងកងពលណា?

សារ៉ាត់ ៖ បាទ!អត់មាននៅទេ ភាគច្រើន ខ្ញុំចាំមិនច្បាស់ថា ។

គី ៖ ភាគច្រើនក្មេង?

សារ៉ាត់ ៖ បាទ! ហើយមកដល់ថ្ងៃនេះ ខ្ញុំចាំច្បាស់តែ៣នាក់នឹង តែស្លាប់ហើយ ។

ដានី ៖ ស្លាប់ទាំង៣ម៉ង?

សារ៉ាត់ ៖ ព្រោះធម្មតាក្រៅពីនឹង វាគ្រាន់តែជាជំនាញ វាអត់យើងវា ។

ដានី ៖ ចុះដូចថាក្នុងកន្លែងកងពលនឹងមានគេអ្នកកត់អីយ៉ាងម៉េច មាន ពូមានស្គាល់មានអី នៅរស់ អី?

សារ៉ាត់ ៖ អត់ៗមាន ជាស្លាប់ ។

ដានី ៖ ឈ្មោះអីគេ?

សារ៉ាត់ ៖ ជា ។

ដានី ៖ ជានឹងគាត់ធ្វើអីគេ?

សារ៉ាត់ ៖ ជំនួយដែរ ។

ដានី ៖ ជំនួយការកងពល?

សារ៉ាត់ ៖ មិត្តភ័ក្តទើបនឹងមក ។

ដានី ៖ ពូនឹកគិតទៀតមើល ក្រៅងលរមានអ្នកនៅរស់អីនៅខាងកងពល?

សារ៉ាត់ ៖ មានអាផ្ដាច់ពីមុន បាត់សូន្យណា ។

ដានី ៖ មានខាងយើងអីនឹង ក្រែងលរម្ពុំៗ?

សាវ៉ាត់ ៖ មានក្រោមៗ ។

ដានី ៖ ដីក្រោយគាត់ធ្វើក្នុងជំនាន់នឹងដែរ?

សាវ៉ាត់ ៖ សម័យយើងដែរ ។

ដានី ៖ កាលសម័យនោះ សម័យនៅកាលនៅ?

សាវ៉ាត់ ៖ សម័យ៣ឆ្នាំអស់ម៉ង ។

ដានី ៖ ពូបកអាកន្លែងម៉ាយេហ្គេសវិញបន្តិច អាកន្លែងពេលដែលពូនៅកន្លែងកងកេងៗនឹង ពេលនឹងគេចាប់ម៉ាយេហ្គេសនឹង គេចាប់នៅកន្លែងណាទៅ?

សាវ៉ាត់ ៖ នៅអាចន្លោះកោះអាគ្មេយ៍ និងកោះប៉ូឡូវៃ ។

ដានី ៖ ប៉ុនគេអត់មានយកមកអាកន្លែងកោះប៉ូឡូវៃ?

សាវ៉ាត់ ៖ អត់ ។

ដានី ៖ គេចាប់ចតចោលនឹងទៅ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ពូមើលពីខាងកងកេង មើលឃើញដែរអត់?

សាវ៉ាត់ ៖ អត់ទេ ឆ្ងាយមើលឃើញម៉េច ។

ដានី ៖ ពូមានបានមើលឃើញអត់?

សាវ៉ាត់ ៖ អត់ទេ ។

ដានី ៖ ចុះម៉េចបានពូដឹងថាគេចតនៅកន្លែងកោះអាគ្មេយ៍?

សាវ៉ាត់ ៖ ជាការស្តាប់វិទ្យុនោះ ស្តាប់វិទ្យុរបស់នេះ តាខៀវ សំផន គាត់ប្រកាស កាលនឹងគាត់មិនប្រមុខរដ្ឋ គាត់ប្រកាស ។

ដានី ៖ អ៊ំខៀវ សំផន គាត់ប្រកាសថាម៉េចទៅ?

សាវ៉ាត់ ៖ គាត់ប្រកាសឲ្យការរំលោភអធិបតេយ្យរបស់អាមេរិចដែលចូលមកប៉ះពាល់លើដែនទឹក ដែនសមុទ្រកម្ពុជានឹង អាមេរិចវាចេះការរំលោភច្បាប់អន្តរជាតិនឹង ដែលច្បាប់អន្តរជាតិគេហាមឃាត់ហើយវាមករំលោភ នេះត្រូវតែឃាត់ ។ ឃាត់ហើយអាមេរិចវាយខាងយោធាគាម ហើយការពិតអាមេរិចវាឆ្លើយថាខ្លួនវាជាមនុស្សវង្វេងអី យើងមិនអាចទទួលទេ ។

ដានី ៖ គាត់ថាអញ្ចឹង?

សាវ៉ាត់ ៖ បាទ!ធម្មតាប្រទេស ប៉ុនអាមេរិចអ្នកបើកបរអាមេរិចមិនអាចមកវង្វេងសមុទ្រកម្ពុជាទេ ។

ដានី ៖ គាត់ថាអញ្ចឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ គាត់ប្រកាសថ្ងៃណា ពូចាំថ្ងៃខែទេ?

សារ៉ាត់ ៖ ថ្ងៃដែលយើងឃាត់ ប្រតិកម្មរបស់អាមេរិច និងយើងឆ្លើយឆ្លងគ្នាភ្លាម ប្រធានាធិបតីអាមេរិចនិង ប្រមុខរដ្ឋ ។

ដានី ៖ កាលនឹងប្រធានាធិបតីអាមេរិចឈ្មោះអីទៅ?

សារ៉ាត់ ៖ ដូចជាខាត់ទ័រ ។

ដានី ៖ ជីវនីខាត់ទ័រ ហើយស្អីគេ?

សារ៉ាត់ ៖ .... ដូចក្រោយទេ ជីវនីខាត់ទ័រហើយ ដូចជីនាល់ហ៊ុំរ ។

ដានី ៖ ជីនាល់ហ៊ុំរ?

សារ៉ាត់ ៖ អឺ!ប្រហែលជាជីនាល់ហ៊ុំរ ហ្នឹងហើយមិនមែនខាត់ទ័រទេ ខាត់ទ័រអាណត្តិក្រោយ ព្រោះយើង ។

ដានី ៖ កាលនឹងជីនាល់ហ៊ុំរនឹង គាត់និយាយថាម៉េច?

សារ៉ាត់ ៖ អឺ!ជាពត៌មានទេ គាត់មិនបានចេញសម្តីក្នុងVOAទេណា វាជាសារពត៌មានរបស់មាយ ចនរបស់អីដែលគេនិយាយ ។

ដានី ៖ បាទ!គេនិយាយថាម៉េច?

សារ៉ាត់ ៖ គេនិយាយថា វាជាការភ័ន្តច្រឡំរបស់កាពីទែន និងប្រធាននាវាបើកបរនឹង ចូលទៅប៉ះពាល់អធិបតេយ្យរបស់កម្ពុជាអីអញ្ចឹង នេះគេត្រូវឲ្យកម្ពុជាប្រជាធិបតេយ្យលែងនាវាគេមកពេញដោយសុវត្ថិភាពដល់ ។

ដានី ៖ អញ្ចឹងកាលចាប់នាវានឹង ចាប់បានរយៈពេលប៉ុន្មាន បានគេលែង?

សារ៉ាត់ ៖ អត់យូរទេ ។

ដានី ៖ ប្រហែល?

សារ៉ាត់ ៖ ខ្ញុំមិនហួស ដូចប៉ុន្មានប្រមាណដូចហួស១២ម៉ោង ។

ដានី ៖ ចាប់អត់ហួស១២ម៉ោង?

សារ៉ាត់ ៖ បាទ!អត់ហួស ។

ដានី ៖ ចុះមានដូចថាមានការមកទម្លាក់គ្រាប់បែកនៅកងកេង មកទម្លាក់នៅកំពង់សោមនឹង ទម្លាក់ពេលណា?

សាវ៉ាត់ ៖ ពត៌មាននឹងពេលព្រឹក ទម្លាក់ម៉ោង២រសៀល អឺ!ម៉ោងពេលព្រឹកយើងយាត់ខ្លួន ហើយដល់ពេលម៉ោង៩ព្រឹកយន្តហោះមកដល់ម៉ង់ ។

ដានី ៖ យើងយាត់ខ្លួនម៉ោងប៉ុន្មាន?

សាវ៉ាត់ ៖ មិនដឹងជាពីយប់ថ្ងៃរសៀលឬយ៉ាងម៉េច ប៉ុនខ្ញុំមកឃើញជួបព្រឹត្តិការណ៍ ដល់ឃើញព្រឹត្តិការណ៍យន្តហោះទម្លាក់បានខ្ញុំតាមដានវិទ្យុមិនអញ្ចឹង ដឹងពត៌មានអីៗអញ្ចឹងទៅ ហើយយើងស្តាប់ម្ខាងនេះប្រកាសមុន ។

ដានី ៖ ខាងអ៊ំខៀវ សំផន គាត់ប្រកាសមុន?

សាវ៉ាត់ ៖ បាទ!ហើយដល់យប់បានយើងស្តាប់VOA ។

ដានី ៖ យប់បានស្តាប់យើងVOA?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ដល់ពេលVOAប្រកាស ដល់ពេលស្អែកឡើងព្រលឹមឡើងគេទម្លាក់បណ្តោយហើយក៏ទម្លាក់ក្រោយ ឬមុន?

សាវ៉ាត់ ៖ ហ្នឹងហើយម៉ោង៩ព្រឹក ដាក់ត្រឹមម៉ង់ ។

ដានី ៖ អញ្ចឹងដល់ពេលគេទម្លាក់នឹង ទម្លាក់រយៈពេលប៉ុន្មានទៅ?

សាវ៉ាត់ ៖ ឆាប់ដែរ ហើយនាវានឹងក៏ស្ងាត់ទៅ ស្ងាត់អានេះនឹងបានចប់ វាគ្រាន់តែជាព្រឹត្តិការណ៍ ។

ដានី ៖ ទម្លាក់នៅកន្លែងណាខ្លះ បើតាមពូដឹង?

សាវ៉ាត់ ៖ នៅកំពង់ផែ កំពង់សោមនោះ នៅចំណោទសេអ៊ី នៅព្រលានយន្តហោះនៅកងកេង ។

ដានី ៖ ចំណោទសេអ៊ី នៅរាម នៅកងកេង?

សាវ៉ាត់ ៖ នៅរាម ឆ្នេរសមុទ្រតែម្តុំនឹងទេ វាអត់ទម្លាក់ទៅកំពតទៅអី ។

ដានី ៖ ទម្លាក់រយៈពេលប៉ុន្មានទៅ រយៈពេល តែមួយភ្លែតនឹង ឬក៏២ ៣ថ្ងៃ ឬក៏?

សាវ៉ាត់ ៖ អត់ទេ តែប៉ុន្មានម៉ោងទេ មិនច្រើនទេ ។

ដានី ៖ ពេលទម្លាក់នឹងមានត្រូវដែរអត់?

សាវ៉ាត់ ៖ វាប៉ះពាល់សម្ភារៈ ។

ដានី ៖ មានជីវិតមនុស្សអីមានអត់?

សាវ៉ាត់ ៖ មាន ។

ដានី ៖ កាលនឹងមានរបាយការណ៍ថាស្លាប់អីប៉ុន្មានដែរ?

សាវ៉ាត់ ៖ ខ្ញុំអត់ចាំៗ ព្រោះវាខ្ញុំវាអត់មានមកកំពង់សោមណាខ្ញុំនៅព្រលានយន្តហោះ ទៅកងកេងអី អត់មានទេ វាអត់ប៉ះពាល់ទេ វាទម្លាក់ចំព្រលានអត់ត្រូវណាទេ ។

ដានី ៖ ទម្លាក់ម៉ោង៩ព្រឹក?

សាវ៉ាត់ ៖ បាទ! ម៉ោង៩ ម៉ោង១០ រយៈពេលនឹងវាគូន់F505 និងF100 ។

ដានី ៖ ទម្លាក់នៅចំណតរាម នៅកងកេង ហើយនិងកំពង់ផែនកំពង់សោម ពកន្លែងនឹងទេ?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ចុះពេលទម្លាក់ហើយ ពេលមានប្រតិកម្ម?

សាវ៉ាត់ ៖ ពេលនឹងវាមិនមែនទម្លាក់តែនឹងទេ កោះក៏វាវាយដែរ យន្តហោះវាយ ។

ដានី ៖ វាវាយទាំងកោះដែរ?

សាវ៉ាត់ ៖ វាយកោះដែរ កោះតាង កោះប៉ូឡូវៃអីវាយទាំងអស់ យកយន្តហោះខ្ទម្ភាចក្រុមកបាញ់ រះគំរាមនៅលើកោះនឹងម៉ង ហើយពួកនឹងតវិញ មានធ្លាក់យន្តហោះ ធ្លាក់អីនឹង ។

ដានី ៖ មានធ្លាក់យន្តហោះដែរ?

សាវ៉ាត់ ៖ ធ្លាក់ ។

ដានី ៖ ធ្លាក់ប៉ុន្មានគ្រឿង?

សាវ៉ាត់ ៖ តាមពុទ្ធិយាយពត៏មានថាដូចធ្លាក់២ ។

ដានី ៖ ធ្លាក់២គ្រឿង?

សាវ៉ាត់ ៖ បាទ!

ដានី ៖ ខាងណាអ្នកបាញ់កាលនឹង?

សាវ៉ាត់ ៖ ពួកនៅកោះ ។

ដានី ៖ ពួកកោះ ពូស្គាល់ដែលអ្នកដែលបាញ់?

សាវ៉ាត់ ៖ អត់ គ្រាន់ដឹងថាកម្លាំងនៅកោះអ្នកបាញ់ ។

ដានី ៖ កម្លាំងអ្នកកោះនឹង កម្លាំងខាងអី?

សាវ៉ាត់ ៖ ៦៣ នៅកោះតាង កងចាយ កាលមុនអ្នកនាំពួកអាមេរិចអីទៅរក កងចាយនឹងអ្នកនាំ បាញ់ ។

ដានី ៖ កងចាយនឹងអ្នកនាំបាញ់?

សាវ៉ាត់ ៖ កងចាយនឹង គាត់អនុសេនាធំ ដូច្នេះគាត់នៅប្រយុទ្ធនៅនឹង កាំភ្លើងអីគាត់បាញ់ទម្លាក់ យន្តហោះ ។

ដានី ៖ គាត់នៅកោះនឹងម៉ង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះក្រៅពីកងចាយ ពីណានៅលើកោះនឹង បើកងចាយទៅបាត់ហើយ?

សារ៉ាត់ ៖ វាបែកគ្នាអស់ហើយ បើខ្ញុំចាំមិនបាន ។

ដានី ៖ ថាធ្លាក់យន្តហោះ២ ថាស្លាប់ពួកអាមេរិចដែរ?

សារ៉ាត់ ៖ បាទ!មានស្លាប់ ។

ដានី ៖ ប៉ុន្តែពូអត់ដឹងទេ?

សារ៉ាត់ ៖ អត់ទេ ខ្ញុំនៅគោកនេះ ប៉ុនយន្តហោះឲ្យឃើញណា វាហោះ ឃើញឆ្វេលមកលើយើងអី ឃើញទទ្ធម្កាចក្រ ឃើញយន្តហោះធូនប្រយុទ្ធធ្ងន់អីនឹងឃើញទាំងអស់អត់ឃើញតែនាវា ។

ដានី ៖ ចុះកាលនឹងមានខាងកងពលអី ឲ្យយើងមានគ្រឿមអីដើម្បីប្រយុទ្ធដែរអត់?

សារ៉ាត់ ៖ គ្រឿមៗប្រយុទ្ធកម្ចាំងឡើងគោករបស់នាវាអាមេរិច បុកទូក ។

ដានី ៖ ប៉ុន្តែអត់មាន អត់បានប្រយុទ្ធទេ?

សារ៉ាត់ ៖ អត់ទេ ថ្មើរជើងៗបានប្រយុទ្ធតែយន្តហោះដាក់ទ័ពនៅកោះតាង ។

ដានី ៖ កាលនឹងខាងយើងស្លាប់ច្រើនដែរអត់ នៅកោះតាង?

សារ៉ាត់ ៖ មិនដឹងប៉ុន្មានទេ ខ្ញុំចាំមិនបានទេ ។

ដានី ៖ ការប្រយុទ្ធគ្នានៅកោះតាង កាលទម្លាក់គ្រាប់បែកនឹងប៉ុន្មានថ្ងៃមើលទៅ?

សារ៉ាត់ ៖ ដូចជាមុនៗទម្លាក់កំពង់សោម ។

ដានី ៖ មុនទម្លាក់កំពង់សោមទៀត?

សារ៉ាត់ ៖ បាទ!មុនទម្លាក់កំពង់សោម ។

ដានី ៖ ពូអត់បានឃើញកាប៉ាល់ម៉ាយ៉េហ្គេសនឹងទេ?

សារ៉ាត់ ៖ អត់ទេ ខ្ញុំអត់ឃើញ ។

ដានី ៖ ចុះពួកថា ពេលនឹងពួកទាហានអី ពួកអាមេរិចអីមានគេចាប់មកខាងកងពលដែរអត់?

សារ៉ាត់ ៖ ទាហានអាមេរិច អត់ទេ អត់មាន ។

ដានី ៖ ចុះក្រោយពីទម្លាក់គ្រាប់បែក មានប្រតិកម្មអីពីខាងដូចថាកម្ពុជាប្រជាធិបតេយ្យ ដូចថាអ៊ីឡៀវ សំផន អាមេរិចអីមានបិទប្រកាសអីតទៅទៀតដែរ បន្ទាប់ពីៗទម្លាក់គ្រាប់បែក បន្ទាប់ពីវាយអីនឹង?

សារ៉ាត់ ៖ អានឹងវាស្ងាត់រហូតតទៅ ។

ដានី ៖ កាប៉ាល់នឹងក៏លែងឃើញ លែងមានពត៌មានអីទៀតហើយ?

សារ៉ាត់ ៖ បាទ!កាលជ្រៀតជ្រែករបស់កាប៉ាល់តូចតាចអីក៏មិនដែលឃើញ ។

ដានី ៖ ពូស្គាល់ខៀវ សំផននឹងតាំងពីអង្កាល់?

សារ៉ាត់ ៖ ខ្ញុំស្គាល់នឹង ស្គាល់គាត់ជាត់ស្តែង ជាប់ការងារអីស្គាល់គាត់ច្បាស់នៅតំបន់យើង ។

ដានី ៖ ចុះកាលជិតនាំ៣ឆ្នាំ ពូ?

សារ៉ាត់ ៖ ៣ឆ្នាំ ខ្ញុំឃើញតែរូបទេ គេហៅគាត់មកថ្លែងការណ៍អញ្ចឹង មើលទៅកៅអីយើងទៅវេទិការ ទេ ។

ដានី ៖ ដឹងថាគាត់ជាប្រធានអីគេ?

សារ៉ាត់ ៖ ប្រធានរដ្ឋ ។

ដានី ៖ ចុះអ្នកផ្សេងទៀត?

សារ៉ាត់ ៖ អ្នកផ្សេងទៀត ខ្ញុំស្គាល់ប៉ុល ពតអីស្គាល់ ប៉ុនស្គាល់ថាក្នុងក្របខ័ណ្ឌអញ្ចឹង ។

ដានី ៖ គាត់មកថ្លែងការណ៍?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះកាលនឹងពូអត់ទាន់ទៅភ្នំពេញដែរ?

សារ៉ាត់ ៖ ទៅ៧៦ ៧៧ ខ្ញុំទៅ ។

ដានី ៖ កាលជួបគាត់នឹង គាត់ថ្លែងការណ៍ៗនៅភ្នំពេញ ថ្លែងការណ៍នៅណា?

សារ៉ាត់ ៖ គាត់ថ្លែងការណ៍ ពេលគាត់ថ្លែងការណ៍បុណ្យជាតិ ដូចថាបុណ្យប្រកាសឯករាជ្យ១៧មេសា អញ្ចឹងគាត់មក ។

ដានី ៖ ដូចប៉ុល ពត គាត់ក៏មកដែរ?

សារ៉ាត់ ៖ បាទ!មកជា ប៉ុនគាត់ជាអ្នកប្រមុខរដ្ឋ ហើយប៉ុល ពត គាត់ជា ។

ដានី ៖ ជាអីគេ?

សារ៉ាត់ ៖ គាត់ជាការងារខាងផ្ទៃក្នុង ។

ដានី ៖ ក្រៅពីខៀវ សំផន ប៉ុលពត ពីណាគេទៅ?

សារ៉ាត់ ៖ ក្រៅពីអ៊ំខៀវ សំផន, អ៊ំប៉ុល ពត, មានតាម៉ុក, មានសុន សេន, មានអៀង សារី, វន វេត, ចេង ផន, សោ ភឹម, រស់ ញឹម, ស្រី យ៉ាអី ជាដើម ។

ដានី ៖ កាលនឹងពូស្គាល់ដែរអត់?

សារ៉ាត់ ៖ ខ្ញុំអត់ស្គាល់ទេ តែឈ្មោះខ្ញុំទទួលដឹង ប៉ុនមនុស្សដែលខ្ញុំស្គាល់មាន អ៊ីខៀវ សំផន, អ៊ីប៉ុល ពត, តាម៉ុក ។

ដានី ៖ តាម៉ុកស្គាល់ច្បាស់ដែរ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ស្គាល់គាត់តាំងពីអង្គាល់កាលនោះ?

សារ៉ាត់ ៖ តាម៉ុកតាំងពីសង្គ្រាមជាមួយអាមេរិច ឆ្នាំ៧០ ។

ដានី ៖ ធ្លាប់ជួប គាតខសប្បាហ៍?

សារ៉ាត់ ៖ ធ្លាប់ជួប និយាយអី គាត់មានផែនការអី ខ្ញុំប្រាប់ទទួលពីគាត់ ។

ដានី ៖ ចុះដល់ពេល៣ឆ្នាំ ជំនាន់៣ឆ្នាំ ដែលជួបគាត់ទៀតអត់?

សារ៉ាត់ ៖ ៣ឆ្នាំអត់សូវទេ ។

ដានី ៖ ប៉ុន្តែធ្លាប់ជួប?

សារ៉ាត់ ៖ បាទ!គាត់អត់សូវមកខាងជើងទឹកទេ ព្រោះគាត់ជាប់ក្នុងការងារគាត់ ។

ដានី ៖ ចុះពូនៅខាងជើងទឹកអី ដូចថាអ្នកធ្លាប់ធ្វើការជាមួយពូ នៅនាវានៅស្ទឹងអញ្ជឹង ដូចថាធ្លាប់មានគេផ្លាស់គាត់ ហើយបាត់អីដំណឹងអីរហូតដែរអត់?

សារ៉ាត់ ៖ ខាងខ្ញុំផ្នែកខាងនាវាមិនមានផង ។

ដានី ៖ អត់មានផ្លាស់ទៅណា ហើយបាត់អីទេ?

សារ៉ាត់ ៖ បាទ!ឧទាហរណ៍ដូចនែក! ណាំ ឡូនដូចអីនឹង តែជួបៗគ្នារហូតមកអញ្ជឹងទៅ ដល់បែកៗគ្នាដោយសភាពការណ៍នីមួយៗ ។

ដានី ៖ ចុះជំនាន់នឹង ដូចថាពូនៅនាវានៅខាងកាប៉ាល់ នៅខាងអីនឹង ពូធ្លាប់បានទៅលេងស្រុកអីដែរអត់ កាលជំនាន់៣ឆ្នាំ?

សារ៉ាត់ ៖ ទៅដែរ ។

ដានី ៖ ទៅដែរ?

សារ៉ាត់ ៖ បាទ!ទៅ ។

ដានី ៖ ទៅបានប៉ុន្មានដង?

សារ៉ាត់ ៖ ទៅ៧៦ក៏ខ្ញុំទៅ ៧៧ក៏ទៅ ។

ដានី ៖ ទៅយើងសុំច្បាប់គេទៅ?

សារ៉ាត់ ៖ បាទ!

ដានី ៖ គេអត់ថាអីទេ គេឲ្យទៅធម្មតា?

សារ៉ាត់ ៖ ឲ្យ ។

ដានី ៖ ពូពេលដែលពូទៅលេងស្រុក ទៅលេងបានប៉ុន្មានថ្ងៃ?

សារ៉ាត់ ៖ ទៅ២ថ្ងៃអញ្ចឹង ៣ថ្ងៃបានមកវិញ ។

ដានី ៖ ដល់ពេលពូទៅដល់ស្រុក ពូឃើញទិដ្ឋភាពនៅតាមសហករណ៍ នៅតាមភូមិស្រុកនឹង ខុសគ្នាយ៉ាងម៉េច ពីកន្លែងកងទ័ពលោកពូ?

សារ៉ាត់ ៖ កម្រិតធ្លាក់ចុះ ពូឃើញទិដ្ឋភាពបានថាខុសប្លែកការរស់នៅណា យើងឃើញប្រជាជនយើងពិបាក នឹកឃើញថាដោយធ្វើការ គាត់និយាយថាតាមឃុំតាមអីគេគៀបសង្កត់អីអញ្ចឹងដល់យើងជួបដែរ ប៉ុនយើងមិនអាចទៅលូកដៃទេ ។

ដានី ៖ អត់លូកដៃបានទេ?

សារ៉ាត់ ៖ បាទ!ការអាណិតអាសូររបស់យើងតែតែមាន តែយើងមិនអាចលូកដៃ ។

ដានី ៖ កាលនឹងឃើញគាត់ហូបអី ហូបចុក?

សារ៉ាត់ ៖ កម្រិតត្រឹមថាជីវភាពគាត់ធ្លាក់ចុះយ៉ាងនេះយើងកម្រិតត្រឹមថាធ្វើម៉េចយើងស៊ូទ្រាំដើម្បី ។

ដានី ៖ ដើម្បីអីគេទៅ?

សារ៉ាត់ ៖ ដើម្បីជីវិតរបស់យើង កូនចៅយើង ការលំបាកណា ។

ដានី ៖ បានន័យថាយើងស៊ូទ្រាំដើម្បីជីវិតអីអញ្ចឹង ខ្លាចយើងមានកុដកម្ម យើងមានអីទៅខ្លាចគេយកយើងទៅសម្លាប់ ហើយម៉េច?

សារ៉ាត់ ៖ អានឹងវា គាត់តែងតែនិយាយហើយ មិនអញ្ចឹង តែងតែជួបដូចថាក្មួយនិងមីង ឪពុកនិងកូនអញ្ចឹងណា ខំទៅនិយាយទៅខ្លាចលំបាក ប៉ុនយើងមិនបាច់និយាយ មិនបាច់រៀបរាប់អីទេ ។ ហើយយើងចម្លើយដែលយើងឆ្លើយទៅគាត់វិញ គ្រាន់ប្រាប់ថាធ្វើម៉េចអានឹងវាជាសភាពការណ៍ ។

ដានី ៖ កាលនឹងគាត់មានប្រាប់ថានៅតាមស្រុក តាមភូមិអីគេចាប់ប្រជាជន ចាប់អីយកទៅសម្លាប់អី គាត់មានប្រាប់ពូដែរ?

សារ៉ាត់ ៖ មាន ។

ដានី ៖ គាត់មាននិយាយដែរ?

សារ៉ាត់ ៖ មានៗ តែយើងនិយាយភាសាតបវិញ យើងត្រូវប្រើពាក្យថាអ្វីដែលកើតមានពេលនោះគឺជារឿងរបស់បុគ្គល តែយើងមិនអាចដោះស្រាយឲ្យចំបញ្ហាទេ ខ្ញុំនិយាយភាសានឹង ។

ឥឡូវឧទាហរណ៍ថា អ៊ីខ្ញុំនិយាយពីកូនគាត់ត្រូវគេចាប់ ហើយខ្ញុំបានប្រាប់ទៅគាត់វិញថា ធ្វើម៉េចអានឹង ខ្ញុំក៏មិនអាចជួយបាន ព្រោះវាចំណែករៀងៗខ្លួន ភារកិច្ចរៀងខ្លួន ដូច្នេះ លូកទៅបានន័យថាក៏លូកមិនកើតដែរ ។

ដានី : លូកទៅវាយ៉ាងម៉េចទៅ បើតាមពូ?

សារ៉ាត់ : បើកាលណាយើងលូកដៃ បានន័យថាយើងពាក់ព័ន្ធ ព្រោះអ្នកនឹងវាអត់មានស្គាល់យើង ណា អ្នកដែលគេធ្វើនោះ ។

ដានី : ពូគិតថា ដូចថាកូនរបស់អ៊ីពូ គេដូចថាៗគេចាប់ គេយកទៅអីអញ្ចឹង ពូគិតថាគាត់ខុសអី គេយកទៅនឹង គាត់មានកំហុសត្រូវតែគេចាប់យកទៅអញ្ចឹងឬក៏យ៉ាងម៉េច?

សារ៉ាត់ : តាមស្រាវជ្រាវហើយពិនិត្យមកដល់ថ្ងៃនេះមនុស្សនឹងក៏នៅដែរ ។

ដានី : នៅដែរ?

សារ៉ាត់ : គេចាប់នឹងហើយសាកសួរទៅមូលហេតុមកពីទំនាស់ៗបុគ្គលមានអំណាចនឹង ក្រោមអំណាច រឿងអីខ្ញុំអត់ដឹង ព្រោះអានឹងវាដេរ្យគ្នា ។ ហើយមកដល់ថ្ងៃនេះគាត់នៅដូចថា ទាន់សុវ៉ាត ខ្ញុំឧទ្ទេសនាមខាងដើម ។

ដានី : ឈ្មោះ ទាន់ សុវ៉ាត ។

សារ៉ាត់ : គាត់ធ្វើជាយុវជនឃុំ មកដល់ពេលដែលត្រូវប្រធានឃុំនឹងគេចាប់ៗនឹងយុវជនឃុំនឹងទៅ ទៀត ដូច្នេះវាទៅម៉ាខ្សែអញ្ចឹងទៅវាពិបាក មិនដឹងជាទំនាស់រឿងអីយើងអត់ដឹង ។ ហើយ អ្នកណាអ្នកចាប់យើងអត់ដឹង ព្រោះវានៅឆ្ងាយពីគ្នា បានន័យថាសហករណ៍ និងកងទ័ព គឺ ដាច់ហើយ ។

ដានី : ចុះពូដូចថាៗមានការមានគេសម្លាប់ មានចាប់ប្រជាជនអីទៅ នៅតាមស្រុកតាមភូមិដូច ដែលនេះ ពូជឿថានៅក្នុងសម័យ៣ឆ្នាំនឹង មានការចាប់ មានការសម្លាប់មនុស្សអីអស់រាប់ លានអីអញ្ចឹង ពូជឿដែរអត់?

សារ៉ាត់ : ខ្ញុំឃើញសភាពការណ៍រួម ខ្ញុំមិនជឿ១០០ភាគរយទេ ។

ដានី : អត់ជឿ១០០ភាគរយ?

សារ៉ាត់ : បាទ!ព្រោះដោយសារមូលហេតុចេះ ដោយសារមូលហេតុត្រង់ថា មនុស្សដែលមានការ ដឹកនាំដូចជាខ្ញុំស្គាល់ ។

ដានី : លោកអ៊ំខៀវ សំផន?

សារ៉ាត់ ៖ បាទ!ហើយ ខ្ញុំយល់ចិត្តគាត់រហូតដល់គាត់ថា ការខុសនិងការត្រូវរបស់មនុស្សយើងមិនអាចយកវាជាការមួយថា ផ្តាច់ការទេ ។ ដូច្នេះ អ្នកដែលធ្វើគាត់ក៏មានការសោកស្តាយដែរ ប៉ុនមិនមែនខ្លួនគាត់អ្នកធ្វើទេ អ្នកដែលធ្វើនឹង គាត់មិនបាន អ្នកដែលធ្វើនឹងមិនបានគិតថាជាមនុស្សត្រូវតែរស់យ៉ាងណាៗឲ្យចែករំលែកការរស់ ដូច្នេះគាត់កំណត់ថាអ្នកធ្វើនឹងមិនយល់អីទាំងអស់ បំពានៗលើអ្នកដឹកនាំបំពានលើមនុស្សលោកម៉ង់គាត់និយាយអញ្ចឹង ។

ដានី ៖ បានន័យថាអ្នកដែលកាប់សម្លាប់ដូចថាប្រជាជនអីអញ្ចឹង គាត់ចង់និយាយថាអ្នកនឹងអត់មិនយល់?

សារ៉ាត់ ៖ មិនអនុវត្តមាគ៌ា ។

ដានី ៖ មិនអនុវត្តមាគ៌ារបស់ខាងថ្នាក់ដឹកនាំ?

សារ៉ាត់ ៖ ដឹកនាំ បាទ!ថ្នាក់ដឹកនាំ មិនៗព្រមធ្វើៗដោយបំពាន ។

ដានី ៖ ពូគិតថាថ្នាក់ដឹកនាំនឹង មិនមានមាគ៌ាណាដែលឲ្យសម្លាប់ប្រជាជនអញ្ចឹង?

សារ៉ាត់ ៖ អត់ ខ្ញុំជឿថាអត់ម៉ង ។

ដានី ៖ ម៉េចបានពូជឿថាអញ្ចឹង?

សារ៉ាត់ ៖ ព្រោះចេះ ព្រោះខ្ញុំជឿងថាគាត់អត់មាន ប្រឹងថាគាត់ស្វែងរកពីអ្វីមួយដែលគេការរីកចំរើនដើម្បីឲ្យមនុស្សល្អ តែក៏មិនមែនយកអំពើផ្តាច់ការដោយយកមនុស្សទាំងខ្សែទៅវាយចោលដូចការនិយាយ ។

ដានី ៖ ពូឮគេនិយាយថា គេយកមនុស្សទាំងខ្សែយកទៅវាយចោល?

សារ៉ាត់ ៖ ខ្ញុំឮ គាត់ក៏ឮ ។

ដានី ៖ ប៉ុន្តែពូអត់ជឿទេ?

សារ៉ាត់ ៖ ខ្ញុំជឿៗត្រង់ថាម៉េច តំបន់ខ្លះ កន្លែងខ្លះវាប៉ះពាល់ដែរ ហើយសួរថាអ្នកណាកាន់អំណាចពេលនឹងគឺថាខ្លួនគាត់ជាអ្នកកាន់អំណាច ។ ដូច្នេះ អ្វីដែលកើតមាន អ្នកណានៅខាងលើគឺអ្នកនឹងអ្នកទទួលខុសត្រូវ តែមនុស្សក្នុងនឹងមានចំណែកមិនអញ្ចឹងហ្នឹងហើយ ។ មានចំណែកអ្នកណាខ្លះ អ្នកណាដែលមានការពាក់ព័ន្ធ ពេលនោះអ្នកណាខ្លះ គណៈសហករណ៍ គណៈស្រុក គណៈតំបន់ ចុះគណៈមជ្ឈិមមានការពាក់ព័ន្ធទេ មាន ។ តែបទបញ្ជាខ្ញុំយល់ថាគាត់មិនចង់បានរបៀបនេះទេ ព្រោះគាត់ក៏រក្សាមុខមាត់គាត់ដែរ ។ ហើយខ្ញុំឃើញកំហុសដ៏ធំខ្ញុំចង់និយាយថាគឺសហករណ៍ម៉ង ។

ដានី ៖ សហករណ៍?

សារ៉ាត់ ៖ បាទ!សហករណ៍ ព្រោះសហករណ៍ក៏ប៉ះពាល់ដែរ បងប្អូនខ្ញុំ ព្រោះឧទាហរណ៍ថាខ្ញុំធ្វើទ័ពគួរណាតែឯងអ្នកឯងយល់ថាមានប្អូនវាធ្វើ មានក្មួយវាធ្វើទ័ព មិនត្រូវធ្វើបាបបងប្អូនគេទេ ។ ប៉ុននេះអត់ទេ ចង់ឯងបងប្អូនម៉េចក៏ដោយ ឯងតែដកជំឡូងមួយដើមអញយកឯងទៅដាក់គុក អាត្រង់នេះហើយដែលខុស ។ ហើយខ្ញុំទទួលស្គាល់ហើយ ទទួលស្គាល់ថាសហករណ៍ពេលនោះអ្នកឯងទទួលខុសច្រើន ហើយសួរថាអ្នកណាអ្នកចាត់ការ ។

ដានី ៖ ពូកាលជំនាន់នឹងពូដឹងថា គេមានបែងចែកប្រជាជនជាប្រជាជនចាស់ ប្រជាជនថ្មីដែរអត់?

សារ៉ាត់ ៖ ដឹងៗថា១៧មេសា ដឹងថាមូលដ្ឋាន ។

ដានី ៖ ចុះកាលបែងចែងប្រជាជនចាស់ថ្មីនឹង បើតាមនឹងទាក់ទងពីខាងថ្នាក់ដឹកនាំទៅ ឬក៏ពីមាត់ឬយ៉ាងម៉េច ទៅឬក៏ខាងក្រោមជាអ្នកបែងចែងជាប្រជាជនចាស់ ជាប្រជាជនថ្មី ដូច១៧មេសាអីនឹង?

សារ៉ាត់ ៖ អានឹងខ្ញុំនៅកងទ័ព ខ្ញុំឮដូចពាក្យប្អូននិយាយអញ្ចឹងណា បើបញ្ហានេះ អ្នកណាអ្នកបែងចែកខ្ញុំដូចមិនទាន់យល់ ប៉ុនដល់មូលដ្ឋានយើងចូលទៅក្នុងមូលដ្ឋានរបស់សហករណ៍ ឮពាក្យនឹងចេញមក ថាអ្នកនេះថ្មី អ្នកនេះចាស់ ។ ដូច្នេះថ្មីធ្វើម៉េច ចាស់ធ្វើម៉េច ហើយយើងជាកងទ័ព ហើយយើងទៅ យើងអាសូរទេ អាណិតទេ យើងតែមនុស្សដូចគ្នាយើងតែអាណិតអាសូរ ។ ចុះធម្មតាអ្នកចាស់អ្នកថ្មី មនុស្សមកពីណា មនុស្សស្រុកភូមិរបស់យើងដដែលហើយយើងបែងចែកៗវាជាការអីមួយ បែងចែកសម្រាប់អីមិនអញ្ចឹង ។ ដូច្នេះ បែងចែកសម្រាប់មនុស្សដូចថា ពូហើយនិងក្មួយ ឬក៏បងជីដូនមួយ ហើយនិងប្អូនជីដូនមួយ បែងចែងអញ្ចឹងត្រូវទេ ។ ហើយខ្ញុំជួបៗយ៉ាងម៉េច បងខ្ញុំបងអ៊ុក យំអោបជើងខ្ញុំគេបែងចែង នេះយើងអាសូរទេ យើងអាណិតទេ មនោសញ្ចេតនារបស់យើង ប្អូនឯងយ៉ាងម៉េច អត់ទេត្រូវតែអាណិត តែយើងដោះស្រាយបានទេ យើងទៅថាឲ្យគេថាម៉េចបងឯងបែងចែកយើងទៅនិយាយបានទេ អត់បានទេ គេថាយើងខ្មាំងទៀត ពេលនឹងគេដាក់យើងភ្លាមក៏មិនដឹង ។

ដានី ៖ កាលជំនាន់ពូទៅលេងផ្ទះនឹង ពូមានបងប្អូនអីដែលគេបែងចែកគាត់ជាប្រជាជនថ្មី ជាប្រជាជនចាស់អញ្ចឹងដែរ?

សារ៉ាត់ ៖ មាន ។

ដានី ៖ មានមកយំអប់ជើងពូ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ពេលដែលគាត់យំអប់ដើងពួអញ្ចឹងៗ ពេលនឹងពូគិតថាម៉េចដែរ ក្នុងចិត្ត?

សារ៉ាត់ ៖ អារម្មណ៍កម្រិតត្រឹមថាការគេដើម្បីអី គិតដែរណា តែថ្ងៃនេះប៉ុននឹង ចុះថ្ងៃក្រោយទៀតយ៉ាងណា ។

ដានី ៖ ចុះអញ្ចឹងពូគិតថាការបែងចែកនឹងដោយសារមកពីខាងថ្នាក់លើ ខាងថ្នាក់ដឹកនាំគេដាក់ច្បាប់មកថាត្រូវឲ្យបែងចែកប្រជាជនចាស់ ប្រជាជន១៧មេសា ប្រជាជនមូលដ្ឋាន ហើយអញ្ចឹងបានពួកថ្នាក់ក្រោម ពួកថ្នាក់ខាងសហករណ៍ ថ្នាក់ស្រុក ថ្នាក់តំបន់គេរៀបចំបែងចែកអញ្ចឹង ឬក៏ខាងលើនេះ មិនបានចេញជាគោលការណ៍គេខាងក្រោម?

សារ៉ាត់ ៖ ពេលនឹងចេះ ពេលនឹងខ្ញុំកងទ័ពមានការប្រជុំរៀនសូត្រអីពីអគ្គមេបញ្ជាការ ហើយប្រជាជនមូលដ្ឋានគេមានរៀនសូត្រខាងមូលដ្ឋាន ដូច្នេះការវែកញែក ការបែងចែក គឺកងទ័ពដឹងតែដឹងភាគតិច អត្ថន័យជាក់ស្តែងសូន្យៗ ។ យើងដឹងតែមួយទេ យើងដឹងថាការប្រយុទ្ធកន្លងទៅគឺដើម្បីប្រទេសជាតិរបស់យើង ពាក្យដែលខ្ញុំនិយាយខាងដើមថា អាធ្មៀវគឺមកធ្វើអីខ្លះដល់ប្រជាជន យើងមានកំហឹងឆ្លើយតបទៅវិញគឺថា មូលហេតុដើមចោទគឺនរណាលន់ នល់ រំលំកម្ពុជាឯករាជ្យទម្លាក់សម្តេចៗអំពាវនាវឲ្យកូនចៅទាំងអស់ម៉ាគីម៉ាគា យើងនិយាយភាសានេះ មិនមែនដាក់ទោសឲ្យអ្នកណាទេ ព្រោះកម្ពុជាវាច្របល់ហើយ ។ ហើយមកដល់អារៀបចំសហករណ៍នឹងទៀត ខ្ញុំមិនដឹងថាអ្នកណាល្អ អ្នកណាអាក្រក់ដែរ មែនទេ មិនដឹងថាប្រធានសហករណ៍អាក្រក់ ឬក៏ដឹកនាំឲ្យបែងចែកអញ្ចឹងយើងអត់ដឹង ។ ទាំងអស់គ្នាសុទ្ធតែសមាជិកនៅក្នុងសម័យនោះ ។ ជឿៗទេ និយាយឲ្យចំទៅ សិទ្ធិនិងសេរីភាពមានកំរិត ។

ដានី ៖ កាលនឹង?

សារ៉ាត់ ៖ បាទ!ខ្ញុំអនុសេនាធំក៏កំរិតខ្ញុំ គេវរសេនាធំគេមានកម្រិតរបស់គេ ។

ដានី ៖ អញ្ចឹងយើងរស់នៅក្នុងកាលពីជិនាន់ពាន្នាំនឹង យើងការរស់នៅយើងសិទ្ធិហើយសេរីភាពយើងមានកំរិត មានដែនកំណត់?

សារ៉ាត់ ៖ បាទ!មានដែនកំណត់ថាអនុសេនាធំធ្វើការងារអី វរសេនាតូចធ្វើការងារអី យើងអត់លូកដៃទេ មិនមែនឆ្លើយឆ្លងគ្នាអញ្ចឹងបាន ។ ឧទាហរណ៍ថាខ្ញុំស្អប់ប្អូនឯង គេធ្វើអីស្រេចតែគេ ដូច្នេះប្អូនឯងអត់មានសិទ្ធិ មិនអញ្ចឹង ខ្ញុំក៏អញ្ចឹងដែរ ។

ដានី ៖ អញ្ចឹងដូចថាពូធ្លាប់រស់នៅឆ្លងច្រើនរបប ដូចថាពីមុន ពីរបបសម្តេច ចូលដល់របបលន់នល់ រហូតដល់របបពាន្នាំ ក្រោយមកចូលដល់តស៊ូ ហើយរហូតមកដល់ឥឡូវនឹង ពូគិតថាការរស់នៅក្នុងរបបមួយៗនឹងវាខុសគ្នាយ៉ាងម៉េចខ្លះទៅ?

សារ៉ាត់ ៖ ខ្ញុំពិចារណាសម័យសម្តេច សម័យលន់នល់ សរុបទៅថ្នាក់ដឹកនាំទាំងអស់កម្ពុជាយើង មានគុណសម្បត្តិ និងគុណវិបត្តិ ប៉ុន្តែអ្នកខ្លះមានតិច អ្នកខ្លះមានច្រើន ។ ប៉ុន្តែមកដល់សព្វថ្ងៃនេះទៀត ខ្ញុំដឹងថាបានឆ្លងកាត់ច្រើនដែរ តែអ្វីដែលខ្ញុំពិនិត្យពិច័យទៅ ក៏នៅតែឃើញនៅតែយល់នៅតែដឹង ពីព្រោះមនុស្សយើងវ័យប៉ុននេះយើងដឹង អ្វីខុសអ្វីត្រូវធ្វើល្អ ។ ដូច្នេះបានន័យថាក្នុងសម័យមួយៗ ។

## កាសែ្សតទី៨ ផ្នែក«ក»

សារ៉ាត់ ៖ ត្រង់ថាខ្ញុំនៅមើលឃើញទៅខ្ញុំធ្វើចេះ គំនិតរបស់ខ្ញុំ នែក!យល់ថាអ្នកណាអាក្រក់ពេក ហើយឲ្យក៏អ្នកណាល្អពេកក៏ខ្ញុំអត់ដឹងទាន់បានយល់ដែរ ។ តែចង់ឲ្យប្រវត្តិសាស្ត្រកត់ត្រានិងស្វែងរកការពិតនេះ តទៅទៀត អ្វីយុត្តិធម៌ អ្វីអយុត្តិធម៌នៅលើការរៀបចំរបស់ជាតិយើង ។ ចង់ឲ្យបានជាតិយើងមួយស្គាល់អ្វីទៅគេហៅថាសុភមង្គលរបស់មាតុភូមិ កុំឲ្យឃើញទៀត អ្វីដែលយើងឃើញទាំងវិនាសកម្មទាំងអីទាំងអស់នេះ ។ ហើយខ្លួនខ្ញុំតាំងចិត្តអញ្ចឹង ។

ដានី ៖ ចុះពូរយៈពេលពូតស៊ូចូលមក ដូចថាចាប់ផ្តើមចូលព្រៃម៉ាគីម៉ាគាតាំងពីឆ្នាំ៧០ តាំងពីរដ្ឋប្រហារ តាំងពីថ្ងៃ១៨ មិនា ១៩៧០ រយៈមកដល់សមាហរណកម្មឆ្នាំ៩៦?

សារ៉ាត់ ៖ ៩៨ ។

ដានី ៖ ៩៨ រហូតកាលពូធ្វើសង្គ្រាមនឹង ជីវិតពូចំណាយពេលអស់ពី៧០ដល់៩៨នឹង វាជាង៣០ឆ្នាំ ពូយល់ឃើញថាការជីវិតដែលពូឆ្លងកាត់មកនឹង ដូចថាពូយល់ឃើញយ៉ាងម៉េចដែរការជីវិតក្នុងសង្គ្រាមនឹង?

សារ៉ាត់ ៖ ការជីវិតឆ្លងកាត់ក្នុងសង្គ្រាមនឹង វាជាឧបករណ៍មួយនៅក្នុងសង្គម សម្រាប់អ្នកនយោបាយប្រើប្រាស់ គ្មានអ្វីសំខាន់ ។

ដានី ៖ គ្មានអីសំខាន់ទេ?

សារ៉ាត់ ៖ បាទ!ដឹងថាសំខាន់ត្រង់ៗ ពេលដែលឃើញយន្តហោះទម្លាក់មក កំហឹងឈឺចាប់ គេម៉េចមកឲ្យទម្លាក់ឲ្យស្លាប់ជាតិខ្មែរ អារម្មណ៍ចាប់ត្រង់នឹង អញ្ចឹងហើយបានធ្វើពន្យាៗ ។ ហើយពេលដែលឃើញ ៧៩មកដល់ពេលនេះ វាឃើញរឿងមួយផ្សេងទៀត ។ អ្នកឯងយ៉ាងម៉េចបានជាមានកាន់កាំភ្លើងតូច កាំភ្លើងធំ មកវាយយើងមនុស្សទន់ខ្សោយ អានឹងដល់វាចេះតែមានហើយ ។ ហើយមកដល់ថ្ងៃនេះ យើងដូចថាអត់មានន័យអី អ្វីដែលធ្វើមកនឹង ។

ដានី ៖ អញ្ចឹងដូចកាលដែលពូចំនាយពេលអស់ជិត៣០ឆ្នាំ ធ្វើសង្គ្រាមអីនឹង ដូចថាពូមានការសោកស្តាយ ដូចថាមានវិបត្តិសារីអីយ៉ាងម៉េចខ្លះដែរ?

សារ៉ាត់ ៖ វិបត្តិសារីនៅត្រង់ថាអ្នកនយោបាយ នៅត្រង់ថាខ្មែរយើងមិនយល់គ្នាម៉ង។

ដានី ៖ មិនយល់គ្នា?

សារ៉ាត់ ៖ បាទ! មិនយល់គ្នាត្រង់ថា ជាតិយើងមួយមានប្រវត្តិសាស្ត្ររុងរឿង ពីអតីតកាលយូរលង់មកហើយ។ ហើយមកដល់បច្ចុប្បន្នក្នុងដំណាក់កាលប៉ុន្មានឆ្នាំនេះ នៅក្នុងកម្ពុជាមួយតូច វាបែរទៅជាមានភ្លើងដុតរោលរាល អ្នកណាក៏ទទួលឥទ្ធិពល កាលរោលរាល ជុំវិញដូចគ្នាមិនថាគេមិនថាខ្ញុំ គ្រួសារណាក៏មាន ហើយវាប៉ះទង្គិចទាំងអស់ ឃើញទាំងអស់គ្នាអញ្ចឹង។ អញ្ចឹងហើយបានខ្ញុំអត់មានអីទេ សព្វថ្ងៃគេថាសម្រាប់ជីវិតរស់តទៅទៀត គឺថាធ្វើម៉េចឲ្យកូនឲ្យចៅចេះយល់ថាខ្មែរទាំងអស់ត្រូវចេះសាមគ្គី ចេះយល់គ្នា កុំអាងអីតែ គិតតែអំណាច ឬគិតតែអី យើងមិនយល់អានឹងមិនបាន។ ដូច្នេះ គ្រួសារមួយមានជីវភាពអនាគតត្រឹមត្រូវ សង្គមទាំងមូល ជាតិទាំងមូលគឺរុងរឿង បាទ!ចង់ឲ្យអញ្ចឹង។

ដានី ៖ ដូចពូធ្លាប់ឆ្លងកាត់សង្គ្រាមជិត៣០ឆ្នាំអីអញ្ចឹងឧបមាថានេះ ពូដូចថាមានចិត្តចង់កាន់កាំភ្លើងចង់អីដើម្បីតស៊ូទៀតអី?

សារ៉ាត់ ៖ សាបសូន្យ មកដល់ថ្ងៃនេះវា៥៨ ៥៩ ៦០ហើយ វ័យនេះវ័យដល់អស់ន័យ យើងត្រូវទៅមានកម្លាំងអីអត់ទៀតអត់។

ដានី ៖ ចុះពូកូនពូក្រោយៗនៅក្មេងនៅអីអញ្ចឹង ពូមានចង់ឲ្យពួកគេតស៊ូ កាន់កាំភ្លើងដើម្បី?

សារ៉ាត់ ៖ អត់ បាទ!អានឹងអត់ទេ សូម្បីតែមកកូនឯងទៅធ្វើទាហាននឹងក៏អត់ដែរ។ កូនឯងខំរៀនចេះដឹងធ្វើការងារណាមានរបៀបរបបក្នុងសង្គមកែចំរើន កែសង្គមឲ្យរីកចំរើន។ ដូច្នេះកូនត្រូវប្រឹងៗរៀនសូត្រឲ្យចេះហើយធ្វើជាអ្នកចេះដឹង ហើយមានទំនៀមទម្លាប់មួយជាខ្មែរច្បាស់លាស់។

ដានី ៖ ចុះពូមកដល់សព្វថ្ងៃ ពូដែលឮពត៌មានគេបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?

សារ៉ាត់ ៖ បាទ!ឮ។

ដានី ៖ ឮដែរ?

សារ៉ាត់ ៖ ខ្ញុំកំពុងតែរង់ចាំ។

ដានី ៖ កំពុងរង់ចាំ?

សារ៉ាត់ ៖ បាទ!តើកាត់ទោសទៅវាប៉ះអ្នកណាខ្លះ ប៉ះមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ឬប៉ះមេដឹកនាំខ្មែរក្រហមជាន់ទាប តាមការសម្រេចរបស់តុលាការខ្នាតអន្តរជាតិ និងខ្នាតជាតិ ។

ដានី ៖ ពូតាមដានច្បាស់ដែរអញ្ចឹង?

សារ៉ាត់ ៖ បាទ!

ដានី ៖ ដឹងថាតុលាការនឹងជាខ្នាតអន្តរជាតិ និងជាតិ?

សារ៉ាត់ ៖ បាទ!

ដានី ៖ ចុះក្នុងចិត្តរបស់ពូៗយល់ឃើញពីតុលាការនឹង ពូយល់ឃើញថាយ៉ាងម៉េចដែរ?

សារ៉ាត់ ៖ យល់ឃើញថា បើតុលាការនេះ មានការរៀបចំឲ្យលំដាប់ថ្នាក់អន្តរជាតិនេះច្បាស់លាស់ ភាពសុក្រិតយុត្តិធម៌ ជាតិ ប្រជាជនកម្ពុជានឹងឃើញ ហើយថាតើអ្នកណាខុសពីបញ្ហាអី អ្នកណាត្រូវពីបញ្ហាអី វាពិតជានឹងឃើញ ។ ប៉ុន្តែបើសិនណាធ្វើមិនបាន ជាតិយើងវានៅច្របូលច្របល់ ។ ដូច្នេះខ្ញុំអត់ចង់ឃើញទេ ភាពច្របូកច្របល់ ព្រោះភាពច្របូលច្របល់វាមានមកហើយ ដូច្នេះតទៅទៀតត្រូវឲ្យមានតំលាភាពមួយច្បាស់ ។

ដានី ៖ ពូចង់ឲ្យតុលាការនឹងធ្វើការទៅប្រកបដោយតំលាភាព?

សារ៉ាត់ ៖ បាទ!តំលាភាព ខុសគឺខុស ហើយខុសភស្តុតាងអីខ្លះ ហើយអ្នកត្រូវភស្តុតាងអីខ្លះ ។

គី ៖ ហើយពូគាំទ្រទេ គាំទ្រតុលាការនឹងទេ?

សារ៉ាត់ ៖ គាំ ។

គី ៖ ឧទាហរណ៍ថានៅក្នុងតុលាការខាងមុខនឹង ឧទាហរណ៍ថាគេកាត់ទោសមេមួយចំនួនដែលលោកពូស្គាល់ ដូចជា បាទ!គាត់អីអញ្ចឹងទៅ តើពុកិតថាតុលាការនឹងត្រឹមត្រូវដែរ បើសិនជាគេកាត់ទោស?

សារ៉ាត់ ៖ នែក!ព្រោះធម្មតាបើកាលណាច្បាប់អន្តរជាតិវាមាន ដូចថាតុលាការកាត់ទោសប្រភេទប្រល័យពូជសាសន៍ក្នុងថ្នាក់ជាតិ ប្រភេទតុលាការកាត់ទោសពួកឧក្រិដ្ឋកម្មសង្គ្រាម ប្រភេទកាត់ទោសពួកមេឃាដក ទាំងអស់នេះខ្ញុំយល់ថាទោះបីអ្នកណា មានឈ្មោះក្តីមិនមានឈ្មោះក្តី ពេលនឹងបើតុលាការកោះត្រូវតែទៅ ហើយគាំទ្រដែរមិនមែនគាំទ្រដែរ គាំទ្រទាំងស្រុងដោយឃើញថាអ៊ីដែរធ្វើមក បើមិនបានចូលទៅជជែកគ្នា គឺអត់រកខុសរកត្រូវឃើញទេ ។ ហើយបើមានការជជែកដោយមានតុលាការ មានមេធាវីច្បាស់លាស់ ពិតជារកខុស រកត្រូវឃើញ កំហុសវានៅត្រង់ណា គ្មានកំហុសវានៅត្រង់ណា បើឃើញអញ្ចឹងខ្ញុំគាំទ្រ ។

ដានី ៖ ប៉ុន្តែដូចថាចំពោះការបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនឹងគេមានកម្រិតថ្ងៃខែគេ អាជ្ញាយុកាលគេ ដូចថាគេចាប់ផ្តើម ច្បាប់នឹងវាមានតែពីថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ដល់៦មករាឆ្នាំ១៩៧៩ ។ អញ្ចឹងការដែលគេកម្រិតច្បាប់នឹង គេកាត់ទោសតែចន្លោះពេល៣ឆ្នាំនឹងទេ ដូចថាពីមុននឹង ពីក្រោយនឹងគេអត់មានទេ ។ អញ្ចឹងពូគិតថាវាយ៉ាងម៉េចដែរ?

សារ៉ាត់ ៖ ខ្ញុំថាបើធ្វើអញ្ចឹងខ្ញុំយល់ថាសភាពការណ៍នៅកម្ពុជាដូចអត់ទាន់ នៅមានកន្ទុយទៀត ។

ដានី ៖ នៅមានកន្ទុយ?

សារ៉ាត់ ៖ មានកន្ទុយ មានក្បាលអានឹងបានអស់ ព្រោះកាត់តែកណ្តាល កន្ទុយហើយនឹងក្បាលគេស៊ីអស់ មិនដឹងអ្នកណាស៊ីខ្ញុំអត់ដឹងទេ ប៉ុនមានតែកណ្តាលអញ្ចឹង សាច់នឹងប្រហែលជាឆ្ងាញ់ហើយបានយកកណ្តាល ។

គី ៖ ពូគិតថាអញ្ចឹង ឧទាហរណ៍ថាខ្ញុំសួរសំនួរនេះ បើសិនជាពូឆ្លើយក៏បាន មិនបាច់ឆ្លើយក៏បាន ហើយខ្ញុំគិតថាតំបន់នេះ ដូចថាមានបងប្អូនអ្នកអតីតកម្ពុជាប្រជាធិបតេយ្យច្រើនអញ្ចឹង ឧទាហរណ៍ថា ពូនិយាយមិញថាយើងកាត់តែកណ្តាលអីអញ្ចឹង ហើយកន្ទុយនឹងវាមានច្រើនអញ្ចឹង ឧទាហរណ៍ថាតុលាការនឹងគេមានដែនអាជ្ញាយុកាលគេចង់កាត់ដល់ពួកខាងក្រោមៗអញ្ចឹង តើពេលនឹងពូគិតថាស្ថានភាពយើងវាយ៉ាងម៉េច ហើយពូគិតថាគាំទ្រឲ្យមានដំណើរការអញ្ចឹង ឬក៏ពូគិតថាពូអត់និយាយ?

សារ៉ាត់ ៖ ខ្ញុំពិសោធន៍ច្បាប់ លោកបង្កើតច្បាប់អន្តរជាតិមួយដែលខ្ញុំចាំបាន ហើយខំអនុវត្តមកឆ្នាំ១៩៩១ នេះកិច្ចព្រមព្រៀងបារីស ឆ្នាំ១៩៦០ទីក្រុងឡាអេ ឆ្នាំប៉ុន្មានមានបន្តបន្ទាប់មកដូចមិនទាន់មានឃើញមេដឹកនាំណានៅក្នុងសកលលោក នៅក្នុងកម្ពុជា នៅប្រទេសផ្សេងៗអនុវត្តច្បាប់អស់ ។ចេះតែបំពាននិងរំលោភបន្តបន្ទាប់មករហូត ឧទាហរណ៍ថាឥឡូវប្រាសាទព្រះវិហារឡាអេសម្រេចឲ្យ៦២ ឥឡូវគេនៅតែថារបស់គេទៀត មែនទេ មានដែលពុអានឹងទេ ។

ដានី ៖ ប៉ុន្តែគេថារបស់គេ ប៉ុន្តែជាលក្ខណៈផ្លូវច្បាប់យើងមានឯកសារគ្រប់គ្រាន់ពីទីក្រុងឡាអេ ជានេះអញ្ចឹង ដែលគេនិយាយថារបស់គេ ជាលក្ខណៈខ្លួនរបស់គេផ្ទាល់ គេអ្នកនិយាយប៉ុន្តែអត់មានការទទួលស្គាល់ជាអន្តរជាតិ ។ ហើយចំពោះមេដឹកនាំផ្សេងៗទៀតនៅលើសកលលោកយើងមានម៉ាចំនួនដែលគេហៅទៅទីក្រុង ដូចគេកាត់ទោសនៅទីក្រុងឡាអេណា ដូច

នៅខាងយូហ្គោស្លាវី ខាងស្ទូបឺដានមីឡូសាវិចអីអញ្ចឹង ហើយនឹងតុលាការនុយរ៉ុប៊ឺននៅខាងអាព្រិចខាងត្បូង មានដែរ ។

សារ៉ាត់ : អញ្ចឹងបានថានិយាយៗទៅកិច្ចព្រមព្រៀងបារីស មានការយល់ព្រមពីអង្គការសហប្រជាជាតិ ថ្ងៃ២៣ តុលា ឆ្នាំ១៩៩១ ហើយយកមកអនុវត្តនៅកម្ពុជាបាន តែមិនទាន់ភាពសុក្រិត ខ្ញុំឃើញថានៅ ។ គទៅទៀតមិនដឹងយ៉ាងណាទេ ពាក្យថាសុក្រិតខ្ញុំចង់និយាយថា ៤ភាគីគឺ៤ភាគី កុំឲ្យ៤ហើយមាន២អានឹងអត់ត្រូវ ។ មែនទេ បើមាន៤គឺ៤ កាលនឹងមិនមាន៤ ។

ដានី : កន្លែងនឹងខ្ញុំនេះមួយ ខ្ញុំមិនដឹងថាខ្ញុំគិតត្រូវឬខុស កន្លែង៤ភាគី កាលពីដំបូងកាលយើងមានអ៊ុនតាក់ដំបូងមក មាន៤ភាគីមែន មានភាគីខាងរដ្ឋកម្ពុជា មានភាគីខាងហ៊្វុនស៊ីប៉ិច ហើយខាងលោកតាសឺនសាន ហើយនឹងខាងកម្ពុជាប្រជាធិបតេយ្យ ខាងពួសំផន ។ ប៉ុន្តែក្រោយមកខាងកម្ពុជាប្រជាធិបតេយ្យ ខាងខៀវ សំផន គាត់ដកចេញដោយខ្លួនឯង ។

សារ៉ាត់ : មានការបោះឆ្នោត ។

ដានី : ដកចេញពីការបោះឆ្នោត ក្រោយមកមាន៣ភាគីៗក្រោយមកទៀត ខាងលោកតាសឺនសាន ក្រោយមកគាត់រំលាយ ហើយនៅសល់តែ២ ។ អញ្ចឹងកាលនឹងពូយល់ថាយ៉ាងម៉េចដែលអញ្ចឹង ដូចថាខ្ញុំយល់ឃើញ ដំបូង៤ភាគីមែន ប៉ុន្តែដោយសារយើងដកខ្លួនចេញដោយឯង?

សារ៉ាត់ : ខ្ញុំយល់ឃើញចេះ យល់ឃើញថា បើពេលនឹងអនុវត្តកិច្ចព្រមព្រៀង គឺថាទាំងអស់គ្នាដើម្បីបោះឆ្នោត អាវុធទាំងអស់នៅក្នុងកណ្តាប់ដៃរបស់អង្គការសហប្រជាជាតិ ប៉ុនពេលនោះអត់ៗអនុវត្ត ត្រង់នឹងហើយបានខៀវ សំផន ដកខ្លួន ខ្ញុំអត់ដឹងយ៉ាងម៉េច ប៉ុនខ្ញុំឃើញអញ្ចឹង ព្រោះពេលនឹងខ្ញុំក៏ទៅប្រចាំការជាមួយគាត់នៅទីស្នាក់របស់ខៀវ សំផន នៅកន្លែងវាំងដីរ ខ្ញុំបានទៅអនុវត្តហើយរហូតចរចា និងអនុវត្តកិច្ចព្រមព្រៀងថាខទី១ ត្រូវធ្វើអី ខទី២អ្នកឯងធ្វើអី ខទី៣អ្នកឯងធ្វើអី តែអន្តរជាតិអត់ ។ អត់ព្រមទាំងអស់៤ភាគីថាឥឡូវអាវុធយកទាំងអស់គ្នា ទុកម៉ាកន្លែងអង្គការសហប្រជាជាតិឲ្យស្អី អង្គការខាងកំទេសអាវុធពិភពលោក ឲ្យឆេះចោលអស់ទៅពេលនឹង ឲ្យឆេះទាំងអស់គ្នាទៅវាចប់ហើយ តែប៉ុននឹងអនុវត្តកិច្ចព្រមព្រៀងចំ ។

គី : ពេលនោះពូឃើញមើលតែដកអាវុធតែពូខាងកម្ពុជាប្រជាធិបតេយ្យមួយទេ?

សារ៉ាត់ : ដូចជាមិនដក ។

ដានី ៖ អត់ដកទាំងអស់?

សារ៉ាត់ ៖ អត់ៗធ្វើៗ

ដានី ៖ ប៉ុន្តែមូលហេតុអីជាមូលហេតុចំបង ដែលធ្វើឲ្យខាងកម្ពុជាប្រជាធិបតេយ្យដកខ្លួនចេញពីការបោះឆ្នោត?

សារ៉ាត់ ៖ មូលហេតុមកពីសង្គ្រាមភ្នំឆ័ត្រផ្ទុះវិញ ភ្នំឆ័ត្រហើយប៉ៃលិន អឺ!ភ្នំឆ័ត្រហើយអន្លង់វែងៗ ហើយប៉ៃលិន មកដល់៩៨ៗ ដេវសេត្តិពេលនឹង ខ្ញុំចង់និយាយ បើអង្គការអន្តរជាតិ ខាងអន្តរជាតិនឹង ហើយដេវសេត្តិរាល់ថ្ងៃនឹង ទម្លាក់កាំទេចអាវុធ បើធ្វើ ខ្ញុំយល់ឃើញថាប្រហែលជាគាត់មិនរត់ចេញទេ អានឹងសរុបចុងក្រោយ អានឹងវាពេលវេលាវាហួសមកហើយ ប៉ុនហួសដូចគ្នាៗ

ដានី ៖ បាទ!ចុះក្រោយមកដូចថាមូលហេតុអីបានយើងចូលសមាហរណ៍កម្មឆ្នាំ៩៨?

សារ៉ាត់ ៖ អានឹងមកពីចេះ មកពីសង្គ្រាមវាកាន់តែវិចវិល ហើយគ្មានន័យអីដែលត្រូវបន្តបានទេ ព្រោះពេលនឹងផ្ទៃក្នុងកម្ពុជាប្រជាធិបតេយ្យបែកបាក់ ខ្ញុំនិយាយឲ្យចំ បែកបាក់ ធម្មតាគ្រួសារមួយឪពុកម្តាយលែងគ្នា កូនទឹកភ្នែកៗ បើកូនមិនទៅអោបជើងឪពុកធំ ឬមាទេ ឪពុកមាទេ ឲ្យមកដោះស្រាយ ហើយបើឪពុកធំហើយឪពុកមាមិនដោះស្រាយទៀត កូនទៅណាៗ ដូច្នេះ កូនត្រូវអប់ជើងហើយ អប់ជើងអ្នកណាមួយយើងមិនដឹងទេ ព្រោះឪពុកម្តាយឈ្លោះគ្នា គ្រួសារមួយបែកបាក់មិនអាចមានបាយហូបទេៗ

គី ៖ សំនួរចុងក្រោយហើយពូៗមិញនិយាយថាយើងកាត់ទោសពួកមេធំៗ ហើយពូថានៅសល់កន្ទុយអញ្ចឹង យើងត្រូវធ្វើម៉េចដើម្បីបំបាត់អាកន្ទុយនឹងចោល?

សារ៉ាត់ ៖ អានឹងទាល់តែដំណើរការ ខ្នាត់អន្តរជាតិខ្ញុំក៏មិនសូវយល់ដែរ ខ្ញុំចង់និយាយថាធ្វើយ៉ាងណាឲ្យតែវាមានតំលាភាពមួយ អនុសាសន៍ណាមួយឲ្យវាឃើញទាំងអស់គ្នាម៉ង់ៗ ឲ្យឃើញថាកម្ពុជានឹងវាមានអីដែរកន្ទុងទៅ រកអាចំណុចខ្លាំងឲ្យឃើញ ហើយចំណុចខ្សោយរបស់កម្ពុជាត្រូវរកឲ្យឃើញ កុំឲ្យឃើញហើយនៅដាក់កំហុស អ្នកណាមកក៏នៅតែខុសៗរហូតៗ បើអញ្ចឹងវាអត់មានត្រូវ ឥឡូវឧទាហរណ៍អញ្ចឹង សម្តេចហ៊ុន សែន គាត់ខ្លាំងហើយ តែមានមតិខ្លះគេថាខុសទៀត មែនទេ សម្តេចសីហនុថាខ្លាំងហើយ ប៉ុននៅមានមតិខ្លះគេថាខុសទៀត អានឹងការពិត អានឹងខ្ញុំសុំនិយាយអញ្ចឹង ថាខៀវ សំផននោះខាងខូចមហាខូច ប៉ុនដល់ជួបខៀវ សំផន ស្គាល់គាត់ថាគាត់ជាមនុស្សស្លូតដែរៗ ដូច្នេះ អានឹងហើយដែលយើងត្រូវរកឲ្យឃើញ ដើមចមនឹងតើមកពីអ្នកណា ខូចមកនៅក្នុងកម្ពុជានឹងអ្នកណាគេ បើ

ថាមនុស្សនឹងរសើបហើយ ចាក់ចង្កេះទៀតរសើបទេ។ ដូចនែក!ក្រពើវានៅលើគោក នៅក្នុងទឹកក៏ដោយប៉ុនចាក់ចង្កេះវាខាំ ប៉ុនអត់ចង្កេះអត់ខាំ ដែលដឹងពាក្យនឹងទេ។

គី : អត់ ពូពន្យល់បន្តិច ពន្យល់ពូពន្យល់ក្នុងន័យក្នុងរឿងស្រុកខ្មែរ ក្រពើនឹងចង់ប្រៀបធៀបទៅអ្នកណា ហើយអ្នកចាក់ចង្កេះនឹងអ្នកណា ពូអាចនិយាយប្រាប់បានទេ?

សារ៉ាត់ : ទឹកដីបាត់បង់តើមានអ្នកណាមកយក ខុសពីអ្នកនៅអន្លុយជិត ឥឡូវឧទាហរណ៍ផ្ទះមួយនឹងបើផ្ទះខាងកើតអត់យក ផ្ទះខាងលិចអត់យកផ្ទះនឹងមិនគង់វង្ស។ មែនទេ? កម្ពុជាអានឹងកម្ពុជានៅត្រង់នឹង។

គី : កម្ពុជាដូចជាក្រពើអញ្ជឹងពូ?

សារ៉ាត់ : កម្ពុជាគឺជាក្រពើ មិនអញ្ជឹង បើខាងកើតចាក់ចង្កេះ ក្រពើវាបោកស្តាំហើយ បើចាក់ខាងលិចក្រពើបោកឆ្វេងហើយ បោកដើម្បីអីព្រោះភ្ញាក់ ហើយនៅតែមាន។

គី : ចុះពូគិតថាកំហុសនឹង ជាកំហុសរបស់ក្រពើ ឬកំហុសអ្នកចាក់?

សារ៉ាត់ : អ្នកចាក់ៗចង់ឲ្យក្រពើនឹងងាប់ បោកឆ្វេង បោកស្តាំងងាប់ហើយ ម៉ាសន្ទុះងាប់ហើយ។

ដានី : ហើយក្រពើនឹងងាប់ទៅបានប្រយោជន៍យ៉ាងម៉េចខ្លះ?

សារ៉ាត់ : បានប្រយោជន៍អ្នកចាក់ ទាំងសងខាងចែកគ្នាទៅ។

គី : បាទ!ពូសុំបន្តិចទៀតចុងក្រោយ ពូគិតថាតុលាការយើងនឹងគិតថាជាផ្តល់មេរៀនអីសំខាន់សម្រាប់ប្រទេសជាតិយើង ក៏ដូចជាក្មេងៗជំនាន់ក្រោយ តុលាការនឹងកើតឡើង?

សារ៉ាត់ : បាទ!នឹងកើតឡើង ហើយវាផ្តល់មេរៀនសំខាន់ណាស់ ធ្វើឲ្យកម្ពុជា ក្មេងខាងក្រោយនេះវាដឹងៗថាពេលណាវាមានលំដាប់ថ្នាក់អន្តរជាតិ ព្រោះអាតុលាការខ្មាតអន្តរជាតិនេះវាមានលំដាប់ មិនមែនចេះតែកើតទេ បើអញ្ជឹងវាទៅកើតនៅស្រុកថៃ។ អាញ្ជឹងហើយបានវាកើតនៅកម្ពុជា បានវាចេះតែជាប់មកអញ្ជឹង ហើយម៉េចខ្ញុំយល់ឃើញអញ្ជឹង។

គី : ដូចគិតថាខ្ញុំចង់ឲ្យក្មេងៗជំនាន់ក្រោយអីយើងបានរៀនសូត្រអីពីតុលាការនឹង?

សារ៉ាត់ : ថាឲ្យបានរៀនសូត្រ វាដឹងថាច្បាស់លាស់នៅកម្ពុជា ក្នុងឧទាហរណ៍ថ្ងៃណាខែណាមានការកាត់ទោសអ្នកណាៗខ្លះអញ្ជឹងទៅ ហើយក្មេងក្រោយយកអានឹងទៅផ្តោតក្នុងអារម្មណ៍ ព្រោះមនុស្សយើងមិនអាចកំណត់វាសនាទេ មិនអាចថាប៉ុន្មានទេ មិនកើតទេ មិនអាចថានែក!ក្មេងនេះវា មានបុណ្យអត់បុណ្យអីយើងអត់និយាយទេ វាស៊ីសងលើការសិក្សា។

គី : ផ្តោតអារម្មណ៍ដើម្បីអីទៅពូ បើយើងគិតថាក្មេងៗជំនាន់ក្រោយនឹងវាអត់បានឆ្លងកាត់អញ្ជឹងដូចពូ ពិបាកអីអញ្ជឹង តើវាផ្តោតអារម្មណ៍ដើម្បីអីទៅ?

សារ៉ាត់ ៖ វាផ្ដោតអារម្មណ៍គ្រាន់តែឃើញយើងរៀន សម័យខ្ញុំរៀនសូត្រប្រវត្តិសាស្ត្រកម្ពុជាអី អញ្ចឹង បានឃើញថាកម្ពុជាបាត់បង់ម៉ាចំណែកទៅនេះ ម៉ាចំណែកទៅនោះទៅ ។ ដូច្នេះ សម្រាប់ខ្លួនខ្ញុំៗអត់ចង់ឲ្យថាប្រទេសជិតខាងលេបបំបាត់ទឹកដីខ្ញុំអត់ចង់ឲ្យទេ អាត្រង់នឹង ហើយដែលខ្ញុំខំធ្វើថាការពារទឹកដី បាទ!ស្រឡាញ់ណាស់ ស្រឡាញ់ទឹកដីជាងស្រឡាញ់ ជីវិតខ្លួនឯង ហើយអ្នកណាយកភាសានឹងមកនិយាយកាលខ្ញុំនៅយុវវ័យរីករាយណាស់ ។

ដានី ៖ ពីណា បើតាមពូដូចថាពូចងចាំដំបូងគេ អ្នកណាដែលធ្វើឲ្យពូ ដូចថានិយាយទៅធ្វើឲ្យពូទឹក ឃើញនៅចាំដល់ឥឡូវនឹងណា ដែលនិយាយពីទឹកដី ដែលធ្វើឲ្យពូមានអារម្មណ៍រំភើបចង់ ការពារទឹកដីទេ?

សារ៉ាត់ ៖ ខ្ញុំអីឡោចជីដូនជីតាខ្ញុំ បាត់ទឹកបាត់ដី ក្នុងវ័យដែលនៅកុមារ គាត់និយាយប្រាប់ខ្ញុំ ហើយខ្ញុំ មកទទួលនយោបាយកម្ពុជាប្រជាធិបតេយ្យពេលដែលខ្ញុំពេលវ័យ ស្គាល់ច្បាស់ថាទឹកដី អធិបតេយ្យមានតំលៃណាស់ ។ ដូច្នេះ យើងមិនអាចយកអ៊ីមួយទៅដូរដោយវិធីលេងៗទេ ត្រូវតែខំការពារ ព្រោះខ្ញុំមានបងប្អូននៅខាងខេត្តក្រមួនស បាសាក់អីទើបនឹងដាច់ ខ្ញុំឈឺ ចាប់ ទើបនឹងដាច់ៗនៅឆ្នាំ១៩៨៩ ។

ដានី ៖ បាទ!អញ្ចឹងពូកខ្ញុំដូចជាអស់សំនួរអី ប៉ុន្តែខ្ញុំចង់សួរឈ្មោះពូ ដែលថាពូមានប្រសាសន៍មក កាលពីមុនមក ថាគាត់នៅណាខ្លះ ដែលធ្លាប់ធ្វើនៅក្នុងកង១៨០ជាមួយពូ?

សារ៉ាត់ ៖ ១៨០នៅជាមួយខ្ញុំមាន នែក!មួយ ហៀង រ៉េត ។

ដានី ៖ ហៀង រ៉េត?

សារ៉ាត់ ៖ បាទ!

ដានី ៖ គាត់នៅណា ហៀង រ៉េត?

សារ៉ាត់ ៖ គាត់នៅរ៉ៃដែក គេហៅអូរប៉ៃឡែវ ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី?

សារ៉ាត់ ៖ ប្រពន្ធគាត់ឈ្មោះ រ៉ៃ ។

ដានី ៖ នៅភូមិអីគេហៅភូមិអីគេ?

សារ៉ាត់ ៖ នៅភូមិរ៉ៃដែក អូរប៉ៃឡែវ ។

ដានី ៖ ឃុំអីនឹង?

សារ៉ាត់ ៖ ឃុំអូរសរិល ។

ដានី ៖ ឃុំអូរ?

សាវ៉ាត់ ៖ អូរសិរិល ស្រុកសំឡូត ។

ដានី ៖ ឃុំអូរសិរិល ស្រុកសំឡូត តាមផ្លូវបតទៅបាត់ដំបងវិញ?

សាវ៉ាត់ ៖ បាទៗ តាមផ្លូវត្រឡប់ទៅវិញ ។

ដានី ៖ ពីនេះទៅចំងាយប្រហែលប៉ុន្មាន?

សាវ៉ាត់ ៖ ហើយម្នាក់ទៀត ពីនេះទៅប្រហែលជា៣០គីឡូ អត់ដល់ទេ ក្នុងចន្លោះនឹង ។

ដានី ៖ ម្នាក់ទៀត អានឹងគាត់ធ្វើដែរ ឈ្មោះរ៉េតនឹង?

សាវ៉ាត់ ៖ គាត់ធ្វើចំការ ។

ដានី ៖ ប៉ុន្តែសម័យ?

សាវ៉ាត់ ៖ សម័យនឹងគាត់នៅនារីដែរ ។

ដានី ៖ នៅនារីខុសពីពូហើយក៏នៅ?

សាវ៉ាត់ ៖ នារីបណ្តែត ។

ដានី ៖ នារីបណ្តែត ។

សាវ៉ាត់ ៖ មួយទៀតនែក! ប៉ុង ឈា ។

ដានី ៖ ប៉ុង ឈា ប្រពន្ធគាត់ពូស្គាល់ទេ?

សាវ៉ាត់ ៖ ឈ្មោះស៊ឹម នៅភូមិជាមួយគ្នានឹង មួយទៀត ឡាយ ប៊ុនហាក់ ។

ដានី ៖ ខ្ញុំសួរឈាមិញ គាត់ធ្វើពីការខាងអីដែរ?

សាវ៉ាត់ ៖ ប្រធាននារីដែរ នារីបណ្តែតដែរ ។

ដានី ៖ ឡាយ ហាក់?

សាវ៉ាត់ ៖ ឡាយ ប៊ុនហាក់ ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអីដែរ?

សាវ៉ាត់ ៖ ឈ្មោះខន ។

ដានី ៖ គាត់នៅណាដែរ?

សាវ៉ាត់ ៖ គាត់នៅភូមិជាមួយគ្នានឹង គាត់ខាងបច្ចេកទេសនារីកងតូច ។ អឺ!ញ៉ែម គង់ មេ ។

ដានី ៖ ស្អីគង់?

សាវ៉ាត់ ៖ ញ៉ែមៗ ។

ដានី ៖ ញ៉ែម គង់?

សាវ៉ាត់ ៖ នៅនារីប្រឆាំង ។

ដានី ៖ ញ៉ែម គង់ប្រពន្ធគាត់ឈ្មោះអីដែរ?

សាវ៉ាត់ ៖ ប្រពន្ធគាត់ឈ្មោះ......អត់ទេ អត់ស្គាល់ ។

ដានី ៖ គាត់នៅណាផ្ទះគាត់?

សាវ៉ាត់ ៖ គាត់នៅស្តៅ គាត់ទៅនៅស្តៅ ។

ដានី ៖ ស្តៅភូមិអីគេ?

សាវ៉ាត់ ៖ ស្តៅនៅ ។

វណ្ណៈ ៖ គាត់ប្រធានកងពល?

សាវ៉ាត់ ៖ បាទ!គាត់ប្រធានកងពល ឥឡូវឡើងភូមិភាគ ។

វណ្ណៈ ៖ ប្រធានភូមិភាគបច្ចុប្បន្ន?

សាវ៉ាត់ ៖ អត់ទេ អត់ប្រធានទេ រង ។

ដានី ៖ ធំជាងឈឿន?

សាវ៉ាត់ ៖ ធំជាង ។

ដានី ៖ គាត់នៅភូមិអី គាត់នឹង?

សាវ៉ាត់ ៖ គាត់នៅស្តៅ នៅផ្សារស្តៅនឹង ទៅដល់ឃើញហើយ ប៉ុនគាត់នៅផ្ទះ មិនសូវនៅផ្ទះទេ ច្រើនទៅប្រចាំនៅខាងមុខសញ្ញាទន្លេសាប ។

ដានី ៖ នៅផ្សារស្តៅ?

សាវ៉ាត់ ៖ នៅខាងលិចផ្សារ អាផ្លូវទៅ ។

ដានី ៖ ផ្សារស្តៅនៅណាទៅ?

សាវ៉ាត់ ៖ ផ្សារស្តៅយើងរតនមណ្ឌលនេះ ។

ដានី ៖ នៅអាកន្លែងរតនមណ្ឌល នៅទីរួមស្រុកនឹងម៉ង?

សាវ៉ាត់ ៖ បាទ!ហ្នឹងហើយ ។

ដានី ៖ ផ្សារស្តៅ?

សាវ៉ាត់ ៖ ទៅសួរគេថា គង់ៗខ្មែរក្រហមនឹង ។

ដានី ៖ ផ្សារស្តៅ គង់មេបញ្ជាការរងភូមិភាគ៥?

សាវ៉ាត់ ៖ បាទ!ភូមិភាគទី៥ និងប្រធាននាវាប្រឆាំង គាត់កំរិតត្រឹមបានរៀនសូត្រទេ អត់ទាន់បានប្រើប្រាស់ ប៉ុននៅ១៨០ ។

វណ្ណៈ ៖ ហើយគាត់អត់បានចុះទៅសមុទ្រទេ មិនទាន់ចុះទៅ?

សារ៉ាត់ ៖ អត់ទេ នៅទេ ទើបនឹងត្រឡប់មកពីស្រុកចិនវិញ ដូចណាំ ឡូនដែរ ។

វណ្ណៈ ៖ មានពីណាទៀតដែរ?

សារ៉ាត់ ៖ មនុស្សសំខាន់ខ្ញុំចាំបានតែប៉ុននឹង ដូចអស់ហើយ ។

វណ្ណៈ ៖ ពូមានស្គាល់វ៉ាន់ទេ?

សារ៉ាត់ ៖ វ៉ាន់នឹងនៅខាងណា?

វណ្ណៈ ៖ វ៉ាន់១៨០ ១៦៨នោះ ។

ដានី ៖ មានពីនោះមកគាត់ខាង ។

វណ្ណៈ ៖ ណាំ ឡូនប្រាប់ ឈ្មោះឈឹម ឈ្មោះអីគេ ឈឹមដែរ?

សារ៉ាត់ ៖ ប្រហែលជាស្លាប់មិនដឹងតាមខ្ញុំចាំ ឈឹមដូចជាស្លាប់ មានប៉ុនស្លាប់ ហើយវ៉ាន់ខ្ញុំអត់ច្បាស់ទេ ។

ដានី ៖ អញ្ចឹងខាងភូមិរ៉ែដែកនឹង ជិះតាមផ្លូវនឹងទៅវិញត្រង់?

សារ៉ាត់ ៖ បាទ!ត្រង់ ។

ដានី ៖ អត់ទាន់ដល់ត្រែងទេ ហើយហួសត្រែង?

សារ៉ាត់ ៖ អត់ទេ ខាងលិចស្ពានដងទង ។

ដានី ៖ ខាងនេះ ខាង?

សារ៉ាត់ ៖ ខាងក្រោយស្ពានដងទង យើងទៅពីនេះបានន័យថាខាងមុខរបស់ដងទងណា ដល់យើងមើលពីស្ពាននឹងវិញ ត្រឡប់ក្រោយងាកមកក្រោយវិញបានដឹង ។

ដានី ៖ ជិតស្ពានដងទងដែរ?

សារ៉ាត់ ៖ ខ្ញុំគូសសញ្ញាឲ្យមួយ ទៅពីយើងនេះទៅគេហៅភ្នំព្រៃរំចេក បាត់ព្រៃមួយខ្ញុំច្រឡំ ទៅអញ្ចឹងនេះចាត់ទុកថាផ្ទះយើង ទៅពីនឹងបន្តិចទៅផ្សារ ។

ដានី ៖ បាទ!អញ្ចឹងពូខ្ញុំដូចជាអស់សំនួរត្រូវសួរនាំពីពូហើយ ដូចថាអរគុណពូច្រើន ដែលចំណាយពេលសំនេះសំនាលជាមួយពួកខ្ញុំ ប៉ុន្មានជិត២ម៉ោង ជិត៣ម៉ោង ហើយពូមានសំនួរអីចង់សួរនាំពួកខ្ញុំដូចថាទាក់ទងនឹងសម័យ៣ឆ្នាំនឹង ដូចមានសំនួរចង់សួរពួកខ្ញុំៗអាចឆ្លើយបាន ។

សារ៉ាត់ ៖ ខ្ញុំមានសំនួរអីទេខ្ញុំសួរថាអ៊ីដែរស្វែងរកការពិតនឹង តើប្អូនៗចុះកត់ត្រាចូលក្នុងប្រវត្តិសាស្ត្រ ឬក៏ដើម្បីការពិតនៅកម្ពុជា ធានារឿងពិតនៅកម្ពុជាបង្ហាញឲ្យច្បាស់?

ដានី ៖ អ៊ីដែលពួកខ្ញុំសួរនាំពូនេះ ពួកខ្ញុំយកទៅសរសេរយកទៅចងក្រងយើងសរសេរបោះពុម្ពក្នុងទស្សនាវដ្ដីស្វែងរកការពិតនឹង សព្វផ្សាយជាទូទៅ សម្រាប់ក្មេងៗជំនាន់ក្រោយ សម្រាប់

អ្នកសិក្សាស្រាវជ្រាវ សម្រាប់ពេលដែលមានតុលាការគេបង្កើតឡើងនឹង ក៏គេអាចយកឯកសារយកអ៊ីដែលពួកខ្ញុំសរសេរសួរនាំពីពូនឹង គេអាចយកទៅមើលដែរ ហើយគេអាចយកទៅប្រើការដែរ ។ ពូយល់ឃើញយ៉ាងម៉េចដែរ ពូអាចឲ្យគេប្រើការ អនុញ្ញាតិឲ្យគេយកទៅប្រើការបាន?

សារ៉ាត់ : តាមការនិយាយរបស់ខ្ញុំនេះ ក៏ខ្ញុំចង់បង្ហាញអ៊ីមួយដែលខ្ញុំបានធ្វើ ហើយបានដឹង ពិតតែចាំបានកន្លែងខ្លះវាជាការពិតរបស់សម្តីរបស់ខ្ញុំ អ៊ីខ្លះដែលខ្ញុំនិយាយដូចថាពាក្យថាខ្ញុំច្រឡំទេ អានឹងវាជាការច្រឡំ ហើយឬការភ្លេច ។ ដូច្នេះ ពាក្យនេះការពិតនេះ ទាល់តែយើងដឹង យើងឮ យើងឃើញ បានយើងនិយាយ ហើយបើយើងស្រពិចស្រពិលយើងបាននិយាយថាអានឹងខ្ញុំមិនច្បាស់ទេ អានេះជាការយោបល់យើងចេញមកហើយ ។ ហើយខ្ញុំរីករាយៗថាប្អូនៗទាំងអស់បានមកអញ្ជឹង ហើយខ្ញុំក៏អត់នឹកស្មានថាប្អូនៗមកស្វែងរកខ្ញុំជួប ។

ដានី : បាទៗសំណាងមែនទែនបានជួបពូនៅផ្ទះពូ បើថាឲ្យពួកខ្ញុំទៅរក ទៅដល់ភូមិពូ ផ្ទះពូនៅនោះប្រហែលជាខ្ញុំពិបាកទៅមែនទែន ប៉ុន្តែដោយចៃដន្យសំណាងខ្ញុំបានជួបពូ ។

គី : បើនិយាយមែនទែន ជួបពូសំណាងពួកខ្ញុំវិញ ដោយសារពត៌មានល្អៗពីពូបានកាន់តែច្រើនយើងដឹងហើយក្នុងសម័យនឹងគេអត់មានឯកសារអី ជាទូទៅគ្រាន់ចុះតាមភូមិតាមឃុំពេលសម្ភាសន៍អញ្ជឹងទៅបានដឹងសាច់រឿងច្រើន ។

សារ៉ាត់ : ហើយខ្ញុំក៏មានសូមអរគុណដល់ប្អូនៗដែល ដោយប្អូនៗបានប្អូនៗពេលនោះខ្ញុំកំណត់ថាប្អូនមិនអាចដឹងបានទេ ។

គី : ខ្ញុំកើតក្រោយអត់ដឹងអីសោះ ។

សារ៉ាត់ : ការយល់ដឹងតិចតួច អញ្ជឹងបានប្អូនៗសំនួរចុងក្រោយមិញ យើងចង់ចងក្រងប្រវត្តិសាស្ត្រមួយនៅកម្ពុជាឲ្យមានអីថាវាជាការពិតឲ្យខ្មែរយើងអនុវត្ត កុំឲ្យគ្រាន់តែឮៗអី!មិនបាន អានឹងខ្ញុំអត់ចូលចិត្តទេ អត់ចូលចិត្តចង់និយាយម៉េច មិនមែនមិនចូលចិត្តវប្អូនទេ ពាក្យថាៗគ្រាន់តែឮគេរំដើបរំដួលអានឹង អ៊ីដែលពិត ដឹង យើងយកជាការ អ៊ីដែលមិនពិត ដឹងហើយមិនបានរឿងពិត យើងថាជាពិតអានឹងខុស ។ ហើយតែងតែខ្ញុំបាន តែងតែឮពាក្យចាស់ គាត់និយាយថា ឮគេថា១០០០ដង អត់ស្មើនឹងយើងឃើញកហើយស្ទាបម្តងទេ ។ ដូច្នេះ វាតិចណាស់ទូរលេខនេះ ខុសត្រូវគ្នាច្រើន ១គុណនឹងម៉ាពាន់ ទេម៉ាពាន់ ។

ដានី : បាទ!អញ្ជឹងពូខ្ញុំថ្លែងអំណរគុណពូច្រើន ដែលចំណាយពេលសំនេះសំនាលជាមួយពួកខ្ញុំនេះអរគុណពូច្រើន ។

សារ៉ាត់ ៖ អញ្ជើងខ្ញុំចេះ ខ្ញុំចង់បានលេខទូរសព្ទ័មានទេ?

ដានី ៖ មាន ។

«ចប់»